# នានាធម្មសមុហោ

អាស្រមសន្តិវ៉ន

ជើងគ្រាវ

លេខ១៣៦អឺឲ វិថីនេរក្ខុមិន្ទ រាជធានីភ្នំពេញ

ព.ស. ២៥១៥ គ.ស. ១៩៧១

អំណោយពីលោក ចៅ ឃុន សំរឹម របស់កុលាបបៃ
ដើម្បីតំកល់ទុកក្នុង elibrary of Cambodia កុម្ភៈ 2015

# នានាធម្មសមុហោ

រៀបរៀងដោយ

ភិក្ខុ ម៉ី - ស៊ាន

នៅ

អាស្រមសន្តិវ័ន សង្កាត់ជើងគ្រាវ
ស្រុករលាប្អៀរ ខេត្រកំពង់ឆ្នាំង

ថ្ងៃសុក្រ ១៤ រោចខែស្រាពណ៍ឆ្នាំកុរត្រីស័ក
ព.ស. ២៥១៥
២០.៨.១៩៧១



# អារម្ភកថា

សៀវភៅនេះ ខ្ញុំបានសរសេររៀបរៀងធម្មកថាផ្សេងៗ មានច្រើនឈ្មោះ ក្រោមក្នុងទីនេះជាមួយគ្នា ហើយសន្មតនាមថា នានាធម្មសមុហោ ប្រែថា ប្រជុំធម៌ផ្សេងៗ ។

ច្បាប់ដើម ដែលជាពូជបណ្តុះសៀវភៅ នានាធម្មសមុហោ នេះ ឲ្យកើតឡើងនោះគឺ ១- ព្រះត្រៃបិដក ; ២- វចនានុក្រមខ្មែរ ; ៣- ភាណវារ និងសត្តបរិត្ត - ទ្វាទសបរិត្ត; ៤- សមាធិនិទ្ទេសនិង អភិធម្មត្ថាធិប្បាយ; ៥- ជាតិ. មោក្ខបាលី-ប្រែ, ធម្មបទដ្ឋកថា និងកច្ចាយនូបត្ថម្ភកៈ ។ ល ។ ច្បាប់ទាំងប៉ុណ្ណេះ ជាដើម ដែលខ្ញុំបានសរសេរដកស្រង់ចម្លងយកស្រាប់ៗ ខ្លះ ដែលពុំចម្លងស្រាប់ៗទេ គ្រាន់តែមើលសង្កេតពិនិត្យសម្រិតសម្រាំងយកតែអត្ថរស គឺរសនៃសេចក្តីកម រចនាគាត់តែងរៀបរៀងខ្លះ ទុកដូចជាប្រទីបបំភ្លឺផ្លូវឬជាគ្រឿងដឹកដៃចង្អុលបង្ហាញផ្លូវ ឲ្យខ្ញុំរៀបរៀងធ្វើសៀវភៅ នានាធម្មសមុហោ នេះ កើតឡើងបាន ។

ធម្មកថាក្នុងសៀវភៅ នានាធម្មសមុហោ នេះខ្ញុំចែកចេញជាកណ្ឌ ៗ ទាំងអស់មាន ៨ កណ្ឌ ផ្សេងៗ គ្នាដាច់ដាប់ៗ ដូចមានក្នុងខាងមុខតទៅនោះឯង ។

សូមឧទ្ទិសចំណែកបុណ្យដ៏ប្រសើរខ្ពង់ខ្ពស់ ដែលសម្រេចមកអំពីការរចនាគាក់តែងរៀបរៀងសៀវភៅ នានាធម្មសមុហោ នេះ បូជាចំពោះបុព្វបុរសទាំងឡាយ មានមាតាបិតាគ្រូឧបជ្ឈាយាចារ្យជាដើម ព្រមទាំងពួកញាតិទាំងអស់ សូមឲ្យលោកមានសិរីវុឌ្ឍិភាព ដោយសម្បត្តិសុខគ្រប់ប្រការ ក្នុងសុគតិភពរហូតដល់ព្រះនិព្វានជាទីបំផុត !

សូមឲ្យព្រះពុទ្ធសាសនាបានចម្រើនរុងរឿងឋិតថេរជាស្ថាពរតរៀងទៅ !

សូមឲ្យពុទ្ធបរិស័ទទាំងឡាយ បានប្រកបដោយសេចក្តីសុខចម្រើន ក្នុងគ្រះ

ពុទ្ធសាសនា បរិបូណ៌ដោយ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ អស់កាលជាយូរអង្វែងទៅហោង ។

ព. ស. ២៥១៥

គិត្ត មុី – សាន

អាស្រមសន្តិវ័ន ជើងគ្រាវ

# ឧទ្ទិសកថា

យើងខ្ញុំទាំងឡាយ ជាក្រុមមិត្តពុទ្ធបរិស័ទ អ្នកឧបត្ថម្ភការប្រាប្រសន្តិវ៉ែន នៅក្នុងសង្កាត់ជើងគោរ ស្រុកលោកប្លៀរខែត្រកំពង់ឆ្នាំង ព្រមទាំងអ្នកភ្នំពេញ បានរួមកម្លាំងសាមគ្គីជាមួយគ្នា ចំណាយប្រាក់តាមសទ្ធារៀង ៗ ខ្លួន បោះពុម្ពសៀវភៅ នានាធម្មសមុហោ នេះ ចំនួន ១០០០ ច្បាប់ សាងទុកជាមនុស្សាររិយ៍ក្នុងព្រះពុទ្ធសាសនា សម្រាប់ចែកជាធម្មទាន ដល់ពួកពុទ្ធបរិស័ទទាំងឡាយជាសាធារណៈទូទៅ ដែលត្រូវការសិក្សារៀនសូត្រ ។

សូមឧទ្ទិសចំណែកកុសលដ៏ប្រសើរ ដែលកើតអំពីធម្មទាននេះ ជូនចំពោះលោកមានគុណទាំងឡាយ មានមាតាបិតាជាដើម និងក្រុមញាតិទាំងអស់ សូមឲ្យលោកបានសម្រេចនូវលោកិយសម្បត្តិ សម្បូណ៌ដោយសិរីសួស្តីជ័យមង្គលវិបុលសុខសព្វប្រការ និងលោកុត្តរសម្បត្តិគឺមគ្គផលព្រះនិព្វាន ដោយសារផលនៃធម្មទានដ៏ប្រសើរខ្ពង់ខ្ពស់នេះ កុំបីអាក់ខានឡើយហោង ។

សូមឲ្យសាធុជនទាំងឡាយ បានប្រកបដោយសេចក្តីសុខចំរើនល្អពលាស់ផុះផាលក្នុងព្រះពុទ្ធសាសនាគ្រប់កាល កុំបីឃ្លាតឃ្លាយទៅជាប្រការអ្វីដទៃឡើយ ។

សូមឲ្យសព្វសត្វទាំងឡាយ មានតែសេចក្តីសុខ មិនបានពៀរនឹងគ្នា សព្វ ៗ កាលទៅហោង ។

# បញ្ជីមាតិកា


មាតិកានុក្រម ទំព័រ

អារម្ភកថា ក

ឧទ្ទិសកថា ខ

នាមនៃគ្រូបរិស័ទអ្នកមានបច្ច័យបរិស័ទអ្នកមានសទ្ធាចំណាយ

ប្រាក់បោះពុម្ព ឃ

## ភណ្ឌទី ១

បទនមស្ការ ២

ពុទ្ធបាទនមស្ការគាថា ២

គុណភាពនៃព្រះបាទនិងស្នាមព្រះបាទ ៣

ពុទ្ធបាទលក្ខណៈ ៥

ពុទ្ធបទចេតិយ ៦

ស្រង់គោលសេចក្តី ៨

មហាបុរិសលក្ខណៈ ៣២ ប្រការ ៩

អាទិសង្កេតគាថា ១៣

សំណូមពរសុខសាន្ត ១៣

## ភណ្ឌទី ២

ធាតុកម្មដ្ឋាន ១៦

មាតិកានុក្រម ទំព័រ


ធាតុ ៤ ... ១៦

លក្ខណៈនិងអាការៈនៃធាតុទាំង៤ បឋវីធាតុ ... ១៧

អាបោធាតុ ... ១៨

តេជោធាតុ ... ១៩

វាយោធាតុ ... ២០

ធាតុភាគបង្វាយ ... ២៣

ភាពដែលមិនបែកចាកគ្នានៃធាតុទាំង ៤ ... ២៤

ធាតុភាពនៃឧបាទិន្នករូប និងអនុបាទិន្នករូប ... ២៤

ពុទ្ធទាំង ... ២៨

ការតំរិះពិចារណា ... ២៦

ការកុកម្មដ្ឋាន ... ២៩

អភិណ្ហបច្ចវេក្ខណធម៌ ... ៣១

កាយគតៈ ១២ ... ៣៣


## ភាគទី ៣


បព្វតសូត្រ ... ៣៧

អាទិត្តសូត្រ ... ៤០

នៃកេបសូត្រ ... ៤៨

មាតិកានុក្រម ទំព័រ

ចូឡវេទល្លសូត្រ សក្កាយបញ្ហា ៥០

សក្កាយសមុទយបញ្ហា ៥១

សក្កាយនិរោធបញ្ហា ៥១

សក្កាយនិរោធគាមិនីបដិបទាបញ្ហា ៥២

ឧបាទានបញ្ហា ៥៣

សក្កាយទិដ្ឋិបញ្ហា ៥៣

មគ្គបញ្ហា ៥៥

សង្ខារបញ្ហា ៥៧

និរោធបញ្ហា ៥៨

វេទនាបញ្ហា ៦១

អនុស័យបញ្ហា ៦២

បដិភាគបញ្ហា ៦៥

ធម្មទិន្នាបសំសា ៦៦


## ភណ្ឌទី ៤


បេតវត្ថុ រឿងខេត្តូបមាប្រេត ៦៩

រឿងប្រេតជាមាតានៃព្រះសារីបុត្ត ៧០

រឿងនាងមត្តាប្រេត ៧២

| មាតិកានុក្រម | ទំព័រ |
| --- | --- |


រឿងខន្ធាប្រេត ៧៨

រឿងសានុវាសិប្រេត ៨២

បាលីឧទ្ទិសទក្ខិណាទានដល់ពួកញាតិដែលលោងខ្លួន

ទៅកាន់លោកខាងនាយ ៨៨


## ភាគទី ៥


បុព្វករណ៍ និងបុព្វកិច្ចនៃឧបោសថកម្មនិងបវារណាកម្ម ៩០

សេចក្តីពន្យល់ ៩៦

ចំនួនឧបោសថក្នុងរដូវទាំង ៣ ៩៦


## ភាគទី ៦


បត្តគណនា បត្តគណនាឧត្តណ្ហណានុជាងធំ ការទ្រង់អនុញ្ញាតឲ្យភិក្ខុ

រឿងកប់បត្ត ១០៦

ដំណើរកប់បត្ត ១០៧

ខែ ១២ ឬ ១៣ ខាងចន្ទគតិ ១០៨

ខែ ១២ ខាងសុរិយគតិ ១០៩

សុក្កបត្តនិងកាឡបត្ត ១១០

ពុទ្ធសករាជ ១១១

ពិធីស្វែងរកពុទ្ធសករាជ ១១៣

| មាតិកានុក្រម | ទំព័រ |
|---|---|
| ចាលីសម្រាប់សូត្រសន្លាក់ទី ១ | ១១៣ |
| " " ២ | ១១៤ |
| អតីតកាល | ១១៤ |
| បច្ចុប្បន្នកាល | ១១៥ |
| អនាគតកាល | ១១៦ |
| សំនួរស័ព្ទសម្រាប់ផ្លាស់ថ្ងៃ ខែ ឆ្នាំ បកតិសំនួរ | ១១៧ |
| សេចក្ដីពន្យល់អំពីរបៀបផ្លាស់ថ្ងៃ ខែ ឆ្នាំ | ១២០ |
| បច្ចុប្បន្នកាល ឈ្មោះឆ្នាំ ១២ | ១២២ |
| ឈ្មោះរដូវ ៣ | ១២៣ |
| ឈ្មោះខែ ១២ | ១២៣ |
| ឈ្មោះបក្ស ២ | ១២៤ |
| ចំនួនតិថី ១៥ | ១២៥ |
| ឈ្មោះថ្ងៃ ៧ | ១២៦ |
| ស័ក ១០ សម្រាប់កប់លំដាប់ឆ្នាំ | ១២៦ |
| កាសិគោរពគាថា | ១២៧ |
| អាសានពេចន៍ | ១២៨ |

ភណ្ឌទី ៧

មាតិកានុក្រម ទំព័រ


ចតុរារិយសច្ចសង្ខេប ១៣១

អរិយសច្ចធម៌ ៤ យ៉ាង ១៣១

ទុក្ខអរិយសច្ច ១៣២

ទុក្ខសមុទយអរិយសច្ច ១៣៤

ទុក្ខនិរោធអរិយសច្ច ១៣៥

ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១៣៦

អត្ថន័យអរិយសច្ច ៤ ១៣៧

សោឡសកិច្ច ១៣៩

ញាណ ៣ ប្រការ សច្ចញ្ញាណ កិច្ចញ្ញាណ ១៤០

កតញ្ញាណ ១៤២

និគមគាថា ១៤៥

អវសានពេចន៍ ១៤៩

ព្រះសូត្រ

យក្ខសូត្រ ១៥៣

វិត្តសូត្រ ១៥៤

គីតសូត្រ ១៥៥

អត្ថបទតាំងសេចក្តីប្រាជ្ញា (បែបទី ១) ១៥៧

មាតិកានុក្រម ទំព័រ

## ភណ្ឌទី ៨


បត្តិទានគាថា យំ កិញ្ចិ .. ១៦១

" យានទេតា ... ១៦៤

អភយបរិត្តគាថា ១៦៧

អត្ថបទសូត្រលើកបុណ្យ ១៦៨

អត្ថបទសូត្រតាំងសេចក្តីប្រាថ្នា (បែបទី២) ១៧២

ពាក្យអារាធនាធម៌ទេសនា ១៧៤


---

## សេចក្តីបញ្ជាក់

សៀវភៅធម៌ នានាធម្មសម្ភារ នេះ

ខ្ញុំ គ្រាន់តែបានជួយសូធ្យផ្ទៀងតាមសំណៅដើម ជួយកែឃ្លាល្បះ និងអក្ខរាវិរុទ្ធតាមសំណូមពររបស់ម្ចាស់អត្ថបទប៉ុណ្ណោះ ពុំមានដកឬបន្ថែមសេចក្តីទៅក្នុងអត្ថបទនៃធម៌ឬសូត្រណាមួយឡើយ គឺសេចក្តីនៃអត្ថបទដើមយ៉ាងណា ក៏ទុកទាំងស្រុងយ៉ាងនោះ ។

ធ្វើនៅវត្តកែវព្រះភ្លើង សង្កាត់លេខ ៦ ក្រុងភ្នំពេញ

ព្រះញាណសំវរ ចៅអធិការ

ហេង – លាងហោ

# ភណ្ឌទី១

## បទនមស្ការ ពុទ្ធបាទនមស្ការគាថា

## មហាបុរិសលក្ខណៈ ៣២ ប្រការ

# បទនមស្ការ

នមត្ថុ រតនត្តយស្ស ។

*សូមនមស្ការ ចំពោះព្រះរតនត្រ័យគឺ*

*ព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ ដោយគោរព ។*

## ពុទ្ធបាទនមក្ការគាថា

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

*ព្រះសម្ពុទ្ធអង្គណា ប្រសើរសេដ្ឋាលើសសត្វលោក*
*កាត់កិលេសស្មោកគ្រោក ដូចជាកេតពាំងអស់បាន ។*
*ញាំងជនជាអនន្ត អនេកលន់ឲ្យមានញាណ*
*ក្រាស់ដឹងធម៌និព្វាន សុខក្សេមក្សាន្តឥតមានមោះ(១) ។*
*ខ្ញុំសូមថ្វាយបង្គំ ព្រះបរមសម្ពុទ្ធនោះ*
*ព្រះអង្គស្តេចចូងផ្តោះ ផុតប្រាំងភពល្អៃក្រពេក ។*
*ព្រះអង្គជាទង់ជ័យ នៃលោកត្រ័យថ្លៃអនេក*
*មានតែព្រះអង្គឯក(២) ជាទីពឹងសត្វត្រៃភព ។*

---

១ ឥតមានមន្ទិលសៅហ្មងទេ ។ ២ មានតែព្រះសម្ពុទ្ធមួយព្រះអង្គទេដែលជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

ស្នាមព្រះបាទឯណា ព្រះសាស្ដាប្រតិស្ឋាន
លើផ្លូវខ្សាច់កល្យាណា ក្បែរឆ្នេរស្ទឹងនម្មទា ។
ស្នាមព្រះបាទឯណា ល្អថ្លៃថ្លាព្រះភគវ
ជាន់ចុះលើពសុធា ធាតុសច្ចពន្ធពិត ។
និងក្នុងសុមនកូដ យើងខ្ញុំសូត្រឈ្មោះពិសិដ្ឋ
និងនៅតាមនបពិត ក្នុងយោនកបុរី ។
ខ្ញុំសូមថ្វាយបង្គំ ហត្ថប្រណម្យទូនសិរសី
ព្រះបាទព្រះមុនី ព្រមទាំងស្នាមព្រះបាទនោះ ។
ដោយចិត្តខ្ញុំជ្រះថ្លា ទូនសិរសាវន្ទាផ្ដោះ
ព្រះបាទព្រះអង្គនោះ សូមសុខសាន្តសព្វកាល ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ

យោនកបុរេ នម្មទាយ នទិយា បញ្ច បាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមថ្វាយបង្គំ ព្រះបរមពុទ្ធបាទ
ប្រាំបានប្រសើរស្អាត អំពីឆ្ងាយកល់យប់ព្រឹក ។
មួយ នៅតាវែក្រខណ្ឌ ភ្នំសុវណ្ណមាលិក
ជាបានល្អគួរនឹក ពីរ សុវណ្ណបពិត ។
បី ភ្នំសុមនកូដ យើងខ្ញុំសូត្រឈ្មោះទៀតពាក់
កប់ទៀតតាមប្រាកដ បួន យោនកបុរី ។
ប្រាំ ស្ទឹងនម្មទា ព្រះគត់ក្រោសប្រណី
សព្វសត្វក្នុងភពបី ព្រះអង្គទ្រង់ប្រតិស្ឋាន ។
ទុកឲ្យសត្វគ្រប់គ្នា ថ្វាយវន្ទាទៀតកល់ក្រុណា
ប្រយោជន៍ឲ្យសត្វបាន សុខក្សេមក្សាន្តប្រសើរហោង ។

ពុទ្ធបាទនមក្ការគាថា ចប់

## គុណភាពនៃព្រះបាទនិងស្នាមព្រះបាទ

ព្រះបាទនិងស្នាមព្រះបាទ នៃព្រះសម្ពុទ្ធបរមគ្រូ មានគុណភាពដ៏ប្រសើរខ្ពង់ខ្ពស់ គួរឲ្យសត្វលោកធ្វើ នូវសេចក្ដីគោរពនមស្ការថ្វាយបង្គំ

ដោយសេចក្ដីជ្រះថ្លាមែនពិត ។

## ពុទ្ធបាទលក្ខណៈ

ព្រះបាទនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានលក្ខណៈដ៏ប្រសើរវិសេសអស្ចារ្យ ប្លែកពីមនុស្សសាមញ្ញធម្មតាទាំងអស់ដូច្នេះគឺ

១- ព្រះមហាបុរស មានព្រះបាទប្រកស្ថានល្អ គឺមានផ្ទៃព្រះបាទទាំងគូបស្មើសព្វអន្លើ ។

២- ក្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមរបស់ព្រះមហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់ចំណុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ។

៣- ព្រះមហាបុរស មានព្រះបណ្ហិ គឺកែង វែង ។

៤- មានព្រះអង្គុលី គឺម្រាមព្រះហស្ត និងម្រាមព្រះបាទវែងៗ ។

៥- មានផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទដ៏ទន់ល្មើយ ។

៦- មានផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទ ប្រទាក់ដោយក្រឡាដូចជាសំណាញ់ ។

៧- មានព្រះបាទដូចជាអណ្ដើកក៏ឡើងខាងលើ ។

៨- មានព្រះជង្ឃា គឺស្មងជើងមូលក្រសួល ស្រដៀងនឹងស្មងសត្វទ្រាយ ។

លក្ខណៈព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ទាំង៨ប្រការខាងលើនេះ មានសេចក្តីពិស្តារនៅក្នុងលក្ខណសូត្រ គម្ពីរទីឃនិកាយបាដិកវគ្គ ឆដ្ឋភាគ លេខ ១៩ ផង ក្នុងព្រហ្មាយុសូត្រ គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ ឆដ្ឋភាគលេខ ២៥ ផង ។

ខ្ញុំសរសេរដកស្រង់យកសេចក្តីខ្លីៗមកតម្កល់ទុក ក្នុងទីនេះ ដើម្បីសម្តែងនូវគុណភាពឲ្យឃើញថា ព្រះបាទរបស់ព្រះសម្ពុទ្ធជាម្ចាស់ មានលក្ខណៈប្រសើរវិសេស លើសមនុស្សសាមញ្ញជនទាំងអស់ ល្មមឲ្យជឿជាក់ថា ព្រះអង្គមានបុណ្យបារមីធំខ្ពង់ខ្ពស់ប្រសើរអស្ចារ្យ ឥតមានមនុស្សទេវតាណា ប្រសើរស្មើនឹងព្រះអង្គឡើយ ។

## ពុទ្ធបទចេតិយ

ឯស្នាមព្រះបាទ របស់ព្រះសម្ពុទ្ធជាម្ចាស់នោះសោត ក៏ជាវត្ថុសក្តិសិទ្ធិមានគុណភាពដ៏វិសេសវិសាល អាចញុំាងប្រយោជន៍ឲ្យសម្រេចដល់សត្វលោកទូទៅទាំងអស់ បើសត្វលោក បានធ្វើនូវសេចក្តីគោរពនមស្ការ ដោយចិត្តជ្រះថ្លា ។

ស្នាមព្រះបាទនោះ បើព្រះអង្គទ្រង់ប្រតិស្ឋានទុកក្នុងទីឋានណាមួយហើយ ក៏អាចតាំងនៅឋិតថេរអស់កាលយូរអង្វែង ឥតមានធម្មជាតិអ្វីមួយ ដែលជាសត្រូវធ្វើឲ្យវិនាសអន្តរាយបានឡើយ ។

ក្នុងគម្ពីរបាលី បានសំដែងសេចក្ដីសរសើរដំពីកេះ ចំពោះស្នាមព្រះបាទរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់យ៉ាងនេះ ថា

ពុទ្ធានំ ហិ បទចេតិយំ អធិដ្ឋហិត្វា អក្កន្តដ្ឋានេយេវ បញ្ញាយតិ ន អញ្ញត្ថ យេសញ្ច អត្ថាយ អធិដ្ឋិតំ ហោតិ តេវ នំ បស្សន្តិ តេសំ បន អទស្សនករណត្ថំ ហត្ថិអាទយោ វា អក្កមន្តុ មហាមេឃោ វា បវស្សតុ វេរម្ភវាតា វា បហរន្តុ ន នំ កោចិ មក្ខេតុំ សក្កោតិ(១) ។

មែនពិត បទចេតិយ គឺស្នាមព្រះបាទ របស់ព្រះពុទ្ធទាំងឡាយ រមែងឃើញមានប្រាកដ តែក្នុងទីដែលព្រះអង្គទ្រង់អធិដ្ឋានហើយជាន់ទុកប៉ុណ្ណោះឯង មិនឃើញមានប្រាកដក្នុងទីដទៃទៀតឡើយ, បើ (ស្នាមព្រះបាទណា) ដែលព្រះអង្គទ្រង់អធិដ្ឋានហើយ ដើម្បីជាប្រយោជន៍ដល់ពួកជនទាំងឡាយណា ពួកជនទាំងឡាយនោះ រមែងបានឃើញជាក់នូវស្នាមព្រះបាទនោះដោយពិត (ពុំខានទេ), សេចក្ដីអស្ចារ្យវិសេសថា ទោះបីហ្វូងសត្វទាំងឡាយមានដំរីជាដើម ជាន់រំលុបចោលក្ដី មហាមេឃបង្អុរភ្លៀងធំចុះមករំលាយចេញក្ដី វេរម្ភវាត គឺខ្យល់ដែលវិល ឬខ្យល់កំបុតត្បូង បក់ប្រហារត្រឡប់ប្រសព្វគ្នា អំពីទិសផ្សេងៗឲ្យលុប

១ ស្រង់ចេញពីគម្ពីរធម្មបទដ្ឋកថា ក្នុងអប្បមាទវគ្គវណ្ណនា រឿងសាមាវតី ។

ឬក្តិចវៃលទៀលផ្កាប់ពៅភ្ញ ( នូវស្លាមព្រះបាទ ) ដើម្បីធ្វើមិនឲ្យពួកជន ទាំងឡាយនោះបានឃើញ ( កំធ្វើឲ្យវិនាសពុំកើតទេ ) គឺជា ឥតមាន សភាវ អ្វីមួយ ( ដែលមានឫទ្ធិអំណាច ) អាចលុបលាងចោល នូវស្លាម ព្រះបាទនោះបានឡើយ ។

## ស្របង់គោលសេចក្តី

តាមដំណើរសេចក្តីខាងលើនេះ ឃើញថា ស្លាមព្រះបាទនៃព្រះ សម្ពុទ្ធបរមគ្រូ មានគុណានុភាពដ៏អស្ចារ្យ ៣ យ៉ាងគឺ

១ ស្លាមព្រះបាទ មានប្រាកដតែក្នុងទីដែលព្រះអង្គទ្រង់អធិដ្ឋាន ហើយជាន់ទុកប៉ុណ្ណោះឯង មិនមានប្រាកដក្នុងទីឯទៀតទេ ;

២– ស្លាមព្រះបាទ បើព្រះអង្គទ្រង់អធិដ្ឋាន ដើម្បីប្រយោជន៍ដល់ ពួកជនណា ទើបពួកជននោះបានឃើញ ;

៣– ស្លាមព្រះបាទ ដែលព្រះអង្គបានអធិដ្ឋានជាន់ទុករួចហើយ ឥតមានសភាវៈអ្វីមួយជាសត្រូវ អាចលុបលាងចេញបានឡើយ ។

ព្រះបាទនិងស្លាមព្រះបាទ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែល ប្រកបដោយមហាបុរិសលក្ខណៈ ដូចសំដែងមកហើយនេះ ជាគន្លឹះ ដ៏វេរត្តិសិទ្ធិ មានគុណភាពដ៏ប្រសើរ អាចនាំមកនូវប្រយោជន៍ និង សេចក្តីសុខដល់សត្វទាំងឡាយ ដែលមានចិត្តសទ្ធាជ្រះថ្លា បានការព

នមស្ការថ្វាយបង្គំមែនពិត ។

## គុណភាពនៃព្រះបាទនិងស្នាមព្រះបាទចប់

បន្ទាប់ពីនេះទៅ នឹងស្រង់យកមហាបុរិសលក្ខណៈ ៣២ ប្រការ ដែលមានក្នុងលក្ខណសូត្រ និងព្រហ្មាយុសូត្រនោះ មកតម្កល់ទុកក្នុងទំព័រខាងមុខនេះ រៀងដោយឡែកទៀត ។

## មហាបុរិសលក្ខណៈ ៣២ ប្រការ

ព្រះតថាគត អរហន្ត សម្មាសម្ពុទ្ធ បរមគ្រូរបស់យើងទាំងឡាយ ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការយ៉ាងនេះគឺ

១- សុប្បតិដ្ឋិតបាទោ ព្រះមហាបុរស មានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។

២- ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ ត្រង់ផ្ទៃព្រះបាទទាំងគូខាងក្រោម របស់ព្រះមហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់ និងដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ។

៣ អាយតបណ្ហិ ព្រះមហាបុរស មានព្រះបណ្ហិ គឺកែងវែងៗ

៤- ទីឃង្គុលី មានព្រះអង្គុលី គឺម្រាមព្រះហស្ថ និងម្រាមព្រះបាទវែងៗ ។

៥- មុទុតលុនហត្ថបាទោ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទ ដ៏ទន់ល្មើយ ។

៦- ជាលហត្ថបាទោ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ ដោយក្រឡា ដូចជាសំណាញ់ ។

៧- ឧស្សង្ខបាទោ មានព្រះបាទដូចជាអណ្តែតឡើងខាងលើ ។

៨· ឯណិជង្ឃោ មានព្រះជង្ឃាគឺស្មងរៀវមូលក្រសូលស្រដៀង ដងស្មងសត្វក្រាយ ។

៩- ឋិតកោ ច អនោនមន្តោ កាលបើទ្រង់ឈរ មិនបាច់ ឱនព្រះអង្គចុះ អាចស្ទាបអង្អែលព្រះជាណុ គឺជង្គង់ដោយផ្ទៃព្រះហស្ត ទាំងពីរបាន ។

១០- កោសោហិតវត្ថគុយ្ហោ មានព្រះអង្គាវយវៈដែលត្រូវ លាក់បាំងដោយសំពត់បិតនៅក្នុងស្រោម ។

១១- សុវណ្ណវណ្ណោ មានស្បែកសម្បុរថ្លៃ (លឿងភ្លឺអន្ទង់) ដូចជាសម្បុរនៃមាស ។

១២- សុខុមច្ឆវី មានព្រះឆវីគឺសម្បុរថ្លៃ ល្អិតផូរផង់លើសស្រិល រអិលធូលីធ្លាក់មកមិនជាប់ព្រះកាយ ។

១៣- ឯកេកលោមោ មានព្រះលោមាតែ១សរសៃ គឺក្នុង

រណ្ដៅរោម ១ មានរោម ១ ។

១៤ ឧទ្ធគ្គលោមោ មានព្រះលោមាមានចុង ងើរឡើងលើព្រះលោមាដែលដុះឡើងហើយ មានចុងឡើងលើជាទក្ខិណាវដ្ដ វិលវង់ព័ទ្ធពេនទៅខាងស្ដាំ មានសម្បុរខៀវ ដូចជាសម្បុរនៃផ្កាអញ្ចន ក្ដួចមូលដូចជាកុណ្ឌល ។

១៥- ព្រហ្មុជុគត្តោ មានព្រះកាយត្រង់ ដូចជាកាយនៃព្រហ្ម ។

១៦- សត្តុស្សទោ មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញបរិបូណ៌(១) ។

១៧- សីហបុព្វឌ្ឍកាយោ (២) មានព្រះកាយពាក់កណ្ដាលខាងលើដូចជាកាយនៃរាជសីហ៍ ។

១៨- បិតន្តរំសោ(៣) មានព្រះបិដ្ឋិ គឺខ្នង ដ៏ពេញបរិបូណ៌(៤) ។

១៩- និគ្រោធបរិមណ្ឌលោ មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ កាយរបស់មហាបុរសប្រវែងណា ព្យាមរបស់មហាបុរសក៏ប្រវែងនោះដែរ គឺមានកាយនិងព្យាមស្មើគ្នា ។

២០- សមវដ្ដក្ខន្ធោ មានព្រះសូរងមូលសម ។

---

១ ព្រះមំសៈ ៧ អន្លើនោះគឺ ត្រង់ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទទាំងពីរ ចង្កួយស្មាទាំងពីរ និងព្រះសូរង ។ ២ សីហបុព្វឌ្ឍកាយោដូច្នេះក៏មាន ។ ៣ ចិតន្តរំសោដូច្នេះក៏មាន ។ ៤ អដ្ឋកថា ថាសាច់ជាចន្លោះនៃស្មាបប្រជៀវទាំងពីរ ។

២១– រសគ្គសគ្គី មានព្រះប្រសាទ គឺសរសៃល្អិតធ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ ។

២២– សីហហនុ មានព្រះហនុកា (ចង្កា) ដូចជាចង្កានៃរាជសីហ៍។

២៣ ចត្តាឡីសទន្តោ មានព្រះទន្ត ៤០ គត់ ។

២៤– សមទន្តោ មានព្រះទន្តរាបស្មើ ។

២៥– អវិវរទន្តោ មានព្រះទន្តជិតស្និទ្ធ ។

២៦– សុសុក្កទាឋោ មានព្រះទាឋា គឺចង្កូម ( ចំនួន៤ )សស្អាត។

២៧– បហូតជិវ្ហោ មានព្រះជិវ្ហា ដ៏ធំវែង ។

២៨. ព្រហ្មស្សរោ ករវិកភាណី មានព្រះសូរស័ព្ទដូចជាសំឡេងនៃព្រហ្ម កាលបើបញ្ចេញវាចា លាន់ឮពីរោះ ដូចជាសំឡេងនៃបក្សីករវិក ។

២៩– អភិនីលនេត្តោ មានព្រះនេត្រខៀវស្រស់ ។

៣០– គោបខុមោ មានដួងព្រះនេត្រដូចជាភ្នែកនៃ (កូន) គោ ។

៣១– ឧណ្ណា ភមុកន្តរេ ជាតា មានព្រះឧណ្ណាលោមគឺរោមប្រជុំចិញ្ចើម ដុះត្រង់ចន្លោះនៃព្រះភមុកា ( ចិញ្ចើម ) មានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី ។

៣២– ឧណ្ហីសសីសោ មានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយ

ក្បាំងមកុដស្រេចស្រាប់ ។

មហាបុរិសលក្ខណៈទាំង ៣២ ប្រការនេះ ក្នុងលក្ខណសូត្រគឺជាក្ខ ព្រះពុទ្ធដីកា ហូរចេញពីព្រះឱស្ឋទិព្វថ្លៃ នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ទេសនា ប្រោសប្រាប់ភិក្ខុសង្ឃផងទាំងឡាយ នៅនាវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថីនោះឯងហោង ។

## បរោបុរិសលក្ខណៈ ៣២ ប្រការចប់

## អាទិសក្តេពគាថា

ពុ ធ សំ មង្គលំ លោកេ ទុក្ខនាសករំ ទរំ

ពុ ធ សំ សរណំ គច្ឆ សុខកាមោ សចេ តុវំ (១) ។

វែវគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រសើរខ្ពង់ខ្ពស់ មង្គលក្នុងលោក អាចជួយកំចាត់ វិបត្តិទុក្ខសោក ឲ្យសត្វក្នុងលោកស្រាកស្រាន្តទុក្ខា បើអ្នកចង់បាន សុខសាន្តយ៉ាងណា ចូរអ្នកស្រេក យកវែវទាំងបី គោលគឺព្រះពុទ្ធ ព្រះធម៌-សង្ឃថ្លៃ ជាទីអាស្រ័យ ពឹងពុំខាក់ចុះ ។

## សំណូមពរសុខសាន្ត

សូមសិរី សួស្តី ជ័យជោគសុខា មង្គលមហា វឌ្ឍនា ឆាប់ហើយ

---

១ បាឡីគាថានេះប្រែផ្តុំឈ្មោះគឺ ពុ-ព្រះពុទ្ធ ធ-ព្រះធម៌ សំ-ព្រះសង្ឃ, (វជិរសារ) ។

*ដល់ទេមក កម្ពុជា កាន់ពុទ្ធសាសន៍ កុំក្រឡាស់ ប្រែក្រឡាប់ ធ្លាក់ទៀយហោន ៗ*

អាទិសង្កេតគាថា និងសំណូមពរសុខសាន្តចប់

បទនមស្ការ ចប់ដោយសង្ខេប

ភណ្ឌទី ១ ចប់

ភណ្ឌទី២

ធាតុកម្មដ្ឋាន អារក្ខកម្មដ្ឋាន

អភិណ្ហប្បច្ចវេក្ខណកធម៌

អាយតនៈ ១២

នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ ព្រះមានព្រះភាគ

អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## ធាតុកម្មដ្ឋាន

### មេរៀនសង្ខេបងាយចន្ទេញ

### ភាប់ចាំ

ធាតុកម្មដ្ឋាន គឺកម្មដ្ឋានដែលព្រះយោគី(១) គប្បីកំណត់ពិចារណា ធ្វើទុកក្នុងចិត្ត នូវកាយតាំងមូលនេះឯង ឲ្យឃើញច្បាស់ថា គ្រាន់តែជាធាតុ ៤ ប៉ុណ្ណោះ មិនមែនជាសត្វ មិនមែនជាជីវិត ឥតមានខ្លឹមសារ ជារបស់ពុកផុយ សោះសូន្យទៅជាធម្មតា ហៅថា ធាតុកម្មដ្ឋាន ឬ ហៅថា ចតុធាតុវវដ្ឋានកម្មដ្ឋាន ។

### ធាតុ ៤

រីឯធាតុ ៤ នោះ មានកំណត់យ៉ាងនេះ គឺ

១ បឋវីធាតុ ធាតុដី;

---

១អ្នកមានព្យាយាមខាងការភាវនា-ការស្ញឹងស្មាធ៌ ឬ អ្នកចម្រើនកម្មដ្ឋាន ។

២ អាបោធាតុ ធាតុទឹក;

៣-តេជោធាតុ ធាតុភ្លើង;

៤ វាយោធាតុ ធាតុខ្យល់ ។

## លក្ខណៈនិងអាការ នៃធាតុទាំង៤

### បឋវីធាតុ

ធាតុណាមានលក្ខណៈកក ខះ រឹងគ្រោតគ្រាត ធាតុនោះតាក់ជា ធាតុដី ហៅថា បឋវីធាតុ ។

បឋវីធាតុនោះ ខាងក្នុងកាយ គឺដែលកើតក្នុងខ្លួន អាស្រ័យខ្លួនខ្លួន មានវិញ្ញាណចូលទៅអាស្រ័យនៅ មានអាការៈ ២០ យ៉ាងគឺ

១-កេសា សក់ទាំងឡាយ;

២-លោមា រោមទាំងឡាយ;

៣-នខា ក្រចកទាំងឡាយ;

៤-ទន្តា ធ្មេញទាំងឡាយ;

៥-តចោ ស្បែក;

៦-មំសំ សាច់;

៧-ន្ហារូ សរសៃទាំងឡាយ;

៨-អដ្ឋិ ឆ្អឹងទាំងឡាយ;

៩-អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង;

១០-វក្កំ តាច;

១១-ហទយំ បេះដូង;

១២-យកនំ ថ្លើម;

១៣-កិលោមកំ ភវ;

១៤-បិហកំ សន្ទះខ្យល់;

១៥-បប្ផាសំ សួត;

១៦-អន្តំ ពោះវៀនធំ;

១៧-អន្តគុណំ ពោះវៀនតូច;

១៨-ឧទរិយំ អាហារថ្មី

១៩-ករីសំ អាហារចាស់;

២០-មត្ថលុង្គំ ខួរក្នុងក្បាល ។

អាការៈទាំង ២០ នេះ ជាបឋវីធាតុ គឺធាតុដីក្នុងកាយ

## អាបោធាតុ

ធាតុណាមានលក្ខណៈ រាវ ហូរ ជ្រួតជ្រាប សើមខ្លួនៅ ធាតុនោះចាត់ជាធាតុទឹក ហៅថា អាបោធាតុ ។

អាបោធាតុនោះ មានក្នុងកាយ គឺដែលកើតក្នុងខ្លួន អាស្រ័យនូវ

ក្នុងខ្លួន មានវិញ្ញាណចូលទៅអាស្រ័យនៅ មានអាការៈ ១២ យ៉ាងគឺ

១-បិត្តំ ប្រមាត់;

២-សេម្ហំ ស្លេស្ម;

៣ បុព្វោ ខ្ទុះ;

៤ លោហិតំ ឈាម;

៥-សេទោ ញើស;

៦ មេទោ ខ្លាញ់ខាប់;

៧-អស្សុ ទឹកភ្នែក;

៨-វសា ខ្លាញ់រាវ;

៩-ខេឡោ ទឹកមាត់;

១០ សិង្ឃាណិកា ទឹកសម្បោរ;

១១- លសិកា ទឹករអិល;

១២-មុត្តំ ទឹកមូត្រ ។

អាការៈទាំង ១២ នេះ ជាអាបោធាតុ គឺធាតុទឹក ក្នុងកាយ ។

## តេជោធាតុ

ធាតុណា មានលក្ខណៈចំហាយក្តៅ ធាតុនោះចាត់ជាធាតុភ្លើង ហៅថា តេជោធាតុ ។

តេជោធាតុនោះ ខាងក្នុងកាយ គឺដែលកើតក្នុងខ្លួន អាស្រ័យខ្លួន មានវិញ្ញាណចូលទៅអាស្រ័យនៅ មានអាការៈ ៤ យ៉ាងគឺ(១)

១– សន្តប្បតិ ភ្លើងដែលញុំាងកាយឲ្យក្តៅស្មើស្រួល ;

២– ជីរិយតិ ភ្លើងដែលញុំាងកាយឲ្យចាស់គ្រាំគ្រា ;

៣– បរិឌយ្ហតិ ភ្លើងដែលញុំាងកាយឲ្យក្តៅពេលពលអន្ទះអន្ទែង;

៤– សម្មា បរិណាមំ គច្ឆតិ ភ្លើងដែលញុំាងអាហារឲ្យរលួយ ឬឲ្យប្រែប្រាយទៅដោយល្អ ។

អាការៈទាំង ៤ នេះ ជាតេជោធាតុ គឺធាតុភ្លើងក្នុងកាយ ។

## វាយោធាតុ

ធាតុណាមានលក្ខណៈ បក់ផាត់ហើយៗ ធាតុនោះចាត់ជាធាតុខ្យល់ ហៅថា វាយោធាតុ ។

វាយោធាតុនោះ ខាងក្នុងកាយ គឺដែលកើតក្នុងខ្លួន អាស្រ័យខ្លួន មានវិញ្ញាណចូលទៅអាស្រ័យនៅ មានអាការៈ ៦ យ៉ាងគឺ

១– ឧទ្ធង្គមា វាតា ខ្យល់ដែលបក់ឡើងទៅខាងលើ;

២– អធោគមា វាតា ខ្យល់ដែលបក់ចុះទៅខាងក្រោម

---

១ អាការៈ៤យ៉ាងនេះ ច្បាប់ខ្លះលោករៀបរៀងថា ១- សន្តប្បត្តិ , ២ ជិរណត្តិ ៣- បរិទយ្ហត្តិ, ៤- បរិណាមត្តិ ដូច្នេះក៏មាន ។

៣–កុច្ឆិសយា វាតា ខ្យល់ដែលបក់នៅខាងក្រៅពោះវៀន;

៤–កោដ្ឋាសយា វាតា ខ្យល់ដែលបក់នៅខាងក្នុងពោះវៀន;

៥–អង្គមង្គានុសារិនោ វាតា ខ្យល់ដែលបក់ផ្សាយទៅសព្វសព៌ាង្គកាយ;

៦–អស្សាសបស្សាសា ខ្យល់ដង្ហើមចេញចូល (១) ។ អាការៈទាំង ៦ នេះ ជាវាយោធាតុ គឺធាតុខ្យល់ក្នុងកាយ ។ ប្រមូលអាការៈនៃធាតុទាំង ៤ នោះដូច្នេះគឺ ធាតុដីមានអាការៈ ២០, ធាតុទឹកមានអាការៈ ១២, ធាតុភ្លើងមានអាការៈ ៤, ធាតុខ្យល់មានអាការៈ ៦, បញ្ចូលគ្នាទាំងអស់ទៅ ត្រូវជាអាការៈ ៤២ ប្រការ ។

ព្រះយោគីគប្បីកំណត់ពិចារណា ធ្វើទុកក្នុងចិត្ត នូវកងកាយទាំងមូលនេះឯង ឲ្យឃើញច្បាស់ថា គ្រាន់តែជាធាតុ ៤ គឺ ដី ទឹក ភ្លើង

---

១— ក្នុងអភិធម្មបិដក ធាតុវិភង្គ សុត្តន្តភាជនីយ បានខ្យល់ ៣ ទៀតគឺ សត្ថកវាតា ខ្យល់ដូចជាសស្ត្រា ១, ខុរកវាតា ខ្យល់ដូចជាកាំបិតកោរ ១, ឧប្បលកវាតា ខ្យល់អាចពន្ទុះនូវហឫទ័យ ១, ខ្យល់ ៣ នេះ លោករៀបរៀងមុនខ្យល់ដង្ហើមចេញចូល ។

ខ្យល់ ប្រកបដោយអាការៈ ២២ ប្រការប៉ុណ្ណោះ មិនមែនជាសត្វ មិនមែនជាជីវិត សុទ្ធតែមិនទៀង ជាទុក្ខ ជាអនត្តា ជារបស់ពុកផុយ សោះសូន្យទៅជាធម្មតា ឥតមានខ្លឹមសារសោះឡើយហោង ។

## ធាតុកម្មដ្ឋានសង្ខេប
## ចប់

ក្នុងសមាធិនិទ្ទេស លោកសំដែងប្រាប់ថា ព្រះយោគីអ្នកមានព្យាយាមចម្រើនធាតុកម្មដ្ឋាននេះ នឹងបានសម្រេចផល ដល់ត្រឹមឧបចារសមាធិដោយពិត ។

## ធាតុត្ថាធិប្បាយ

ក្នុងលំដាប់នេះ ខ្ញុំនឹងអធិប្បាយអំពីធាតុ ៤ ក៏ធាតុទាំង ៤ នោះ មានពិធីសម្រាប់ពិចារណាច្រើនយ៉ាង ហើយលោកអធិប្បាយសេចក្ដីល្អិតល្អន់ ជ្រាលជ្រៅក្រៃលែង ក្នុងទីនេះ សូមអធិប្បាយតែល្មមសមគួរ ។ ទុកជាគ្រឿងប្រដាប់ សម្រាប់ពិចារណា នៃសាធុសប្បុរស ទាំងឡាយតទៅ ។

ពាក្យថា ធាតុ ប្រែថា ‘‘ធម្មជាតិទ្រទ្រង់ខ្លួនឯង,, បានសេចក្ដីថា ធម្មជាតិដែលទ្រទ្រង់ទុក នូវលក្ខណៈរបស់ខ្លួនដោយខ្លួនឯង តាមសមគួរដល់ខណៈរបស់ខ្លួន គឺមិនប្រព្រឹត្តទៅហួសពីខណៈ ពីស្របក់ ឬ ពីយុគរបស់ខ្លួនទេ តែងតែប្រែប្រួលវិនាសបាត់បង់ទៅតាមកំណត់កាលរបស់ខ្លួនជាធម្មតា ហៅថា ធាតុ ។

## លក្ខណៈនៃធាតុទាំង ៤ ផ្សេងៗគ្នា

ឯលក្ខណៈរបស់ធាតុទាំង ៤ នោះ បានសម្ដែងទុកក្នុងមេរៀនខាងដើមរួចម្ដងមកហើយ តែសូមថ្លែងបញ្ជាក់ថែមម្ដងទៀត ក្នុងទំព័រអធិប្បាយនេះថា បឋវីធាតុ មានសភាពដែលកក ខះ រឹង គ្រោតគ្រាត ដើបដុប ជាលក្ខណៈ; អាបោធាតុ មានសភាពដែល ទន់ ជ្រាយ ករ

ហូរ ជ្រួតជ្រាប សើមខ្លួនទៅជាលក្ខណៈ; តេជោធាតុ មានសភាពផល ចំហាយ ក្តៅ អប់ កម្តៅ កំសួលក្តៅជាលក្ខណៈ; វាយោធាតុ មានសភាពផែល បក់ ផាត់ ផ្សព្វផ្សាយ រហើយៗជាលក្ខណៈ ។

## ភាពដែលមិនបែកចាកគ្នានៃធាតុទាំង ៤

ធាតុទាំង៤នេះ គ្រាន់តែមានលក្ខណៈផ្សេងគ្នាដូច្នោះមែន ប៉ុន្តែជាធម្មជាតិមិនដែលបែកខ្ញែកចេញពីគ្នាសោះឡើយ កាលដែលកើតឡើង រមែងកើតឡើងជាមួយគ្នា កាលដែលប្រព្រឹត្តទៅក៏រមែងប្រព្រឹត្តទៅជាមួយគ្នាដែរ ហើយជាបច្ច័យជាទីពឹងផ្អែក ជួយទំនុកបំរុងគ្នាទៅវិញទៅមក ទើបនៅរួមជាមួយគ្នាបាន ។

## ធាតុភាពនៃឧបាទិន្នករូបនិងអនុបាទិន្នករូប

កាលបើធាតុទាំង៤ បានប្រជុំព្រមមូលគ្នាហើយ ក៏មានធាតុភាពនៃឧបាទិន្នករូប និងអនុបាទិន្នករូប កើតប្រាកដជាក់ស្តែងឡើង ។

រូបណា ដែលមានវិញ្ញាណចូលទៅអាស្រ័យនៅ រូបនោះហៅថា ឧបាទិន្នករូប (១); រូបណា ដែលឥតមានវិញ្ញាណចូលទៅអាស្រ័យនៅទេ រូបនោះហៅថា អនុបាទិន្នករូប(២), ឧបាទិន្នករូបទាំងឡាយក្តី

---

១ ឧបាទិន្នករូប បានដល់រូបពួកមនុស្ស ពួកទេវតា ពួកសត្វតិរច្ឆានជាដើម ។

២ អនុបាទិន្នករូប បានដល់រូបភ្នំ ផែនដី ដែក ថ្ម ក្រួស ដើមឈើស្មៅ ជាដើម ។

ដូច្នេះថា រាងកាយទាំងមូលនេះ ជាឧបាទិន្ន-រូប គឺរូបដែលមានវិញ្ញាណចូលមកអាស្រ័យនៅជាមួយផង ឯរូបគឺរាងកាយនេះ គ្រាន់តែជាទីប្រជុំព្រមនៃធាតុទាំង ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ប្រកបដោយអាការៈ ៤២ ប្រការ ជាទព្វសម្ភារៈគឺជាគ្រឿងប្រុង សម្រាប់បញ្ចេញកងហេងក្រោយ ឲ្យប្រាកដជាក់ស្តែងឡើងប៉ុណ្ណោះ ឥតមានដឹងការណ៍អ្វីគិតគូរសោះទេ ប្រៀបដូចរាងផ្ទះ ឬ រាងខ្ទមដែលឥតដឹងការណ៍អ្វីសោះនោះឯង ។

វិញ្ញាណដែលអាស្រ័យនៅក្នុងរាងកាយ ជាធម្មជាតសម្រាប់ទទួលដឹងការណ៍អ្វីៗទាំងពួង ហើយបង្គាប់បញ្ជាប្រើប្រាស់ នូវរាងកាយឲ្យធ្វើការងារផ្សេងៗ ឲ្យស៊ី ផឹក ទំពា ហុត ស្រូប នូវអាហារចំណី ឲ្យដើរ ឈរ អង្គុយ ដេក និយាយស្តីជាដើម ប្រៀបដូចជាម្ចាស់ផ្ទះដែលជាអ្នកគ្រប់គ្រងថែរក្សាផ្ទះនោះដែរ ។

គ្រោងកាយនេះ ជាទីប្រជុំចុះព្រមនៃធាតុទាំង ៤ ដូចពោលមកហើយ មានតែសំណុំសាច់ បាច់ឆ្អឹង និងសរសៃតូចធំសម្រាប់ទាក់ចងភ្ជាប់គ្នាជាដើមប៉ុណ្ណោះ មិនឃើញមានរបស់ណាមួយដែលមានខ្លឹម-សារសំខាន់ ល្មមនឹងឋិតនៅឲ្យបានទៀងទាត់នោះទេ ជារបស់មិនទៀងតែងតែប្រែប្រួលវិនាសទៅជាធម្មតា ដូចគ្នានឹងដុំនៃពពុះទឹកនោះមែនពិត ។

ឯធាតុកម្មដ្ឋាន គឺកម្មដ្ឋានដែលត្រូវកំណត់ពិចារណា នូវរាងកាយ

ឲ្យឃើញថាគ្រាន់តែជាធាតុនោះ គឺដើម្បីបន្ទាបចិត្ត ឲ្យនឿយណាយ ធុញទ្រាន់ ឬឲ្យគ្រាកចេញអំពីការអឹមអររីករាយចំពោះរាងកាយ ដែលជាទីប្រជុំនៃធាតុទាំង ៤ ដើម្បីឲ្យប្រែខ្លួនចាកទុក្ខគ្រប់យ៉ាង ដូចព្រះពុទ្ធទ្រង់ដែលសម្តែងមកហើយខាងដើមនោះឯង ។

## ធាតុត្ថាធិប្បាយ
## ចប់ដោយសង្ខេប

អារក្ខកម្មដ្ឋាន

ពុទ្ធានុស្សតិ មេត្តា ច

អសុភំ មរណស្សតិ

ឥច្ចេតា ចតុរារក្ខា

ភាវេតព្វា បុនប្បុនំ ។

អារក្ខកម្មដ្ឋាន ៤ យ៉ាងនេះគឺ ពុទ្ធានុស្សតិ១ មេត្តា១ អសុភៈ១ មរណស្សតិ១ គួរសាធុជនចម្រើនរឿយៗថា:

វន្ទាមិ ពុទ្ធំ គុណសាគរន្តំ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសម្ពុទ្ធ ទ្រង់មានព្រះគុណដ៏ធំធេង ដូចសាគរ,

សត្តា សទា ហោន្តុ សុខី អវេរា សូមសត្វទាំង-ឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នា សព្វកាល,

កាយោ ជិគុច្ឆោ សកលោ ទុគ្គន្ធោ រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់,

គច្ឆន្តិ សព្វេ មរណំ តថាហំ សព្វសត្វទាំងអស់រមែងដល់នូវសេចក្ដីស្លាប់ ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ។

វន្ទាមិ ធម្មំ សុគតេន វុត្តំ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះធម៌

ដែលព្រះសុគតទ្រង់ត្រាស់សម្តែងហើយ,

សត្តា សន្តា ហោន្តុ សុខី អវេរា សូមសត្វទាំងឡាយ មានតែសេចក្តីសុខ មិនមានពៀរនឹងគ្នា សព្វកាល,

កាយោ ឋិយញ្ញោ សគណោ ទុគន្ធោ រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់,

គច្ឆន្តិ សព្វេ មរណំ តថាហំ សព្វសត្វទាំងអស់រមែងដល់នូវសេចក្តីស្លាប់ ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ។

វន្ទាមិ សង្ឃំ មុនិរាជបុត្តំ ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសង្ឃ ដែលជាបុត្រនៃព្រះសម្ពុទ្ធ ជាស្តេចនៃអ្នកប្រាជ្ញ,

សត្តា សន្តា ហោន្តុ សុខី អវេរា សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នា សព្វកាល,

កាយោ ឋិយញ្ញោ សគណោ ទុគន្ធោ រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់,

គច្ឆន្តិ សព្វេ មរណំ តថាហំ សព្វសត្វទាំងអស់រមែងដល់នូវសេចក្តីស្លាប់ ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ។

អារក្ខកម្មដ្ឋាន ចប់

## អភិណ្ហប្បច្ចវេក្ខណធម៌

អភិណ្ហប្បច្ចវេក្ខណធម្មោ *ធម៌គួរពិចារណារឿយៗមាន ៥ យ៉ាងគឺ*

១ ជរាធម្មោម្ហិ ជរំ អនតីតោ *អាត្មាអញមានការចាស់ជរាជាធម្មតា នឹងកន្លងការចាស់ជរាទៅពុំបានឡើយ,*

២-ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ *អាត្មាអញមានការឈឺចាប់ជាធម្មតា នឹងកន្លងការឈឺចាប់ទៅពុំបានឡើយ,*

៣ មរណធម្មោម្ហិ មរណំ អនតីតោ *អាត្មាអញមានសេចក្ដីស្លាប់ជាធម្មតា នឹងកន្លងសេចក្ដីស្លាប់ទៅពុំបានឡើយ,*

៤ សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ *អាត្មាអញគង់តែព្រាត់ប្រាសចាកសព្វនិងសត្វជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខាន,*

៥ កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ *អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឲ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់អាស្រ័យ, អាត្មាអញនឹងធ្វើនូវកម្មណា*

ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ ពុំខាន ។

## អភិណ្ហប្បច្ចវេក្ខណធម៌ ចប់

## អាយតនកៈ ១២(១)

*(អាយតនៈ ១២ មានសេចក្ដីមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួលជាធម្មតា យ៉ាងនេះគឺ)*

១ ចក្ខុំ អនិច្ចំ ទុក្ខំ អនត្តា វិបរិណាមធម្មំ

*ភ្នែកមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា)*

២-រូបា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

*រូបទាំងឡាយមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា),*

៣ សោតំ អនិច្ចំ ទុក្ខំ អនត្តា វិបរិណាមធម្មំ

*ត្រចៀកមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា),*

៤ សទ្ទា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

*សំឡេងទាំងឡាយមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា),*

---

១- អភិធម្មបិដក -អាយតនវិភង្គ, ខ្ញុំសរសេរថែមពាក្យខ្លះតាមដំណើរសេចក្ដី ដើម្បីសម្រួលក្នុងការសូត្រស្វាធ្យាយ ពាក្យក្នុងវង់ក្រចក (...) ដូច្នេះជាពាក្យផ្សំថែម ។

៥-ឃានំ អនិច្ចំ ទុក្ខំ អនត្តា វិបរិណាមធម្មំ

ច្រមុះមិនទៀត ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា)

៦-គន្ធា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

ក្លិនទាំងឡាយ មិនទៀត ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា),

៧-ជិវ្ហា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

អណ្តាត មិនទៀត ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា),

៨ រសា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

រសទាំងឡាយ មិនទៀត ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា)

៩-កាយោ អនិច្ចោ ទុក្ខោ អនត្តា វិបរិណាមធម្មោ

កាយ មិនទៀត ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា),

១០ ផោដ្ឋព្វា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

សម្ផស្សទាំងឡាយ មិនទៀត ជាទុក្ខ ជារបស់សោះសូន្យ មានសភាព

ប្រែប្រួល ( ជាធម្មតា ) ,

១១-មនោ អនិច្ចោ ទុក្ខោ អនត្តា វិបរិណាមធម្មោ

មនោ មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល (ជាធម្មតា) .

១២-ធម្មា អនិច្ចា ទុក្ខា អនត្តា វិបរិណាមធម្មា

ធម៌ទាំងឡាយ មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល ( ជាធម្មតា ) ,

( អាយតនៈ ១២ មានសេចក្ដីមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួលជាធម្មតាយ៉ាងហ្នឹងឯង ) ។

អាយតនៈ ១២ ចប់

ភណ្ឌទី ២ ចប់

ភណ្ឌទី ៣

បច្ចរិសូត្រ

អាទិត្តសូត្រ

វនរោបសូត្រ

ចូឡវេទល្លសូត្រ

ព្រះសូត្រទាំងនេះ ខាងបាលី

ខ្ញុំសរសេរស្រង់ចំពោះតែគាថា

ក្រៅអំពីគាថា ពុំបានសរសេរទេ ។

នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ ចំពោះព្រះមានព្រះភាគ

អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

## មច្ឆរិសូត្រ(១)

(៨៧)(២) សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង កាលរាត្រីបឋមយាមកន្លងហើយ មានពួកសតុល្លប្បកាយិកាទេវតា (៣) ជាច្រើន មានរស្មីរុងរឿង ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

(៨៨) លុះទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរហើយ ក៏ពោលគាថានេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគថា

---

១ សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បឋមភាគ លេខ២៩ ក្នុងទេវតាសំយុត្ត សតុល្លប្បយិកាវគ្គ ។ ២ លេខនេះគឺជាលេខរៀងបព្វៈក្នុងព្រះត្រៃបិដក ។ ៣ សតៈ ប្រែថាសប្បុរស ឧល្លប្បៈ ប្រែថាពោល កាយិកា ប្រែថាពួក គឺទេវតាពួកនេះ កាលនៅជាពាណិជ លិចសំពៅក្នុងសមុទ្រ បានពោលសមាទានធម៌របស់សប្បុរស និច្ចសីល អំពីបុរសម្នាក់ ហើយបានទៅកើតក្នុងឋានសួគ៌ បានជាឈ្មោះថា សតុល្លប្បកាយិកា ។ អដ្ឋកថា ។

មច្ឆេរា ច បមាទា ច

ឯវំ ទានំ ន ទីយតិ

បុញ្ញមាកង្ខមានេន

ទេយ្យំ ហោតិ វិជានតាតិ ។

ព្រោះតែសេចក្តីកំណាញ់និងសេចក្តីប្រមាទ

បានជាទានដែលឲ្យទានមិនកើតយ៉ាងនេះ

បាន កាលបើបុគ្គលដឹងច្បាស់ ជាអ្នក

ប្រាថ្នានូវបុណ្យ គួរតែឲ្យ ៗ

(៣៩) លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថា

ទាំងឡាយនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ថា

យស្សេវ ភីតោ ន ទទាតិ មច្ឆរី

តទេវ អទទតោ ភយំ

ជិឃច្ឆា ច បិបាសា ច

យស្ស ភាយតិ មច្ឆរី

តមេវ ពាលំ ផុសតិ

អស្មឹ លោកេ បរម្ហិ ច

តស្មា វិនេយ្យ មច្ឆេរំ

ឧជ្ឈា ឆានំ មលាតិគ្គ
បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

មនុស្សកំណាញ់ ភ័យចំពោះហេតុណា ហើយមិនឲ្យទាន ហេតុនោះឯង ជាភ័យរបស់អ្នកមិនឲ្យ បុគ្គលកំណាញ់ ខ្លាចចំពោះហេតុណា ព្រោះសេចក្ដីឃ្លានទឹងស្រេក ហេតុនោះឯង តែងពាល់ត្រូវបុគ្គលពាលក្នុងលោកនេះ និងលោកខាងមុខ ព្រោះហេតុនោះ សាធុជន គួរតែកំចាត់បង់នូវសេចក្ដីកំណាញ់ ជាអ្នកគ្របសង្កត់នូវមន្ទិល ហើយត្រូវឲ្យទាន (ព្រោះថា) បុណ្យទាំងឡាយ ជាទីពឹង របស់ពួកសត្វក្នុងលោកខាងមុខ ។

(៩០) លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថាទាំងឡាយនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ថា

តេ មតេសុ ន មិយ្យន្តិ
អទ្ធានំវ សហាវជំ
អប្បស្មិំ យេ បវេច្ឆន្តិ

ឯសធម្មោ សនន្តនោ

អប្បស្មេកេ បវេច្ឆន្តិ

ពហុនេកេ ន ទិច្ឆរេ

អប្បស្មា ទក្ខិណា ទិន្នា

សហស្សេន សមំ មិតាតិ ។

ពួកជនណា កាលទ្រព្យមានតិច ក៏នៅតែឲ្យទានបាន ដូចជាអ្នកដើរផ្លូវឆ្ងាយ (ចែកស្បៀងដែលមានតិចតួច ដល់គ្នាបាន) កាលបើគេស្លាប់កល់គ្នា ជននោះឈ្មោះថាមិនស្លាប់ ធម៌នេះ ជាធម៌របស់បុកណាតាប្យ ជនពួកខ្លះ កាលទ្រព្យមានតិចក៏នៅតែឲ្យទានបាន ជនពួកខ្លះ ស្ដុកស្ដម្ភណ៍ទ្រព្យច្រើន ក៏ឲ្យទានមិនកើត ទក្ខិណាទាន ដែលគេថែមអំពីទ្រព្យតិចហើយឲ្យ រមែងមានផលស្មើគ្នានឹងទានរាប់ពាន់ ៗ

(៩១) (លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថាភាសិតឡាយនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគថា

ទុទ្ទទំ ទទមានានំ

ទុក្ករំ កម្មកុព្វតំ

អសន្តោ នានុកុព្វន្តិ

សតំ ធម្មោ ទុរន្វយោ

តស្មា សតញ្ច អសតញ្ច

នានា ហោតិ ឥតោ គតិ

អសន្តោ និរយំ យន្តិ

សន្តោ សគ្គបរាយនាតិ ។

កាលបើពួកសប្បុរស កំពុងឲ្យរបស់ដែលឲ្យបានដោយកម្រ កំពុងធ្វើអំពើដែលធ្វើបានដោយកម្រ ពួកអសប្បុរសធ្វើតាមមិនបាន (ព្រោះ) ធម៌របស់ពួកសប្បុរស គឺពួកអសប្បុរសប្រព្រឹត្តតាមបានដោយកម្រ ព្រោះហេតុនោះ គតិរបស់ពួកសប្បុរសនិងអសប្បុរស រមែងផ្សេងគ្នា អំពីលោកនេះទៅ គឺពួកអសប្បុរសទៅកាន់នរក ពួកសប្បុរស ទៅកាន់ឋានសួគ៌ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ការបើក

របស់អ្នកណាហ្នឹងជាសុភាសិត ។

(៩២) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ភាសិតរបស់អ្នកគ្រប់គ្នាជាសុភាសិត ដោយបរិយាយដែរហើយ តែអ្នកទាំងឡាយ ចូរស្ដាប់ពាក្យរបស់តថាគតវិញ ថា

ធម្មំ ចរេ យោបិ សមុញ្ជកំ ចរេ
ទារំ ច បោសំ ទទំ អប្បកស្មឹ
សតំ សហស្សានំ សហស្សយាគីនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

ជនណា ចិញ្ចឹមភរិយាផង កាលបើទ្រព្យមានតិច នៅតែឲ្យទានបានផង ប្រព្រឹត្តធម៌បានផង ប្រព្រឹត្តឡសេចក្ដីខ្វល់ខ្វាយ (ក្នុងការងារ) ផង ពួកជនដែលមានការបូជារាប់ពាន់ ដល់បុគ្គលមួយសែននាក់ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះបាន ។

(៩៣) លំដាប់នោះ ទេវតាមួយអង្គទៀត បានពោលគាថាចំពោះព្រះមានព្រះភាគ ថា

ធនេន យញ្ញោ វិបុលោ មហគ្គតោ
សមេន ទិន្នស្ស ន អគ្ឃមេតិ

ឯវំ សហស្សាន សហស្សយាគីនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

យញ្ញនុ៎ះ មានផលដ៏ទូលាយច្រើនដែរ នៅតែមិនដល់ ទានដែលបុគ្គលឲ្យហើយ ដោយធម៌ដ៏ស្មើ តើដោយ ហេតុដូចម្ដេច បុគ្គលមានការបូជាកប់ពាន់ ដល់ បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយ ចំណែករបស់បុគ្គលយ៉ាងនោះ តើដូចម្ដេច ។

(៩៤) លំដាប់នេះឯង ព្រះមានព្រះភាគ បានត្រាស់នឹងទេវតា នោះ ដោយគាថា ថា

នយន្តិ ហេកេ វិសមេ និវិដ្ឋា
ឆត្វា វធិត្វា· អថ សោចយិត្វា
សា ទក្ខិណា អស្សុមុខា សទណ្ឌា
សមេន ទិន្នស្ស ន អគ្ឃមេតិ
ឯវំ សហស្សាន សហស្សយាគីនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

បុគ្គលពួកមួយ បានឋិតនៅស៊ប់ក្នុងធម៌មិនស្មើ ហើយ បៀតបៀន សម្លាប់ ពុំពោះសោក ធ្វើបុគ្គលដទៃ ឲ្យ

សោកសៅ ទើបឲ្យតាំង ទុក្ខណាមាននោះ ឈ្មោះថា មានមុខទទឹកដោយទឹកភ្នែក ប្រកបដោយអាជ្ញា មិន ដល់នូវតម្លៃនមាន ដែលបុគ្គលឲ្យហើយដោយធមិ ដំស្មើរ បុគ្គលមានការបូជារាប់ពាន់ ដល់បុគ្គល មួយពាន់នាក់នោះ នៅតែមិនដល់មួយចំណិត របស់បុគ្គលយ៉ាងនោះ ដូច្នេះឯង ។

មច្ឆរិសូត្រ ចប់

## អាទិត្តសូត្រ(១)

(១៣៧) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ លំដាប់នោះឯង កាលដែលវេលាកក្រើបបឋមយាមកន្លងទៅហើយ ទេវតាមួយអង្គ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏អភិវាទព្រះមានព្រះ-ភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។

(១៣៨) លុះទេវតានោះឋិតនៅក្នុងទីសមគួរហើយ បានពោលនូវគាថាទាំងនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ថា

អាទិត្តស្មឹ អគារស្មឹ
យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ
នោ ច យំ តត្ថ ឌយ្ហតិ
ឯវមាទិត្តកោ លោកោ
ជរាយ មរណេន ច
នីហរេថេវ ទានេន

---

១ អាទិត្តវគ្គ ។

ទិន្នំ ហោតិ សុនិព្ភតំ

ទិន្នំ សុខផលំ ហោតិ

នាទិន្នំ ហោតិ តំ តថា

ចោរា ហរន្តិ រាជានោ

អគ្គិ ឌយ្ហតិ នស្សតិ

អថ អន្តេន ជហតិ

សរីរំ សបរិគ្គហំ

ឯតទញ្ញាយ មេធាវី

ភុញ្ជេថ ច ទទេថ ច

ទត្វា ច ភុត្វា ច យថានុភាវំ

អនិន្ទិតោ សគ្គមុបេតិ ឋានន្តិ ។

បុគ្គលដកញ្ចូននូវភាជន៍ណា អំពីផ្ទះដែលភ្លើងកំពុង
ឆេះ ពុំនោះសោត ភ្លើងមិនទាន់ឆេះខ្ទេចវត្ថុណាក្នុង
ផ្ទះនោះ ភាជន៍នឹងវត្ថុនោះជាប្រយោជន៍នៃបុគ្គល
នោះឯង សត្វលោកដែលជរានិងមរណៈឆេះហើយ
នេះ ត្រូវតែនាំទ្រព្យចេញ ដោយទានកុំខាន ទាន
ដែលបុគ្គលឲ្យហើយ ឈ្មោះថានាំចេញដោយ

ល្អ វត្ថុដែលបុគ្គលឲ្យហើយ ជាវត្ថុមានសុខជាផល
វត្ថុដែលបុគ្គលមិនឲ្យហើយ ជាវត្ថុមិនមានសុខជាផល
ទេ ពួកចោរតែងនាំទៅ ពួកពលការតែងរឹបយក
ភ្លើងតែងឆេះវិនាសទៅ ពុំនោះសោត វេលាស្លាប់
ទៅ ក៏រមែងលះបង់នូវសរីរៈនិងរបស់ដែលបុគ្គល
ជាប់ហួងហែង អ្នកប្រាជ្ញដឹងនូវសេចក្តីនេះហើយ
គប្បីបរិភោគផង ឲ្យទានផង បុគ្គលឲ្យទានទាំង
បរិភោគ ឲ្យសមគួរតាមសក្តិហើយ គេមិន
ដែលនិន្ទាទេ តែងបានទៅកើតក្នុងឋានសួគ៌ ។

រាជិត្តសូត្រ ចប់

## វនរោបសូត្រ (១)

(១៤៧) តេសំ ទិវា ច រត្តោ ច
សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា
តេ ជនា សគ្គគាមិនោតិ ។

*ទេវតាទូលថា បុណ្យរមែងចម្រើនដ៏ជាប់ ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនពួកណា ជនពួកណា ឈ្មោះជាតាំងនៅក្នុងធម៌ ឈ្មោះថាបរិបូណ៌ដោយសីល ពួកទៅកាន់ឋានសួគ៌បាន ។*

(១៤៨) អារាមរោបា វនរោបា
យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច
យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច
សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា

---

១ អាទិត្តវគ្គ ។

## គេ ជនា សគ្គគាមិនោតិ ។

ព្រះមានព្រះភាគត្រាស់ថា ជនណាដាំច្បារឈើមាន
ផ្កាផ្លែ ដាំច្បារឈើមានម្លប់ សាងស្ពាន សាងពេន
ឲ្យមានទឹក ទាំងជីកស្រះ ជនទាំងឡាយណា ឲ្យនូវ
ទីសម្នាក់អាស្រ័យ បុណ្យ រមែងចម្រើនមិនដាច់
ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនទាំងឡាយនោះ
ជនទាំងនោះ ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌
ឈ្មោះថាបរិបូណ៌ដោយសីល គួរទៅកាន់
ឋានសួគ៌ឋាន ។

### វនរោបសូត្រ ចប់

## ចូឡវេទល្លសូត្រ(១)

(១៤៥) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ឧបាសកឈ្មោះវិសាខៈ បានចូលទៅរកធម្មទិន្នាភិក្ខុនី លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំធម្មទិន្នាភិក្ខុនី ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។

## សក្កាយបញ្ហា(២)

(១៤៦) លុះវិសាខឧបាសក អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរធម្មទិន្នាភិក្ខុនីយ៉ាងនេះថា បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគតែងត្រាស់ថា សក្កាយៈ សក្កាយៈ បពិត្រព្រះនាងជាអម្ចាស់ ធម៌ដូចម្ដេចខ្លះ ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ។

ធម្មទិន្នាភិក្ខុនីតបថា ម្នាលអាវុសោវិសាខៈ ឧបាទានក្ខន្ធ ៥ ប្រការនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ឧបាទានក្ខន្ធ ៥

---

១ សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ ចូឡយមកវគ្គ ភតិយភាគ លេខ ២២ ។ ២ មាតិកាត្រង់ចន្លោះនេះ ក្នុងបិដកច្បាប់ដើមមិនមានទេ ខ្ញុំសរសេររៀបរៀងដាក់មក ដើម្បីឲ្យសេចក្ដីនៃបញ្ហាធម៌មួយៗ មានឃ្លាឃ្លាតចេញសេចក្ដីពីគ្នា បានច្បាស់លាស់ល្អ តទៅខាងមុខទៀតក៏ដូចគ្នាដែរ ។

នោះគឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបា-
ទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ម្នាលអាវុសោវិសាខៈ ឧបាទានក្ខន្ធ
ទាំង ៥ ប្រការនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា **សក្កាយៈ** ។

## សក្កាយសមុទយបញ្ហា

វិសាខឧបាសក ក៏ត្រេកអរនឹងភាសិតរបស់ធម្មទិន្នាភិក្ខុនី ថាពីរោះណាស់ព្រះនាងម្ចាស់ ហើយក៏បានសួរប្រស្នានឹងធម្មទិន្នាភិក្ខុនីតទៅទៀតថា បពិត្រព្រះនាងម្ចាស់ ព្រះមានព្រះភាគទ្រង់តែងត្រាស់ថា **ហេតុដែលនាំឱ្យកើតសក្កាយៈ ហេតុដែលនាំឱ្យកើតសក្កាយៈ** (សក្កាយសមុទ័យ) បពិត្រព្រះនាងម្ចាស់ ធម៌ដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា **ជាហេតុនាំឱ្យកើតសក្កាយៈ** ។

ធម្មទិន្នាភិក្ខុនីតបថា ម្នាលអាវុសោវិសាខៈ តណ្ហាដែលនាំឲ្យសត្វកើតក្នុងភពថ្មីទៀត ប្រកបដោយនន្ទិរាគ មានសេចក្តីត្រេកអរក្នុងភពនោះៗ តណ្ហានោះគឺ កាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ ម្នាលអាវុសោវិសាខៈ នេះឯងហើយដែលព្រះមានព្រះភាគត្រាស់ថា **ហេតុដែលនាំឱ្យកើតសក្កាយៈ** ។

## សក្កាយនិរោធបញ្ហា

វិ.(១) បពិត្រព្រះនាងម្ចាស់ ព្រះមានព្រះភាគត្រាស់ថា **អារ**

---

១ វិ. គឺវិសាខឧបាសកសួរថា

រំលត់សក្កាយៈ ការរំលត់សក្កាយៈ (សក្កាយនិរោធ) បពិត្រព្រះនាងជាម្ចាស់ ធម៌ដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងរំលត់សក្កាយៈ ។

ធ.(១) ម្នាលអាវុសោវិសាខៈ សេចក្តីនឿយណាយ និងការរំលត់ដោយមិនសល់ ការលះបង់ ការជម្រុះចោល ការរួចស្រឡះ ការលែងអាឡោះអាល័យ ចំពោះតណ្ហានោះឯង ម្នាលអាវុសោវិសាខៈ នេះឯងហើយដែលព្រះមានព្រះភាគត្រាស់ថា ការរំលត់សក្កាយៈ ។

## សក្កាយនិរោធគាមិនី បដិបទាបញ្ហា

វិ. បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ (សក្កាយនិរោធគាមិនីបដិបទា) បពិត្រព្រះនាងជាម្ចាស់ ធម្មជាតិដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគត្រាស់ថា បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ ។

ធ. ម្នាលអាវុសោវិសាខៈ មគ្គប្រកបដោយអង្គ៨ដ៏ប្រសើរនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា បដិបទាជាដំណើរទៅកាន់សេច-

---

១ ធ. គឺធម្មទិន្នាភិក្ខុនីតបថា

**ក្ដីរំលត់សក្កាយៈ** មគ្គដែលប្រកបដោយអង្គ ៨ នោះគឺ សេចក្ដីយល់ត្រូវ ១ ការត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្ដីព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតំកល់ចិត្តនឹងត្រូវ ១ ។

## ឧបាទានបញ្ហា

វិ. បពិត្រព្រះនាងជាម្ចាស់ ឧបាទាននោះ គឺឧបាទានក្ខន្ធទាំង ៥ នោះឯង ឬក៏ឧបាទានដោយឡែកអំពីឧបាទានក្ខន្ធទាំង ៥ (នោះ) ទេ ។

ធ. ម្នាលអាវុសោវិសាខៈ ឧបាទាននោះឯង មិនមែនជាឧបាទានក្ខន្ធទាំង ៥ នោះទេ ឯឧបាទាន (នោះ) សោត ក៏មិនមែនដោយឡែកអំពីឧបាទានក្ខន្ធទាំង ៥ ដែរ ម្នាលអាវុសោវិសាខៈ ឧបាទាននោះឯង មិនមែនជាឧបាទានក្ខន្ធទាំង ៥ នោះទេ តែឧបាទាននឹងញែកចេញអំពីឧបាទានក្ខន្ធមិនបានដែរ ម្នាលអាវុសោវិសាខៈ សេចក្ដីត្រេកត្រអាល (ឆន្ទរាគៈ) ក្នុងឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា ឧបាទាន ក្នុងឧបាទានក្ខន្ធនោះ ។

## សក្កាយទិដ្ឋិបញ្ហា

(១៤៧) វិ. បពិត្រព្រះនាងជាម្ចាស់ ចុះសក្កាយទិដ្ឋិដូចម្ដេច ។

ធ. ម្នាលអាវុសោវិសាខៈ បុថុជ្ជនក្នុងលោកនេះជា អ្នកមិនចេះដឹង

មិនបានជួបប្រទះនឹងពួកព្រះអរិយៈ(១) មិនឈ្លាសវៃក្នុងធម៌ព្រះអរិយៈ មិនបានហាត់ខ្លួនក្នុងធម៌របស់ព្រះអរិយៈ តាំងមិនបានឃើញពួកសប្បុរស(១) មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបជាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ ពិចារណាឃើញរូបក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងរូបខ្លះ ពិចារណាឃើញវេទនា... សញ្ញា ..សង្ខារតាំងឡាយ... ពិចារណាឃើញវិញ្ញាណជាខ្លួនខ្លះ ពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ ពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ម្នាលអាវុសោវិសាខៈ យ៉ាងនេះឯងហើយ ដែលហៅថា សក្កាយទិដ្ឋិ ។

ច. បពិត្រព្រះនាងជាម្ចាស់ ដែលហៅថា មិនមានសក្កាយទិដ្ឋិ ដូចម្តេច ។

ឆ. ម្នាលអាវុសោវិសាខៈ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈ ឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានហាត់ចិត្តល្អក្នុងធម៌ព្រះអរិយៈ តាំងបានជួបប្រទះនឹងពួកសប្បុរស ឈ្លាសវៃក្នុងធម៌របស់សប្បុរស បានហាត់ចិត្តដោយល្អក្នុងធម៌របស់សប្បុរស មិនបាន

---

១ បុគ្គលដែលឆ្ងាយចាកកិលេសហៅថា អរិយៈ, បុរសដែលល្អដោយលោកុត្តរគុណហៅថា សប្បុរស ពាក្យទាំងពីរនេះសំដៅយក ព្រះពុទ្ធព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវ័ក ។ អដ្ឋកថា ។

ពិចារណាឃើញនូវរូបថាខ្លួនខ្លះ មិនពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ មិនពិចារណាឃើញរូបក្នុងខ្លួនខ្លះ មិនពិចារណាឃើញខ្លួនក្នុងរូបខ្លះ មិនបានពិចារណាឃើញវេទនា... សញ្ញា... សង្ខារទាំងឡាយ... មិនបានពិចារណាឃើញវិញ្ញាណថាខ្លួនខ្លះ មិនបានពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ មិនបានពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ និងមិនពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ម្នាលអាវុសោវិសាខៈ យ៉ាងនេះឯងហើយដែលហៅថា មិនមានសក្កាយទិដ្ឋិ ។

## មគ្គបញ្ហា

(១៤៨) វិ. បពិត្រព្រះនាងជាម្ចាស់ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។

ធ. ម្នាលអាវុសោវិសាខៈ មគ្គដែលប្រកបដោយអង្គ ៨ ប្រការ ដ៏ប្រសើរនេះឯង គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតាំងចិត្តត្រូវ ១ ។

វិ. បពិត្រព្រះនាងជាម្ចាស់ ចុះអដ្ឋង្គិកមគ្គដ៏ប្រសើរនោះ ជាសង្ខតធម៌(១) ឬជាអសង្ខតធម៌ ។

---

១ ជាធម៌ដែលព្រះអរិយៈទៅកើត នៅតាក់តែង ត្រូវតែប្រតិបត្តិហៅថាសង្ខតៈ ។

ធ. ម្នាលអាវុសោវិសាខៈ អដ្ឋង្គិកមគ្គដ៏ប្រសើរ ជាសង្ខតធម៌ ។

វិ. បពិត្រព្រះនាងជាម្ចាស់ ខន្ធទាំង ៣ ប្រការ លោកសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរ ឬអដ្ឋង្គិកមគ្គដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ។

ធ. ម្នាលអាវុសោវិសាខៈ ខន្ធទាំង៣ប្រការ លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខៈ តែអដ្ឋង្គិកមគ្គទាំង ៨ប្រការដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ម្នាលអាវុសោវិសាខៈ សម្មាវាចា១ សម្មាកម្មន្តៈ១ សម្មាអាជីវៈ១ ធម៌ទាំង(៣)នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ សម្មាវាយាមៈ១ សម្មាសតិ១ សម្មាសមាធិ១ ធម៌ទាំង៣នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ សម្មាទិដ្ឋិ១ សម្មាសង្កប្បៈ១ ធម៌ទាំង២នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ។

វិ. បពិត្រព្រះនាងជាម្ចាស់ សមាធិដូចម្ដេច ពួកធម៌ជាសមាធិនិមិត្តដូចម្ដេច ពួកធម៌ជាសមាធិបរិក្ខារដូចម្ដេច សមាធិភាវនាដូចម្ដេច ។

ធ. ម្នាលអាវុសោវិសាខៈ សភាវៈដែលធ្វើចិត្តឲ្យនឹងនៅក្នុងអារម្មណ៍តែមួយ ហៅថា សមាធិ សតិប្បដ្ឋានទាំង ៤ ហៅថា សមាធិនិមិត្ត សម្មប្បធាន៤ ហៅថាសមាធិបរិក្ខារ ការធ្វើចិត្តឲ្យកម្ពល់ទាំង ការចម្រើន និងការធ្វើឲ្យច្រើនចំពោះធម៌ទាំងនោះឯង ហៅថា សមាធិភាវនា ។

## សង្ខារបញ្ហា

(១៤៩) វិ. បពិត្រព្រះនាងជាម្ចាស់ . ចុះសង្ខារទាំងឡាយ មានប៉ុន្មាន ។

ធ. ម្នាលអាវុសោវិសាខៈ សង្ខារទាំងឡាយនេះ មាន៣ គឺកាយ-សង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។

វិ. បពិត្រព្រះនាងជាម្ចាស់ កាយសង្ខារតើដូចម្តេច វចីសង្ខារដូចម្តេច ចិត្តសង្ខារ ដូចម្តេច ។

ធ. ម្នាលអាវុសោវិសាខៈ ខ្យល់ដកដង្ហើមចេញចូលហ្នឹងឯង ហៅថា កាយសង្ខារ វិតក្កៈនិងវិចារៈហៅថា វចីសង្ខារ សញ្ញានិងវេទនា ហៅថា ចិត្តសង្ខារ ។

វិ. បពិត្រព្រះនាងជាម្ចាស់ ព្រោះហេតុអ្វី បានជាខ្យល់ដង្ហើមចេញចូលហៅថា កាយសង្ខារ ព្រោះហេតុអ្វី បានជាវិតក្កៈនិងវិចារៈហៅថា វចីសង្ខារ ព្រោះហេតុអ្វី បានជាសញ្ញានិងវេទនាហៅថា ចិត្តសង្ខារ ។

ធ. ម្នាលអាវុសោវិសាខៈ ការដកដង្ហើមចេញចូលហ្នឹងឯង ជាធម៌ប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនុ៎ះជាធម៌ជាប់ទាក់ទងនឹងកាយ ព្រោះហេតុនោះ បានជាខ្យល់ដកដង្ហើមចេញចូលហៅថាកាយសង្ខារ ម្នាលអាវុសោវិសាខៈ បុគ្គលត្រិះរិះពិចារណាមុនសិន ទើបបញ្ចេញវាចា (ក្រោយ)

ព្រោះហេតុនោះ បានជាវិតក្កៈនិងវិចារៈហៅថា វចីសង្ខារ ឯសញ្ញានិងវេទនា ជាធម៌ប្រព្រឹត្តទៅក្នុងចិត្ត ធម៌ទាំងនុ៎ះជាធម៌ជាប់ទាក់ទងនឹងចិត្ត ព្រោះហេតុនោះ បានជាសញ្ញានិងវេទនាហៅថា ចិត្តសង្ខារ ។

## និរោធបញ្ហា

(១៥០) វិ. បពិត្រព្រះនាងជាម្ចាស់ ចុះសញ្ញាវេទយិតនិរោធសមាបត្តិ ដូចម្តេច ។

ធ. ម្នាលអាវុសោវិសាខៈ ភិក្ខុដែលកំពុងចូលសញ្ញាវេទយិតនិរោធ (នោះ) មិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលសញ្ញាវេទយិតនិរោធ ឬថាអាត្មាអញកំពុងចូលសញ្ញាវេទយិតនិរោធ ឬក៏ថាអាត្មាអញចូលសញ្ញាវេទយិតនិរោធហើយដូច្នេះឡើយ តែថា មុននឹងដល់និរោធសមាបត្តិនោះ ភិក្ខុនោះបានចម្រើនចិត្តយ៉ាងនោះ បានជាបង្អោនទៅដើម្បីជាបុគ្គលលះចិត្តសង្ខារ(១) ។

---

១ តាមសេចក្តីយល់ថា របៀបចូលសញ្ញាវេទយិតនិរោធនោះ ត្រូវចូលរូបជ្ឈាននិងអរូបជ្ឈានសិន រួចទើបចូលសញ្ញាវេទយិតនិរោធ ។ មុននឹងដល់សញ្ញាវេទយិតនិរោធនោះ ភិក្ខុនោះមានគំនិតថា នឹងចូលឬចូលយ៉ាងនេះ តែបន្ទាប់ពីនេវសញ្ញានាសញ្ញាយតនៈទៅ ភិក្ខុនោះមិនមានគំនិតថានឹងចូលនិរោធនោះទេ តែដោយអំណាចដែលបានហាត់ចិត្តស្ទាត់មកហើយនោះ ក៏ស្រាប់តែរអិលដល់និរោធនោះតែម្តង ។ ក្នុងនិរោធនោះសោតគ្មានចិត្តសង្ខារទេ គឺលះសញ្ញានិងវេទនារស់ ដូចជាបុគ្គលគ្មានចិត្ត ។ (សេចក្តីយល់នេះ បាននៅក្នុងធម្មលក្ខណៈនៃសូត្រនោះឯង) ។

ស. បពិត្រព្រះនាងជាម្ចាស់ ចុះភិក្ខុដែលចូលសញ្ញាវេទយិតនិរោធ ពួកធម៌ណាលត់មុន កាយសង្ខារ ឬវចីសង្ខារ ឬក៏ចិត្តសង្ខារ (លត់មុន) ។

ឆ. ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធនោះ វចីសង្ខារលត់មុន តមកទើបកាយសង្ខារ ( លត់ ) តពីនោះមកទៀត ទើបចិត្តសង្ខារ ( លត់ ) ។

ស. បពិត្រព្រះនាងជាម្ចាស់ ការចេញអំពីសញ្ញាវេទយិតនិរោធសមា-បត្តិមកវិញ ដោយប្រការដូចម្តេច ។

ឆ. ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ( នោះ ) មិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ឬថា អាត្មាអញចេញអំពីសញ្ញាវេទយិត-និរោធសមាបត្តិឥឡូវនេះ ឬក៏ថា អាត្មាអញចេញហើយអំពីសញ្ញាវេទយិតនិរោធសមាបត្តិដូច្នេះឡើយ តែថា មុននឹងចេញអំពីនិរោធសមាបត្តិនោះ ភិក្ខុនោះចម្រើនចិត្តយ៉ាងនេះ បានជាបង្អោនចិត្តទៅ ដើម្បីជាបុគ្គលមានចិត្តសង្ខារឡើងវិញ ។

ស. បពិត្រព្រះនាងជាម្ចាស់ ចុះភិក្ខុដែលចេញអំពីសញ្ញាវេទយិត-និរោធ ពួកធម៌ណាកើតមុន កាយសង្ខារ ឬវចីសង្ខារ ឬក៏ ចិត្តសង្ខារ ( កើតមុន ) ។

ធ. ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិនោះ (នោះ) ចិត្តសង្ខារកើតមុន តមក ទើបកាយសង្ខារ (កើត) តពីនោះមកទៀត ទើបវចីសង្ខារ (កើត) ។

វិ. បពិត្រព្រះនាងជាម្ចាស់ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ មានផស្សៈប៉ុន្មានពាល់ត្រូវ ។

ធ. ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ មានផស្សៈ ៣ ប្រការពាល់ត្រូវគឺ សុញ្ញតផស្សៈ(១) ១ អនិមិត្តផស្សៈ(១) ១ អប្បណិហិតផស្សៈ(១) ១ ។

វិ. បពិត្រព្រះនាងជាម្ចាស់ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្ត (លោក) បង្អោនទៅរកអ្វី ទោរទន់ទៅរកអ្វី ឈមទៅរកអ្វី ។

ធ. ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្តលោកបង្អោនទៅរកវិវេក ទោរទន់ទៅរកវិវេក ឈម

---

១ ផស្សៈដែលកើតជាមួយនឹងសុញ្ញតផលសមាបត្តិឈ្មោះថា សុញ្ញតផស្សៈ។ ផស្សៈដែលកើតជាមួយនឹងអនិមិត្តផលសមាបត្តិនោះ ហៅថា អនិមិត្តផស្សៈ ។ ផស្សៈដែលកើតជាមួយនឹងអប្បណិហិតផលសមាបត្តិនោះ ហៅថា អប្បណិហិតផស្សៈ ។ អដ្ឋកថា ។

ទៅកើតទៀត ៗ

## វេទនាបញ្ហា

(១៨១) វ. បពិត្រព្រះនាងជាម្ចាស់ វេទនាតើមានចំនួន ?

ធ. ម្នាលអាវុសោវិសាខៈ វេទនានេះមាន ៣ ប្រការគឺ សុខវេទនា១ ទុក្ខវេទនា១ អទុក្ខមសុខវេទនា១ ។

វ. បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនាតើដូចម្តេច ទុក្ខវេទនាដូចម្តេច អទុក្ខមសុខវេទនាតើដូចម្តេច ?

ធ. ម្នាលអាវុសោវិសាខៈ ធម្មជាតិដែលទទួលអារម្មណ៍ជាសុខដ៏ឆ្ងាញ់ ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថា សុខវេទនា ម្នាលអាវុសោវិសាខៈ ធម្មជាតិដែលទទួលអារម្មណ៍ជាទុក្ខមិនឆ្ងាញ់ ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថា ទុក្ខវេទនា ម្នាលអាវុសោវិសាខៈ ធម្មជាតិដែលទទួលអារម្មណ៍ដែលឆ្ងាញ់ក៏មិនមែន មិនឆ្ងាញ់ក៏មិនមែន ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថា អទុក្ខមសុខវេទនា ។

វ. បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនាមានអ្វីជាសុខ មានអ្វីជាទុក្ខ ?

ធ. ម្នាលអាវុសោវិសាខៈ សុខវេទនាមានកិរិយាឋិតនៅដែលជា

សុខ មានការប្រែប្រួលទៅវិញជាទុក្ខ ទុក្ខវេទនា មានកិរិយាឋិតនៅជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញជាសុខ ឯអទុក្ខមសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹងជាទុក្ខ ។

## អនុសយបញ្ហា

វិ. បពិត្រព្រះនាងជាម្ចាស់ ចុះអនុស័យអ្វី ដេកសម្ងំនៅក្នុងសុខវេទនា អនុស័យអ្វី ដេកសម្ងំនៅក្នុងទុក្ខវេទនា អនុស័យអ្វីដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។

ធ ម្នាលអាវុសោវិសាខៈ រាគានុស័យ ដេកសម្ងំនៅក្នុងសុខៈ-វេទនា បដិឃានុស័យ ដេកសម្ងំនៅក្នុងទុក្ខវេទនា អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។

វិ. បពិត្រព្រះនាងជាម្ចាស់ រាគានុស័យ សុទ្ធតែដេកសម្ងំនៅក្នុងសុខវេទនាទាំងអស់ បដិឃានុស័យ សុទ្ធតែដេកសម្ងំនៅក្នុងទុក្ខវេទនាទាំងអស់ អវិជ្ជានុស័យ សុទ្ធតែដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនាទាំងអស់ ឬដូចម្តេច ។

ធ. ម្នាលអាវុសោវិសាខៈ រាគានុស័យ មិនសុទ្ធតែដេកសម្ងំនៅក្នុងសុខវេទនាទាំងអស់ទេ បដិឃានុស័យ មិនសុទ្ធតែដេកសម្ងំនៅក្នុងទុក្ខវេទនាទាំងអស់ទេ អវិជ្ជានុស័យ មិនសុទ្ធតែដេកសម្ងំនៅក្នុងអទុក្ខម

សុខវេទនាទាំងអស់ទេ ។

វ. បពិត្រព្រះនាងជាម្ចាស់ ចុះអ្វីដែលបុគ្គលត្រូវលះបង់ដោយសុខវេទនា អ្វីដែលត្រូវលះបង់ដោយទុក្ខវេទនា អ្វីដែលត្រូវលះបង់ដោយអទុក្ខមសុខវេទនា ។

ធ. ម្នាលអាវុសោវិសាខៈ រាគានុស័យ ត្រូវលះបង់ដោយសុខវេទនា បដិឃានុស័យត្រូវលះបង់ដោយទុក្ខវេទនា អវិជ្ជានុស័យត្រូវលះបង់ដោយអទុក្ខមសុខវេទនា ។

វ. បពិត្រព្រះនាងជាម្ចាស់ រាគានុស័យ ត្រូវលះបង់ដោយសុខវេទនាទាំងអស់ បដិឃានុស័យ ត្រូវលះបង់ដោយទុក្ខវេទនាទាំងអស់ អវិជ្ជានុស័យ ត្រូវលះបង់ដោយអទុក្ខមសុខវេទនាទាំងអស់ឬ ។

ធ. ម្នាលអាវុសោវិសាខៈ រាគានុស័យមិនត្រូវលះបង់ដោយសុខវេទនាទាំងអស់ទេ បដិឃានុស័យ មិនត្រូវលះបង់ដោយទុក្ខវេទនាទាំងអស់ទេ អវិជ្ជានុស័យ មិនត្រូវលះបង់ដោយអទុក្ខមសុខវេទនាទាំងអស់ទេ ។ ម្នាលអាវុសោវិសាខៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីវិវេក លោកលះបង់រាគៈ ដោយបឋមជ្ឈាននោះ ឯរាគានុស័យ ដេកសម្ងំនៅ

ក្នុងបឋមជ្ឈាននោះ មិនបានទេ ម្នាលអាវុសោវិសាខៈ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញដូច្នេះថា កាលណាហ្ន៎ អាត្មាអញនឹងបានចូលកាន់អាយតនៈគឺអរហត្ត ដែលពួកព្រះអរិយៈតែងចូលក្នុងកាលឥឡូវនេះ កាលបើភិក្ខុតាំងនូវសេចក្តីប្រាថ្នា ចំពោះពួកវិមោក្ខដ៏ប្រសើរដូច្នេះហើយ ទោមនស្សរមែងកើតឡើង ព្រោះសេចក្តីប្រាថ្នាជាបច្ច័យ ភិក្ខុនោះរមែងលះបង់នូវបដិឃៈដោយទោមនស្ស(១) ឯបដិឃានុស័យ ក៏ដេកសម្ងំនៅក្នុងទោមនស្សនោះមិនបានទេ ម្នាលអាវុសោវិសាខៈ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សេចក្តីសុខផង លះបង់សេចក្តីទុក្ខផង រលត់សោមនស្សនិងទោមនស្សក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈានដែលឥតសុខឥតទុក្ខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅដោយឥរិយាបថតាំង៤ ភិក្ខុនោះ រមែងលះបង់អវិជ្ជាដោយចតុត្ថជ្ឈាននោះ អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងចតុត្ថជ្ឈាននោះ មិនបានឡើយ ។

---

១ អដ្ឋកថាពន្យល់ថា មិនមែនលះបង់បដិឃៈដោយទោមនស្សតែម្តងទេ គឺភិក្ខុដែលមានសេចក្តីប្រាថ្នាចង់បានអរហត្តផល ហើយមិនបានដូចប្រាថ្នា ទោមនស្សក៏កើតឡើង ម្ល៉ោះហើយភិក្ខុនោះខំប្រឹងប្រែងធ្វើសេចក្តីព្យាយាមរហូតដល់បានរលាស់បដិឃៈចោល ដោយអនាគាមិមគ្គបាន ។ ម្យ៉ាងទៀត ទោមនស្សនេះ ពិតជាអកុសលដោយចំណែកមួយមែនហើយ តែទោមនស្សនេះ គួរសេពគប់ ។

## បដិភាគបុច្ឆា

(១៥២) វិ. បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនាមានអ្វីជាគ្រឿងប្រៀបធៀប (បដិភាគ) ឲ្យប្រៀបហេលគ្នា ។

ធ. ម្នាលអាវុសោវិសាខៈ សុខវេទនាមានរាគៈជាគ្រឿងប្រៀបធៀប ។

វិ. បពិត្រព្រះនាងជាម្ចាស់ ចុះទុក្ខវេទនាមានអ្វីជាគ្រឿងប្រៀបធៀប ។

ធ. ម្នាលអាវុសោវិសាខៈ ទុក្ខវេទនាមានបដិឃៈជាគ្រឿងប្រៀបធៀប ។

វិ. បពិត្រព្រះនាងជាម្ចាស់ ចុះអទុក្ខមសុខវេទនាមានអ្វីជាគ្រឿងប្រៀបធៀប ។

ធ. ម្នាលអាវុសោវិសាខៈ អទុក្ខមសុខវេទនាមានអវិជ្ជាជាគ្រឿងប្រៀបធៀប ។

វិ. បពិត្រព្រះនាងជាម្ចាស់ ចុះអវិជ្ជាមានអ្វីជាគ្រឿងប្រៀបធៀប ។

ធ. ម្នាលអាវុសោវិសាខៈ អវិជ្ជាមានវិជ្ជាជាគ្រឿងប្រៀបធៀប ។

វិ. បពិត្រព្រះនាងជាម្ចាស់ ចុះវិជ្ជាមានអ្វីជាគ្រឿងប្រៀបធៀប ។

ធ. ម្នាលអាវុសោវិសាខៈ វិជ្ជាមានវិមុត្តិជាគ្រឿងប្រៀបធៀប ។

វិ. បពិត្រព្រះនាងដ៏ជាម្ចាស់ ចុះវិមុត្តិមានអ្វីជាគ្រឿងប្រៀបធៀប ។

ធ. ម្នាលអាវុសោវិសាខៈ វិមុត្តិ មានព្រះនិព្វានជាគ្រឿងប្រៀបធៀប ។

វិ. បពិត្រព្រះនាងដ៏ជាម្ចាស់ ចុះព្រះនិព្វាន មានអ្វីជាគ្រឿងប្រៀបធៀប ។

ធ. ម្នាលអាវុសោវិសាខៈ អ្នកសួរជ្រុលហួសពេកហើយ អ្នកណា ក៏មិនអាចនឹងកាន់យកទីបំផុតរបស់ប្រស្នាទាំងឡាយ (នេះ) បានទេ ម្នាលអាវុសោវិសាខៈ ព្រោះព្រហ្មចរិយធម៌ ឈមទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត ម្នាលអាវុសោវិសាខៈ បើអ្នកត្រូវការ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលសួរសេចក្តីនេះចុះ បើព្រះមានព្រះភាគ ទ្រង់ព្យាករដែលអ្នកយ៉ាងណា ត្រូវអ្នកចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។

## ធម្មទិន្នាបសំសា

## ការទ្រង់សរសើរធម្មទិន្នាភិក្ខុនី

(១៨៣) លំដាប់នោះឯង វិសាខឧបាសក ត្រេកអរអនុមោទនាចំពោះភាសិតរបស់ធម្មទិន្នាភិក្ខុនី ហើយក្រោកចាកអាសនៈថ្វាយបង្គំធម្មទិន្នាភិក្ខុនី ធ្វើប្រទក្សិណហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ

លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានបុញ្ញសិរី ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះវិសាខឧបាសក អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលពាក្យដែលខ្លួនបានចរចា នឹងធម្មទិន្នាភិក្ខុនីទាំងប៉ុន្មាន ចំពោះព្រះមានព្រះភាគ ដោយសព្វគ្រប់ ។ លុះវិសាខឧបាសក ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងវិសាខឧបាសក យ៉ាងនេះថា ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនី ជាបណ្ឌិត ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនី ជាស្ត្រីមានប្រាជ្ញាច្រើន ម្នាលវិសាខៈ បើទុកជាអ្នកត្រឡប់សួរសេចក្តីនុ៎ះ នឹងតថាគតវិញ តថាគតក៏គួរព្យាករសេចក្តីនុ៎ះ ដូចសេចក្តីដែលធម្មទិន្នាភិក្ខុនីព្យាករហើយ យ៉ាងនោះដែរ សេចក្តីនៃប្រស្នានោះ យ៉ាងហ្នឹងហើយ ចូរអ្នកចាំទុកប្រស្នានុ៎ះយ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគ ត្រាស់ភាសិតនេះហើយ វិសាខឧបាសក ក៏ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ចូឡវេទល្លសូត្រ

# ភណ្ឌទី ៤

## បេតវត្ថុ

រឿងខេត្តូបមាប្រេត

រឿងប្រេតជាមាតានៃព្រះសារីបុត្ត

រឿងនាងមត្តាប្រេត

រឿងនន្ទាប្រេត

រឿងសានុវាសិប្រេត

សុត្តន្តបិដក

ខុទ្ទកនិកាយ បេតវត្ថុ

បឋមភាគ

---

( *ការសរសេរដកស្រង់* )

នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការ ព្រះមានព្រះភាគ*

*អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

ឧរគវគ្គទី ១

រឿងខេត្តូបមាប្រេត (១)

*(១) ពួកព្រះអរហន្ត ដូចស្រែ ពួកទាយក ដូចអ្នកភ្ជួរស្រែ ទេយ្យធម៌ ដូចពូជ ផលកើតមកអំពីព្រះអរហន្ត និងទាយក និងទេយ្យធម៌នុ៎ះ ឯពូជនិងការភ្ជួររាស់និងស្រែនុ៎ះ តែងមានដល់ពួកប្រេតទាំងឡាយផង ដល់ទាយកផង ប្រេតទាំងឡាយតែងបរិភោគនូវផលនៃទាននោះ ទាយកអ្នកឲ្យទាន តែងចម្រើនដោយបុណ្យ ក្នុងលោកនេះ បុគ្គលធ្វើកុសលហើយ គួរតែបូជាចំពោះប្រេតទាំងឡាយ ព្រោះថាបុគ្គល*

---

១ សៀវភៅព្រះត្រៃបិដកលេខ ៥៦

ធ្វើកុសលកម្មដ៏ចម្រើន រមែងទៅកាន់ឋានសួគ៌ ។

ចប់ រឿងខេត្តូបមាប្រេត ។

## រឿងប្រេតជាមាតានៃព្រះសារីបុត(១)

(១៤) (ព្រះសារីបុត្តសួរថា) ម្នាលស្រីស្គម មានឆ្អឹងជំនីរគាម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនពេញទៅដោយសរសៃ នាងជាអ្វីមកឈរនៅទីនេះ ។

(នាងប្រេតតបថា) អំពីមុន ខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្ដីស្រេកឃ្លាន បរិភោគទឹកមាត់ដែលគេស្ដោះចោល ទឹកសម្បោរ ស្លេស្ម ខ្ទាញ់ពក (នៃសាកសព) ដែលគេដុត និងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន និងឈាមនៃដំបៅនឹងច្រមុះនឹងក្បាលដាច់ មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគខ្ទុះនិងឈាមដែលជាប់នឹងសរីរៈនៃស្ត្រីនិងបុរស ខ្ទុះនិងឈាម នៃបសុសត្វនិងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំនៅ ដេកតែលើទីស្មសាន ដូចគ្រែ លោកម្ចាស់ជាបុត្រ សូមលោកម្ចាស់ឲ្យទានដើម្បីខ្ញុំ លុះឲ្យហើយ ដូ.

---

១ ក្នុងឧព្វរីវគ្គទី ២ ។

ទទួលផលដល់ខ្ញុំ តើធ្វើម្ដេចហ្ន៎ ឲ្យខ្ញុំគប្បីបានរួចចាកការបរិភោគនូវខ្ទុះនិងឈាម ។

ព្រះអគ្គសាវ័ក មាននាមថា ឧបតិស្សៈ(១) លុះបានស្ដាប់ពាក្យនៃនាងប្រេត ជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិនៈ ១ ឲ្យធ្វើកុដិទាំងឡាយ ៤ ខ្នង ហើយនោះផងដែរ ឲ្យញុំាងនូវ ចំពោះសង្ឃដែលមកអំពីទិសទាំង ៤ ហើយឧទ្ទិសទក្ខិណានុប្បទានដល់មាតា ។ វិបាក ក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ គោលឧបាហារនិងទឹកផឹកនិងសំពត់ (ក៏កើតឡើង) នេះជាផលនៃទក្ខិណាទាន លំដាប់នោះ (ស្រីនោះ) ស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងអលង្ការណៈដ៏វិចិត្រ បានចូលទៅរកព្រះកោលិត ។

(ព្រះកោលិតសួរថា) ម្នាលនាងទេវតា នាងមានសម្បុរល្អ មកឈរនៅ (ទីនេះ) ភ្លឺស្វាងរួងរឿងសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក ឯសម្បុរប្រាកដដូច្នោះ កើតឡើងដល់នាង ដោយហេតុដូចម្ដេច ផលនៃសុចរិត សម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេច បានជាភោគៈណាទាំងឡាយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវតា មានអានុភាពច្រើន យើងសូម

---

១ ព្រះសារីបុត្ត មានឈ្មោះថា ឧបតិស្សៈ ។

សួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើ
បុណ្យដូចម្ដេច នាងជាទេវធីតា មានអានុភាព
ភ្លឺផ្លេកយ៉ាងនេះ ចាំងសម្បុរនាង គំភ្លឺសព្វ
ទិស . ដោយបុញ្ញកម្ម ដូចម្ដេច ។

(ប្រេតតបថា) អំពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ក្នុងជាតិទាំងឡាយដទៃ មកកើតក្នុងកំណើតនៃប្រេត ។ល។ ដេកនៅលើទីស្មសានដូចគ្រែ ។ ខ្ញុំត្រេកអរដោយទាននៃព្រះសារីបុត្ត ទើបមិនមានភ័យក្នុងទីណាៗ បពិត្រលោកដ៏ចម្រើន ខ្ញុំមក ដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញ ប្រកបដោយសេចក្ដីករុណាក្នុងលោក ។

## ចប់រឿងប្រេតជាមាតានៃព្រះសារីបុត្ត

## រឿងនាងមត្តាប្រេត(១)

(១៥) (នាងតិស្សាសួរថា) ម្នាលស្រីស្គម មានឆ្អឹងជំនីរគោម នាងជាស្រីមានកាយអាក្រាត មានរូបអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរលីងដោយសរសៃ នាងជាអ្វី បានជាមកឈរនៅក្នុងទីនេះ ។

(នាងមត្តាប្រេតតបថា) កាលអំពីមុន ខ្ញុំនិងឯង ឈ្មោះតិស្សា

---

១ ក្នុងឧព្វរីវគ្គទី ២ ។

ខ្ញុំឈ្មោះមត្តា ជាស្រីរួមប្ដីរបស់នាង បានធ្វើអំពើបាប ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

(គ.)(១) ចុះអំពើអាក្រក់ ដែលនាងបានធ្វើហើយ ដោយកាយ វាចា ចិត្តនោះ តើដូចម្ដេច នាងឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះវិបាកនៃកម្មដូចម្ដេច ។

(ម.)(២) ខ្ញុំជាស្រីសាហាវ (ឆ្នាស) បានពោលជេរស្ដីជា ស្រីប្រុស ក៏ណាញ់ អួតអាង ខ្ញុំនោះបានពោលពាក្យអាក្រក់ ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ។

(គ.) ពិតមែនហើយ យើងបានដឹងថា នាងជាស្រីឆ្នាស យើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងមានខ្លួនប្រាណប្រឡាក់ដោយអាចម៍ដី ព្រោះកម្មដូចម្ដេច ។

(ម.) នាងបានលុបលាងក្បាលរួចហើយ មានសំពត់ថ្មីស្អាតប្រដាប់ហើយ ខ្ញុំនិងយើងសោត ក៏ប្រដាប់តាក់តែងដោយគ្រឿងអលង្ការដ៏ក្រៃលែងជាងនាង កាលខ្ញុំនោះកំពុងសម្លឹងមើល ឯងក៏ពោលចរចានឹងស្វាមី ក្នុងលំដាប់នោះ ខ្ញុំមានសេចក្ដីឫស្សាកើតណាស់ ខ្ញុំបាន

---

១ ដើម្បីកុំឲ្យអ្នករៀនច្រឡំសេចក្ដី ទើបធ្វើអក្សរអាទិសង្កេតនេះ គ. គឺនាងតិស្សា ។ ២ ម. គឺនាងមត្តាប្រេត ច្បាប់ដើមបិនមានអក្សរ គ. ម. នេះទេ ។

សេចក្ដីក្រោធកើតឡើង គអំពីនោះ ខ្ញុំក៏ប្រវ៉ាយកអាចម៍ដី ទៅរោយដាក់នាងដោយអាចម៍ដី ព្រោះហេតុនោះ ខ្ញុំទើបមានខ្លួនប្រឡាក់ដោយអាចម៍ដី ព្រោះវិបាកនៃកម្មនោះឯង ។

(ក.) ពិតមែនហើយ យើងដឹងថា នាងបានរោយអាចម៍ដីដាក់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងត្រូវកេកកម-រមាស់បៀតបៀនដោយកម្មអ្វី ។

(ម.) យើងទាំងពីរនាក់ បានចូលទៅកាន់ព្រៃដើម្បីរកថ្នាំ ចំណែកនាងបានយកថ្នាំមក ឯខ្ញុំបាននាំយកខ្ញែមកវិញ កាលបើនាងមិនដឹង ខ្ញុំក៏រោយខ្ញែលើដំណេករបស់នាង ព្រោះហេតុនោះ រាងកាយរបស់ខ្ញុំទើបត្រូវកេកកមរមាស់បៀតបៀន ព្រោះវិបាកនៃកម្មនោះឯង ។

(ក.) ពិតមែនហើយ យើងបានដឹងថា នាងបានរោយ (ខ្ញែ) លើដំណេករបស់យើង តែយើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងមានកាយអាក្រាត ដោយកម្មអ្វី ។

(ម.) មានការប្រជុំមិត្តសម្លាញ់ និងជួបជុំពួកញាតិ គេបានហៅនាងព្រមទាំងស្វាមី តែខ្ញុំគេមិនហៅ កាលបើនាងមិនបានដឹង ខ្ញុំក៏លួចយកសំពត់នាងទៅលាក់ ហេតុនោះ ខ្ញុំទើបមានរាងកាយអាក្រាត ព្រោះវិបាកនៃកម្មនោះឯង ។

(ក) ពិតមែនហើយ យើងដឹងថា នាងបានលួចសំពត់របស់យើងទៅលក់ យើងសួរនាងពីហេតុដទៃទៀត ចុះកាយរបស់នាងមានក្លិនស្អុយដូចក្លិនលាមក ព្រោះកម្មអ្វី ។

(ម.) ខ្ញុំបានលួចយកនូវគ្រឿងក្រអូប ជាកម្រង និងគ្រឿងលាបដ៏មានតម្លៃ របស់នាងទៅចោលក្នុងរណ្តៅលាមក ខ្ញុំបានធ្វើអំពើអាក្រក់នោះ ហេតុនោះ បានជាខ្ញុំមានក្លិនស្អុយដូចក្លិនលាមក ព្រោះហេតុវិបាកនៃកម្មនោះឯង ។

(ក.) ពិតមែនហើយ យើងបានដឹងហើយថា នាងបានធ្វើអំពើអាក្រក់នោះ យើងសូមសួរនាងអំពីហេតុដទៃទៀត ចុះនាងជាស្រីទុគ៌ត ព្រោះវិបាកនៃកម្មអ្វី ។

(ម.) កាលយើងទាំងពីរនាក់ មានទ្រព្យសម្បត្តិក្នុងផ្ទះស្មើគ្នា កាលទេយ្យធម៌មាន ខ្ញុំក៏មិនបានធ្វើទីពឹងដើម្បីខ្លួន ព្រោះហេតុនោះ បានជាខ្ញុំជាស្រីទុគ៌ត ដោយវិបាកនៃកម្មនោះឯង ។

(ក.) នាងឯងបានស្តីឲ្យខ្ញុំថា នាងកុំសេពអំពើអាក្រក់ ដ្បិតថា សុគតិ មិនមែនបានដោយងាយ ព្រោះបាបកម្មឡើយ ។ នាងបានកំហែងយើង ដោយបទ្ទុស ទាំងបានឫស្យាយើង នាងចូរមើលចុះ វិបាកនៃអំពើអាក្រក់ប្រាកដយ៉ាងណា (អំពីមុន) ខ្ញុំស្រីទាំងឡាយ

ក្នុងផ្ទះនោះ និងគ្រឿងប្រដាប់ប្រដានោះឯងជារបស់ខ្ញុំក៏មាន (ស្ត្រីនេះ) របស់អស់នោះ ក៏បានទៅអ្នកដទៃប្រើប្រាស់ ទ្រព្យទាំងឡាយ ក៏ជារបស់មិនទៀង ស្ត្រីនេះ (កុដុម្ពិក) ជាបិតារបស់ខ្ញុំ ត្រឡប់អំពីផ្សារមកផ្ទះ ធ្វើដូចម្ដេច កុដុម្ពិក នឹងឲ្យទេយ្យធម៌តិចតួចដល់នាង នាងកុំអាលទៅអំពីទីនេះឡើយ ។

(ម.) ខ្ញុំជាស្រីអាក្រាត មានរូបកាយអាក្រក់ក្រៃពេក ជាស្រីស្គមមានខ្លួនកើមទៅដោយសរសៃ នេះជាកេរ្តិ៍ខ្មាសរបស់ស្រីទាំងឡាយ កុំឲ្យកុដុម្ពិក ជាបិតានាងមកឃើញខ្ញុំឡើយ ។

(គ.) បើដូច្នោះ ខ្ញុំគួរឲ្យអ្វីដល់នាង ម្យ៉ាងទៀតខ្ញុំនឹងធ្វើឧបការៈអ្វីដល់នាង ដើម្បីជាហេតុឲ្យនាងសម្រេចដោយសេចក្ដីប្រាថ្នាទាំងពួង ដល់នូវសេចក្ដីសុខ ។

(ម.) នាងចូរនិមន្តភិក្ខុ៨រូប គឺភិក្ខុ៤រូបអំពីសង្ឃ ភិក្ខុ៤រូបទៀតអំពីបុគ្គលឲ្យឆាន់ ហើយឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំនោះ ជាហេតុឲ្យខ្ញុំសម្រេចសេចក្ដីប្រាថ្នាទាំងពួង ដល់នូវសេចក្ដីសុខ ។

នាងតិស្សា បានទទួលពាក្យនាងមត្តាប្រេតថា សាធុ ហើយទើបនិមន្តភិក្ខុ ៨ រូបឲ្យឆាន់ រួចហើយឲ្យស្លៀកដណ្ដប់ដោយសំពត់ទាំងឡាយ ហើយឧទ្ទិសនូវទក្ខិណាទាន ដល់នាងមត្តាប្រេតនោះ ។ វិបាកក៏កើត

ឡើងក្នុងលំដាប់ដែលខ្ញុំសរហើយ កោដ្ឋាគារ សំពត់ស្លៀកដណ្តប់និងទឹកដីក ក៏កើតឡើង នេះជាផលនៃទក្ខិណាទាន លំដាប់នោះ នាងប្រែកជាស្រីស្អាត មានគ្រឿងស្លៀកពាក់ស្អាត ទ្រទ្រង់ខ្លួនសំពត់ដ៏ឧត្តម ជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ទើបបានចូលទៅរកនាងតិស្សាជាស្រីរួមប្តី ។

(នាងតិស្សាសួរថា) ម្នាលនាងទេវធីតា នាងមានសម្បុរដ៏រុងរឿងដោយស្រី មកឋិតនៅ ក្នុងស្ថានខ្ពស់ឲ្យភ្លឺទិសទាំងឡាយ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នោះ ដោយហេតុដូចម្តេច ផលនៃសុចរិត សម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេច បានជាភោគៈទាំងឡាយណានីមួយ ដែលជាទីពេញចិត្តកើតឡើងដល់នាង

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូម។
សួរនាង នាងកើតជាមនុស្សបានធ្វើបុណ្យកម្មដូច
ម្តេច នាងជាទេវធីតាមានអានុភាពភ្លឺផ្លេកយ៉ាង
នេះ ដោយបុណ្យកម្មដូចម្តេចបានជានាង
មានអានុភាពដ៏រុងរឿង ទាំងសម្បុររបស់នាង
ក៏ភ្លឺសព្វទិស ។

(នាងមត្តាប្រាប់តបថា) កាលអំពីមុន នាងឈ្មោះតិស្សា ខ្ញុំ

ខ្ញុំឈ្មោះមត្តា ជាស្រីរួមប្តីរបស់នាង បានធ្វើនូវអំពើអាក្រក់ ទើបបានឃ្លាតអំពីមនុស្សលោកនេះ ទៅកាន់បេតលោក ខ្ញុំត្រេកអរដោយទានរបស់នាង ដែលបានឲ្យហើយ ទើបមិនមានភ័យក្នុងទីណាឡើយ ។ ម្នាលប្អូន ចូរនាងរស់នៅអស់កាលយូរ ព្រមដោយពួកញាតិទាំងអស់ចុះ ម្នាលនាងល្អ ចូរនាងខំប្រព្រឹត្តធម៌ ខំឲ្យទានក្នុងលោកនេះ នឹង (ចូលទៅកាន់ឋានសួគ៌) ដែលមិនមានសោក មិនមានធូលី ជាទីនៅនៃសេវត្តីទេវតាផងទាំងឡាយ ។ នាងចូរបន្ទោបង់នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫសគល់ចេញដែលគេនិន្ទាមិនបាន ចូលទៅកាន់ឋានសួគ៌ ។

## ចប់ រឿងនាងមត្តាប្រេតៈ ។

## រឿងនន្ទាប្រេត(១)

(១៦) (នន្ទសេនជាស្វាមីសួរថា) នាងជាស្រីមានខ្លួនខ្មៅ មានរូបអាក្រក់គ្រោតគ្រាតមើលគួរខ្លាច មានភ្នែកលឿង មានធ្មេញក្រឡើល យើងមិនសម្គាល់ថានាងជាស្រីមនុស្សទេ ៖

(នាងនន្ទាប្រេតតបថា) ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះកាន់បេតលោក ។

---

១ ក្នុងឧព្វរិវគ្គទី ២ ។

(ន.)(១) ចុះកំណើតអាក្រក់ដែលនាងបានទទួលហើយ ដោយសារកាយ វាចា ចិត្តនោះ តើដូចម្ដេចខ្លះ នាងទៅអំពីមនុស្សលោក.ន.កាន់បេត. លោក ដោយវិបាកនៃកម្មដូចម្ដេចខ្លះ ៗ

(នា.)(២) ខ្ញុំជាស្រីកំណាចផង មានវាចាអាក្រក់ផង ឥតមាន សេចក្ដីគោរពចំពោះអ្នកផង ខ្ញុំពោលពាក្យអាក្រក់ ចំពោះអ្នក ទើប បានទៅអំពីមនុស្សលោកនេះ កាន់បេតលោក ៗ .

(ន.) បើដូច្នោះ យើងនឹងឲ្យសំពត់សាដកដល់នាង ចូរនាងស្លៀក សំពត់នេះចុះ លុះនាងស្លៀកសំពត់នេះហើយ ចូរចូលមក យើងនឹង នាំនាងទៅផ្ទះ នាងទៅដល់ផ្ទះហើយ នឹងបានសំពត់ បាយទឹក បាន ឃើញនូវបុត្តទាំងឡាយ របស់នាងផង បានឃើញកូនប្រសាស្រីរបស់ នាងផង ៗ

(នា.) វត្ថុដែលអ្នកបានឲ្យផ្ដាលដៃដោយដៃ មិនសម្រេចដល់ខ្ញុំ ទេ អ្នកចូរញុំាងភិក្ខុទាំងឡាយ ដែលបរិបូណ៌ដោយសីល ជាអ្នកប្រាស ចាកកាមៈ ជាពហុស្សុត ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ហើយ ឧទ្ទិសនូវទក្ខិណាទាន ដល់ខ្ញុំក្នុងវេលានោះ ខ្ញុំទើបនឹងដល់នូវសេចក្ដីសុខ

---

១ ន.គឺនន្ទសេនឧបាសកជាស្វាមី, ។ ២ នា. គឺនាងនន្ទាប្រេត, ច្បាប់ដើមមិនមានអក្សរ ន. នា.នេះទេ ។

សម្រេចនូវសេចក្ដីប្រាថ្នាទាំងពួងបាន ។

- លំដាប់នោះ នន្ទសេនឧបាសកនោះទទួលថាសាធុ ដូច្នេះហើយ បានតាក់តែងនូវទានដ៏បរិបូណ៌គឺ បាយ ទឹក បន្លែ សំពត់ សេនាសនៈ ឆត្រ គ្រឿងក្រអូប ផ្កាកម្រង ស្បែកជើងផ្សេងៗ ។ នន្ទិសេនឧបាសក ក៏បានញ៉ាំងកិច្ចទាំងឡាយដែលបរិបូណ៌ដោយសីល ព្រោះ យាចកៈ ជាពហុស្សុត ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក ហើយ ឧទ្ទិសទក្ខិណាទាន ដល់នាងឧត្តរាប្រេត ។

វិបាកក៏កើតឡើងក្នុងលំដាប់ដែលបានឧទ្ទិស គោជនាហារ សំពត់ ស្បៀង ទាំងទឹកផឹកក៏កើតឡើង នេះជាផលនៃទក្ខិណាទាន លំដាប់ នោះ នាងឧត្តរាប្រេតនោះ ជាស្រីស្អាត មានសំពត់ស្អាត ទ្រទ្រង់នូវសំពត់ ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាភរណៈដ៏វិចិត្រ ចូលទៅរកស្វាមី ។

(នន្ទិសេនឧបាសកសួរថា) ម្នាលនាងទេវតា នាងមានសម្បុររុងរឿង គឺស្វាងខ្លួនទៅសព្វទិសទាំងឡាយ ដូចផ្កាយព្រឹក សម្បុររបស់នាងប្រាកដដូច្នេះ ដោយហេតុដូចម្ដេច ផលៈនៃសុចរិតសម្រេច ដល់នាងក្នុងទីនេះ ដោយហេតុដូចម្ដេច បានជាភោគៈទាំងឡាយណា នីមួយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរ
នាង នាងកាលកើតជាមនុស្ស បានធ្វើបុញ្ញកម្មដូចម្តេច
នាងជាទេវធីតាមានអានុភាពរុងរឿងយ៉ាងនេះ ដោយ
បុញ្ញកម្មដូចម្តេច ទាំងសម្បុររបស់នាងក៏ភ្លឺសព្វទិស ៖

(នាងប្រេតតបថា) ម្នាលនន្ទសេន ខ្ញុំឈ្មោះនន្ទា ជាភរិយារបស់អ្នកក្នុងកាលមុន បានធ្វើអំពើអាក្រក់ ទើបបានទៅអំពីមនុស្សលោកនេះកាន់បរលោក ខ្ញុំក្រេកអរដោយទានរបស់អ្នកដែលបានឲ្យហើយ ទើបឥតមានភ័យក្នុងទីណាៗឡើយ ។ ម្នាលគហបតី អ្នកព្រមទាំងពួកញាតិទាំងអស់គ្នា ចូររស់នៅអស់កាលយូរ ម្នាលគហបតី អ្នកប្រព្រឹត្តធម៌ ឲ្យទានក្នុងលោកនេះ នឹងចូលទៅកាន់ទីស្ថាន ដែលមិនមានសោក មិនមានធូលី ជាទីនៅនៃសេក្តីទេវកជទាំងឡាយ ។

អ្នកចូរបន្ទោបង់នូវមន្ទិល គឺសេចក្តីកំណាញ់ព្រម
ទាំងឫសគល់ចេញ ព្រោះសពាកនិត្តា ចូរទៅកាន់
ឋានសួគ៌ ។

ចប់ រឿងនន្ទាប្រេត

## រឿងសានុវាសិប្រេត(១)

(៦៧) (ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ពោលថា) ព្រះថេរៈឈ្មោះបោដ្ឋបាទ អ្នកកើតក្នុងក្រុងកុណ្ឌី បាននៅអាស្រ័យលើភ្នំឈ្មោះសានុវាសី ជាអ្នករម្ងាប់បាប មានឥន្ទ្រិយចម្រើនហើយ (ដោយអរិយមគ្គភាវនា) ។ មាតាបិតានិងបងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកដល់នូវសេចក្ដីលំបាក បានកើតក្នុងយមលោក (នរក) លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បេតលោក ព្រោះធ្វើបាបកម្ម ពួកប្រេតទាំងនោះ ជាអ្នកដល់នូវសេចក្ដីលំបាក មានខ្ទារហក់ប៉ុនទម្ពុលក្រដាបក្រដួស មានកាយអាក្រាត ស្គមកំព្រឹង ស្លុតខ្ទក់ ភ័យខ្សឹងខ្សាង ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ បងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកអាក្រាត តែម្នាក់ឯងក្នុងផ្លូវចុះតែដើរមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអវយវៈបួន គឺវារប្រញាប់ប្រញាល់ទៅបង្ហាញខ្លួនដល់ព្រះថេរៈ ។ ព្រះថេរៈ មិនបានធ្វើទុកក្នុងចិត្តថា អ្នកនោះឈ្មោះនេះ ហើយក៏នៅស្ងៀមដើរហួសទៅ ឯប្រេតនោះ បានទូលព្រះថេរៈឲ្យដឹងច្បាស់ថា បពិត្រព្រះថេរៈ ខ្ញុំព្រះករុណាត្រូវជាបងបានទៅកាន់បេតលោកហើយ ។ បពិត្រលោកដ៏ចម្រើន មាតានិងបិតា

---

១ ក្នុងចូឡវគ្គទី ៣ ។

របស់លោក ដល់នូវសេចក្ដីលំបាក កើតក្នុងយមលោក លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បរលោក ព្រោះធ្វើកម្មដ៏លាមក មាតាបិតាទាំងនោះ ជាអ្នកដល់នូវសេចក្ដីលំបាក មានទារមោកប៉ុន ខ្ទម្ទុល ក្រដាបក្រដួស មានកាយអាក្រាក ស្គមក្រិន ស៊ុកខ្ទក់ ភ័យខ្សឹនខ្សាន់ ជាអ្នកបានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឲ្យគេឃើញឡើយ ។ លោកជាអ្នកមានសេចក្ដីករុណាអាសូរ សូមអនុគ្រោះឲ្យទានឧទ្ទិសទៅឲ្យយើងទាំងឡាយផង មាតាបិតាទាំងនោះ ដែលមានកម្មអាក្រក់ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលលោកម្ចាស់ឲ្យហើយ ។

ព្រះថេរៈផង ភិក្ខុទាំងឡាយដទៃ ១៤ អង្គផង ដើរទៅបិណ្ឌបាតហើយប្រជុំក្នុងទីជាមួយគ្នា ព្រោះហេតុនៃភត្តកិច្ច ។ ព្រះថេរៈ បាននិយាយនឹងពួកភិក្ខុទាំងអស់នោះថា លោកទាំងឡាយសូមឲ្យនូវភត្ត ដែលលោកទាំងឡាយបានហើយយាំងណាដល់ខ្ញុំ ខ្ញុំនឹងធ្វើសង្ឃភត្ត ដើម្បីអនុគ្រោះដល់ពួកញាតិ ។

ភិក្ខុទាំងនោះ បានប្រគេន (ភត្តទាំងនោះ) ដល់ព្រះថេរៈ ព្រះថេរៈ បាននិមន្តសង្ឃ លុះព្រះថេរៈបានឲ្យទានហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងផងថា សូមឲ្យទាននេះ សម្រេចដល់ពួកញាតិរបស់ខ្ញុំ

សូមឲ្យពួកញាតិ បានដល់នូវសេចក្តីសុខ ។

គោជនក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស (គោជនៈនោះ) ជាភោជនដ៏ស្អាត ថ្លៃថ្លា ឆ្ងាញ់ ជាម្ហូបមានរសជាច្រើន ក្នុងកាលខាងក្រោយ អំពីកាលដែលបាននូវភោជនោះមក ប្រេតជាបងមានសម្បុរល្អ មានកម្លាំង មានសេចក្តីសុខ បានបញ្ចាញខ្លួន (ដល់ព្រះថេរៈហើយពោលថា) បពិត្រលោកដ៏ចម្រើន សូមលោកមើលមើលនូវភោជនដ៏ច្រើន (ដែលពួកយើងបានហើយ ដោយអនុភាពនៃទានរបស់លោក) ប៉ុន្តែពួកយើងអាក្រាតនៅឡើយ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវសំពត់ដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានរើសកំណាត់សំពត់ចោលទាំងឡាយ អំពីគំនរនៃសម្រាម ហើយធ្វើកំណាត់សំពត់ឲ្យជាផ្ទាំង គឺធ្វើជាចីវរ បានប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំង ៤ ។ ព្រះថេរៈ បានឲ្យទានហើយឧទ្ទិសដល់បិតាមាតានិងបងថា ទាននេះ ចូរសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខ ។

សំពត់ទាំងឡាយ ក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស លំដាប់នោះ (ប្រេតជាបង) ក៏ស្លៀកដណ្តប់សំពត់ដ៏ល្អ

បានបង្ហាញខ្លួនដល់ព្រះថេរៈ ។ (ប្រេតនោះ) មានសម្បុរល្អ មានកម្លាំង មានសេចក្តីសុខ (បាននិយាយថា) បពិត្រលោកដ៏ចំរើន សំពត់ជាគ្រឿងបិទបាំងកាយ ក្នុងដែន របស់ព្រះបាទនន្ទៈទាំងប៉ុន្មាន (សំពត់ជាគ្រឿងបិទបាំង របស់ពួកយើង) ច្រើនលើសជាងសំពត់ជាគ្រឿងបិទបាំងកាយទាំងនោះ ។

សំពត់ទាំងឡាយ ជាគ្រឿងស្លៀកពាក់របស់ពួកយើង គឺកោសេយ្យពស្ត្រ កម្ពលីយពស្ត្រ ខោមពស្ត្រ កប្បាសិកពស្ត្រ ជាសំពត់ដ៏ទូលាយមានថ្លៃច្រើន ឯសំពត់ទាំងនោះ ក៏សំយុងចុះពីអាកាស ពួកយើងនឹងស្លៀកពាក់សំពត់ទាំងនោះ តាមចិត្តស្រឡាញ់ បពិត្រលោកដ៏ចំរើន ពួកយើងគួរបានផ្ទះដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានធ្វើកុដិប្រក់ដោយស្លឹក ហើយប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំងបួន លុះព្រះថេរៈបានប្រគេនហើយឧទ្ទិសដល់បិតា-មាតានិងបងថា សូមទាននេះសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិបានដល់នូវសេចក្តីសុខចុះ ។

ផ្ទះទាំងឡាយ ផ្ទះកំពូលទាំងឡាយ ជាទីនៅ ដែលញែកចែក ដែលចែកដោយប្រមាណស្មើគ្នា ក៏សម្រេច (ដល់ពួកប្រេតទាំងនោះ)

ក្នុងលំដាប់ដែលឧទ្ទិស ។

(ប្រេតទាំងនោះពោលថា) ផ្ទះទាំងឡាយរបស់ពួកយើង ក្នុងបេតលោកនេះ យ៉ាងណា ផ្ទះទាំងឡាយក្នុងមនុស្សលោក មិនដូច្នោះទេ តែផ្ទះទាំងឡាយ ក្នុងឋានទិព្វទាំងឡាយ យ៉ាងណា ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះ យ៉ាងនោះដែរ ជាផ្ទះដ៏រុងរឿង អាចញុំាងទិសទាំង ៤ ឲ្យភ្លឺជុំវិញបាន ។ បពិត្រលោកដ៏ចម្រើន ពួកយើង រួចបានទឹកផឹក ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានដាក់ទឹកបំពេញធម្មក្រក ហើយប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា សូមទាននេះ សម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្ដីសុខ ។

ទឹកក៏សម្រេច (ដល់ប្រេតទាំងនោះ) ក្នុងលំដាប់ដែលឧទ្ទិស ស្រះបោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មនិម្មិតល្អហើយ ជ្រៅ មានជ្រុងបួន មានទឹកដ៏ត្រជាក់ មានកំពង់ល្អ ជាស្រះត្រជាក់ មានក្លិនក្រអូប ប្រៀបមិនបាន ដេរដាសដោយផ្កាឈូកនិងផ្កាឧប្បល ពេញដោយលំអងលើទឹក ។ ប្រេតទាំងនោះងូត ផឹក ក្នុងស្រះបោក្ខរណីនោះហើយ

បង្ហាញខ្លួនដល់ព្រះថេរៈថា បពិត្រលោកដ៏ចម្រើន (ពួកយើងបាន) ទឹកច្រើនហើយ តែជើងទាំងឡាយរបស់ពួកយើង ឈើ ពុករាង ពួកយើងកាលដើរជាន់លើក្រួសក្រាន លើស្បូវភ្លាំងនិងបន្លា រមែងរបួស បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវយាន ដោយប្រការណា សូមលោក ព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈ បានស្បែកជើងមានជាន់មួយ ហើយបានប្រគេនដល់ព្រះសង្ឃដែលមកអំពីទិសទាំង ៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏ឧទ្ទិសចំពោះបិតាមាតានិងបងថា សូមទាននេះ សម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខ ។

ពួកប្រេតបានមកដោយរថ ក្នុងលំដាប់ដែលឧទ្ទិសហើយ (និយាយថា) បពិត្រលោកដ៏ចម្រើន ពួកយើងលោកបានអនុគ្រោះហើយ ដោយបាយផង ដោយគ្រឿងបិទបាំងផង ដោយផ្ទះផង ដោយទានតាំងពីតែបានយានទានផង បពិត្រលោកដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញប្រកបដោយសេចក្តីករុណាក្នុងលោក ។

ចប់ រឿងសានុវាសិប្រេត

ផលបើឧទ្ទិសទក្ខិណាទានដល់ពួកញាតិ

ដែលរំលងខន្ធទៅកាន់លោកខាងនាយ

ឥទំ វោ ញាតីនំ ហោតុ

សុខិតា ហោន្តុ ញាតយោ(១) ។

*សូមឲ្យទាននេះ សម្រេចដល់ពួកញាតិរបស់ខ្ញុំ*

*សូមឲ្យពួកញាតិ បានដល់នូវសេចក្ដីសុខ(១) ។*

---

១ សុត្តន្តបិដក ខុទ្ទកនិកាយ បេតវត្ថុ ចូឡវគ្គទី ៣ ក្នុងរឿងសានុវាសិប្រេត ។

## ភាគទី ៤ ចប់

# ខណ្ឌទី ៥

## បុព្វករណ៍ និង បុព្វកិច្ច

## នៃ

## ឧបោសថកម្ម និង បវារណាកម្ម

## ចំណែកខាងព្រះសង្ឃ

## បុព្វករណ៍ និង បុព្វកិច្ច

## នៃ

## ឧបោសថកម្ម និង បវារណាកម្ម

នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស ។

សុណាតុ មេ ភន្តេ(១) សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, អហំ អាយស្មន្តំ(២) ឥត្ថន្នាមំ(៣) វិនយំ បុច្ឆេយ្យំ ។

សុណាតុ មេ ភន្តេ(១) សង្ឃោ, យទិ សង្ឃស្ស បត្តកល្លំ, អហំ អាយស្មតា(២) ឥត្ថន្នាមេន(៣) វិនយំ

---

១ ពាក្យ "ភន្តេ" នេះ បើភិក្ខុអ្នកសូត្រប្រកាសសង្ឃនោះជាថេរៈចាស់ជាងសង្ឃទាំងអស់ ត្រូវសូត្រផ្លាស់ថា "អាវុសោ" ដូច្នេះវិញ ។ ២ ពាក្យថា "អាយស្មន្តំ អាយស្មតា" នេះជាបិយវចនៈ ពោលក៏គួរ មិនពោលក៏គួរ ។ ៣ ពាក្យថា "ឥត្ថន្នាមំ ឥត្ថន្នាមេន" នេះត្រូវផ្លាស់ចេញហើយបញ្ចូលនាមរបស់ភិក្ខុអ្នកសួរប្រស្នា វិសជ្ជនា មាននាមថា "ពុទ្ធរក្ខិត ធម្មរក្ខិត" ជាដើម ឧទាហរណ៍ដូចជា ភិក្ខុអ្នកបុច្ឆាឈ្មោះពុទ្ធរក្ខិត ភិក្ខុអ្នកវិសជ្ជនាឈ្មោះធម្មរក្ខិត បើពុទ្ធរក្ខិតជាថេរៈចាស់ជាង ត្រង់ឥត្ថន្នាមំ ត្រូវផ្លាស់ថា "ធម្មរក្ខិតំ ភិក្ខុំ" បើខ្ចីជាងត្រូវថា "ធម្មរក្ខិតំ ថេរំ" ដូច្នេះវិញទើបគួរ; ឯភិក្ខុធម្មរក្ខិតអ្នកវិសជ្ជនាក៏ដូច្នោះដែរ គឺបើធម្មរក្ខិតជាថេរៈចាស់ជាង ត្រង់ឥត្ថន្នាមេន ត្រូវផ្លាស់ថា "ពុទ្ធរក្ខិតេន ភិក្ខុនា" បើខ្ចីជាងត្រូវផ្លាស់ថា "ពុទ្ធរក្ខិតេន ថេរេន" ដូច្នេះវិញទើបគួរ ។

បុដ្ឋោ វិស្សជ្ជេយ្យំ ។

សម្មជ្ជនី បទីបោ ច ឧទកំ អាសនេន ច

ឧបោសថស្ស (១)<br>បវារណាយ } ឯតានិ បុព្វករណន្តិ វុច្ចតិ ។

ឧកាស ! សម្មជ្ជនី ? សម្មជ្ជនករណញ្ច ។ បទីបោ ច ? បទីបុជ្ជលនញ្ច (ឥទានិ សុរិយាលោកស្ស អត្ថិតាយ(២) បទីបកិច្ចំ នត្ថិ) ។ ឧទកំ អាសនេន ច ? អាសនេន សហ បានីយបរិភោជនីយឧទកដ្ឋបនញ្ច(៣) ។ ឧបោសថស្ស<br>បវារណាយ } ឯតានិ បុព្វករណន្តិ វុច្ចតិ ? ឯតានិ ចត្តារិ ទត្តានិ សម្មជ្ជនករណាទីនិ សង្ឃសន្និបាតតោ បឋមំ កត្តព្វត្តា,

ឧបោសថស្ស ឧបោសថកម្មស្ស<br>បវារណាយ បវារណាកម្មស្ស } បុព្វករណន្តិ វុច្ចតិ,

---

១ បាលីពីរបន្ទាត់ក្នុងវាក់ខាងលើនេះ បើឧបោសថកម្មត្រូវសូត្រតាមបន្ទាត់ខាងលើ បើបវារណាកម្មត្រូវសូត្រតាមបន្ទាត់ខាងក្រោម, វាក់ដែលមានតទៅមុខទៀតក៏ត្រូវចំណាំដូចគ្នាដែរ ។ ២ បើសង្ឃធ្វើឧបោសថកម្ម (ឬ បវារណាកម្ម) ក្នុងវេលាថ្ងៃត្រូវសូត្រតាមរបៀបខាងលើនេះស្រាប់ហើយ បើធ្វើក្នុងវេលាយប់ ត្រូវផ្លាស់ អត្ថិតាយ ថា នត្ថិតាយ ផ្លាស់ នត្ថិ ថា អត្ថិ ដូច្នេះវិញ ។ ៣ បាលីថា បានីយ-បរិភោជនីយឧដ្ឋបនញ្ច, បានីយបរិភោជនីយបដ្ឋបនញ្ច, បានីយបរិភោជនីយុបដ្ឋបនញ្ច ដូច្នេះក៏មាន ។

បុព្វករណានីតិ អក្ខាតានិ ។

ឆន្ទបារិសុទ្ធិ
ឆន្ទប្បវារណា } ឧតុក្ខានំ ភិក្ខុគណនា ច ឱវាទោ

ឧបោសថស្ស
បវារណាយ } ឯតានិ បុព្វកិច្ចានិ វុច្ចតិ ។

ឆន្ទបារិសុទ្ធិ ?
ឆន្ទប្បវារណា ? } ឆន្ទារហានំ ភិក្ខូនំ

ឆន្ទបារិសុទ្ធិ អាហរណញ្ច
ឆន្ទប្បវារណាហរណញ្ច } (ឥធ នត្ថិ)(១) ។

ឧតុក្ខានំ ។ ហេមន្តាទីនំ តិណ្ណំ ឧតូនំ ឯត្តកំ អតិក្កន្តំ ឯត្តកំ អវសិដ្ឋន្តិ ឯវំ ឧតុអាចិក្ខនំ; ឧតូនីធ បន សាសនេ ហេមន្តគិម្ហវស្សានានំ វសេន តីណិ ហោន្តិ; (អយំ ហេមន្តឧតុ, អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, ឆ ឧបោសថា អវសិដ្ឋា)(២)។ ភិក្ខុគណនា ច ។

១ បើមានភិក្ខុនាំឆន្ទៈបារិសុទ្ធិមក ត្រូវសូត្រថា "ឥធ អត្ថិ"។ ២បាលីថា អយំ ។បេ។ អវសិដ្ឋា នៅក្នុងខ្សែសញ្ញាខាងលើនេះ នឹងមានសេចក្ដីពន្យល់ក្នុងទំព័រខាងមុខផ្សេងដោយឡែកទៀត ។

តស្មិំ ឧបោសថគ្គេ / បវារណគ្គេ } សន្និបតិតានំ ភិក្ខូនំ គណនា (ឯត្តកា)(១) ភិក្ខូ ហោន្តិ ។ ឱវាទោ ។ ភិក្ខុនីនំ ឱវាទោ នាគច្ឆោ, (ឥទានិ បន តាសំ នត្ថិតាយ, សោ ច ឱវាទោ ឥធ នត្ថិ) ។

ឧបោសថស្ស / បវារណាយ } ឯតានិ បុព្វកិច្ចន្តិ វុច្ចតិ ។ ឯតានិ

បញ្ច កម្មានិ ឆន្ទាហរណាទីនិ បាតិមោក្ខុទ្ទេសតោ / ឆន្ទប្បវារណាហរណាទីនិ ញត្តិយា ឋបនតោ

បឋមំ កត្តព្វត្តា, ឧបោសថស្ស ឧបោសថកម្មស្ស / បវារណាយ បវារណាកម្មស្ស } បុព្វកិច្ចន្តិ វុច្ចតិ, បុព្វកិច្ចានីតិ អត្ថាតានិ ។

ឧបោសថោ / បវារណា } យាវតិកា ច ភិក្ខូ កម្មប្បត្តា សភាគាបត្តិយោ ច ន វិជ្ជន្តិ, វជ្ជនីយា ច បុគ្គលា តស្មិំ ន ហោន្តិ, បត្តកល្លន្តិ វុច្ចតិ ។

១ ត្រូវប្រាប់ចំនួនភិក្ខុដែលមកប្រជុំ ។

ឧបោសថោ ? / បវារណា ? } តីសុ { ឧបោសថទិវសេសុ / បវារណាទិវសេសុ } ចាតុទ្ទសី

បណ្ណរសី សាមគ្គីសុ { អជ្ជុបោសថោ (បណ្ណរសោ)(១) / អជ្ជ បវារណា បណ្ណរសី } ។ យា.

ទតិកា ច ភិក្ខូ កម្មប្បត្តា ? យត្តកា ភិក្ខូ តស្ស

ឧបោសថកម្មស្ស / បវារណាកម្មស្ស } បត្តា យុត្តា អនុរូបា, សព្វន្តិមេន

បរិច្ឆេទេន { ចត្តារោ / បញ្ច } ភិក្ខូ បកតត្តា សង្ឃេន អប្បដិក្ខិត្តា,

តេ ច ខោ ហត្ថបាសំ អវិជហិត្វា ឯកសីមាយំ ឋិតា ។
សភាគាបត្តិយោ ច ន វិជ្ជន្តិ ? វិកាលភោជនាទិវត្ថុ-
សភាគាបត្តិយោ ច ន វិជ្ជន្តិ ។ វជ្ជនីយា ច បុគ្គលា
តស្មឹ ន ហោន្តិ ? គហដ្ឋបណ្ឌកាទយោ ឯកវីសតិ
វជ្ជនីយបុគ្គលា, ហត្ថបាសតោ ពហិករណវសេន វជ្ជេ-
តព្វា, តស្មឹ ន ហោន្តិ ។ បត្តកល្លន្តិ វុច្ចតិ ? សង្ឃស្ស

ឧបោសថកម្មំ / បវារណាកម្មំ } ឥមេហិ ចតូហិ លក្ខណេហិ សង្គហិតំ,

---

១ ឧបោសថកម្មក្នុងថ្ងៃទី ១៤ ត្រូវសូត្រថា "ចាតុទ្ទសោ" ។

បត្តកល្លន្តិ វុច្ចតិ, បត្តកាលទន្តិ អក្ខាតំ ។ បុព្វករណ-បុព្វកិច្ចានិ សមាបេត្វា, ទេសិតាបត្តិកស្ស សមគ្គស្ស ភិក្ខុសង្ឃស្ស អនុមតិយា { បាតិមោក្ខំ ឧទ្ទិសិតុំ / ញត្តិ ឋបេតុំ } អារាធនំ(១) ករោមិ ។

បុព្វករណ៍ និង បុព្វកិច្ច ចប់

១ បាលីថា ''អជ្ឈេសនំ,, ដូច្នេះក៏មាន ។

# សេចក្ដីពន្យល់

ត្រង់បាលីថា **អយំ ។ល។ អវសិដ្ឋា** ដូច្នេះនៅក្នុងខទសញ្ញាខាងដើមនោះ គឺប្រាប់ឈ្មោះរដូវ និងចំនួនឧបោសថក្នុងរដូវមួយៗ ឲ្យដឹងថា ឥឡូវនេះនៅក្នុងរដូវណា? ដល់ឧបោសថទីប៉ុន្មាន? ឧបោសថកន្លងទៅប៉ុន្មានហើយ? នៅសល់ប៉ុន្មានទៀត? ក្នុងរដូវមួយៗ ឧបោសថត្រូវចំនួនប៉ុណ្ណោះហើយឬ ។

ឯរដូវដែលនិយមប្រើក្នុងពុទ្ធសាសនានេះមាន ៣ យ៉ាងគឺ ហេមន្តរដូវ១ គិម្ហរដូវ១ វស្សានរដូវ១ អ្នកសិក្សាគប្បីរាប់ចំនួនឧបោសថ កំណត់តាមរដូវទាំង៣នេះឯង ។

## ចំនួនឧបោសថក្នុងរដូវទាំង ៣

១. ហេមន្តរដូវមាន ៤ ខែ រាប់ពីត្រឹមថ្ងៃ ១ រោចខែកត្តិក ដល់ថ្ងៃ ១៥ កើតខែផល្គុន មានឧបោសថ ៨ គឺ

ឧបោសថទី ១ ត្រង់ថ្ងៃ ១៥ រោចខែកត្តិកត្រូវសូត្រ(១) ថា ( **អយំ ហេមន្តឧតុ. អស្មឹ ឧតុម្ហិ អដ្ឋ ឧបោសថា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, នត្ថិ ឧបោសថោ អតិក្កន្តោ, សត្ត ឧបោសថា អវសិដ្ឋា** ) ។

---

១ពាក្យថា សូត្រនិងសូធ្យ, សូត្រនេះ(វចនានុក្រមខ្មែរ), សូធ្យនេះ (កល្យាណមិត្តរបស់ខ្ញុំ) ។

ឧបោសថទី ២ ត្រង់ថ្ងៃ ១៥ កើតខែមិគសិរ ត្រូវសូត្រថា

( អយំ ។ល។ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, ន ឧបោសថា អវសិដ្ឋា ) ។

ឧបោសថទី ៣ ត្រង់ថ្ងៃ ១៤ កេចខែមិគសិរ ត្រូវសូត្រថា

( អយំ ។ល។ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, បញ្ច ឧបោសថា អវសិដ្ឋា ) ។

ឧបោសថទី៤ ត្រង់ថ្ងៃ ១៥កើតខែបុស្ស ត្រូវសូត្រថា

( អយំ ។ល។ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា. ចត្តារោ ឧបោសថា អវសិដ្ឋា ) ។

ឧបោសថទី ៥ ត្រង់ថ្ងៃ ១៥កេចខែបុស្ស ត្រូវសូត្រថា

( អយំ ។ល។ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, តយោ ឧបោសថា អវសិដ្ឋា)។

ឧបោសថទី ៦ ត្រង់ថ្ងៃ ១៥កើតខែមាឃ ត្រូវសូត្រថា

( អយំ ។ល។ សម្បត្តោ, បញ្ច ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា ) ។

ឧបោសថទី ៧ ត្រង់ថ្ងៃ ១៤កេចខែមាឃ ត្រូវសូត្រថា

( អយំ ។ល។ សម្បត្តោ, ឆ ឧបោសថា អតិក្កន្តា,

ឯកោ ឧបោសថោ អទសិដ្ឋោ ) ។

*ឧបោសថទី ៨ ត្រង់ថ្ងៃ ១៥ កើតខែផល្គុន ត្រូវសូត្រថា*

( អយំ ។ល។ សម្បត្តោ, សត្ត ឧបោសថា អតិក្កន្តា អដ្ឋ ឧបោសថា បរិបុណ្ណា ) ។

ឧបោសថ ៨ ក្នុងហេមន្តរដូវ ចប់

៦–គិម្ហរដូវ តាមប្រក្រតីដែលមិនមានអធិកមាសទេ មាន៤ខែ គឺ ពីថ្ងៃ ១រោចខែផល្គុន ដល់ថ្ងៃ ១៥កើតខែអាសាឍ មានឧបោសថ ៨ គឺឧបោសថទី ១ ត្រង់ថ្ងៃ១៥រោចខែផល្គុន, ទី២ ត្រង់ថ្ងៃ១៥កើតខែចេត្រ, ទី៣ត្រង់ថ្ងៃ១៤រោចខែចេត្រ, ទី៤ត្រង់ថ្ងៃ១៥កើតខែពិសាខ, ទី៥ត្រង់ថ្ងៃ១៥រោចខែពិសាខ, ទី៦ត្រង់ថ្ងៃ១៥កើតខែជេស្ឋ, ទី៧ត្រង់ថ្ងៃ១៤រោចខែជេស្ឋ ឬ១៥រោចខែជេស្ឋ បើឆ្នាំដែលមានអធិកវារៈលើកថ្ងៃ១ថ្ងៃ, ទី៨ ត្រង់ថ្ងៃ១៥កើតខែអាសាឍ ។

ឧបោសថទាំង៨ ក្នុងគិម្ហរដូវជាប្រក្រតីនេះ មានរបៀបសូត្រដូចគ្នានឹងឧបោសថ ៨ ក្នុងហេមន្តរដូវដែរ ប្លែកគ្នាតែឈ្មោះរដូវប៉ុណ្ណោះ ក្រៅពីនេះដូចគ្នាទាំងអស់ ឥតមានប្លែកគ្នាទេ ។

បើឆ្នាំដែលមានអធិកមាស គិម្ហរដូវមាន៥ខែ រាប់ពីថ្ងៃ១រោចខែផល្គុន ដល់ថ្ងៃ១៥កើតខែទុតិយាសាឍមានឧបោសថ១០ គឺ

ឧបោសថទី១ ត្រង់ថ្ងៃ១៥រោចខែផល្គុន ត្រូវសូត្រថា

(អយំ គិម្ហឧតុ, អស្មឹ ឧតុម្ហិ បកតិវសេន អដ្ឋ ឧបោសថា អធិកមាសវសេន ទស ឧបោសថា, ឥមស្មឹ បន ឧតុម្ហិ អធិកមាសោ ភវិស្សតិ, តស្មា ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, នត្ថិ ឧបោសថោ

អតិក្កន្តោ, នវ ឧបោសថា អវសិដ្ឋា) ។

*ឧបោសថទី៦ ត្រង់ថ្ងៃ១៥កើតខែចេត្រ ត្រូវសូត្រថា*

(អយំ គិម្ហឧតុ, អស្មិំ ឧតុម្ហិ បកតិវសេន. អដ្ឋ ឧបោសថា, អធិកមាសវសេន នវ ឧបោសថា តស្មិំ បន សំវច្ឆរេ (១) អធិកមាសោ អត្ថិ (២), តស្មា តមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, អដ្ឋ ឧបោសថា អវសិដ្ឋា) ។

*ឧបោសថទី៧ ត្រង់ថ្ងៃ១៤រោចខែចេត្រ ត្រូវសូត្រថា*

(អយំ ។ល។ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, សត្ត ឧបោសថា អវសិដ្ឋា) ។

*ឧបោសថទី៨ ត្រង់ថ្ងៃ១៥កើតខែពិសាខ ត្រូវសូត្រថា*

(អយំ ។ល។ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា, ឆ ឧបោសថា អវសិដ្ឋា) ។

---

១ ត្រង់បទថា ‹‹សំវច្ឆរេ និង អត្ថិ,, នេះ ខ្ញុំយល់ឃើញថា បើមិនទាន់ចូលឆ្នាំទេ គុំអាលសូត្រ ឲ្យសូត្រថា ‹‹ឧតុម្ហិ,, ថា ‹‹ភវិស្សតិ,, ដូចឧបោសថទី១ដែរលុះដល់ចូលឆ្នាំហើយសឹមសូត្រថា ‹‹សំវច្ឆរេ,,ថា ‹‹អត្ថិ,, រាល់ថ្ងៃឧបោសថតរៀងដរាបដល់ផុតគិម្ហរដូវ ព្រោះការចូលឆ្នាំនោះមិនទៀងទេ ចូលក្នុងខ្នើតខែចេត្រក៏មានចូលក្នុងរនោចឬផុនហួសដល់ទៅខ្នើតខែពិសាខទើបចូលឆ្នាំក៏បានដែរ ដំណើរនេះសូមលោកអ្នកបណ្ឌិតឈ្លាសវៃរិលលកតាមសមគួរដល់សេចក្តីពេញព្រះហឫទ័យចុះ ។

ឧបោសថទី៥ ត្រង់ថ្ងៃ១៥កើតខែពិសាខ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, បញ្ច ឧបោសថា អវសិដ្ឋា)។

ឧបោសថទី៦ ត្រង់ថ្ងៃ១៥កើតខែជេស្ឋ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, បញ្ច ឧបោសថា អតិក្កន្តា, ចត្តារោ ឧបោសថា អវសិដ្ឋា) ។

ឧបោសថទី៧ ត្រង់ថ្ងៃ១៤រោចខែជេស្ឋ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, ឆ ឧបោសថា អតិក្កន្តា, តយោ ឧបោសថា អវសិដ្ឋា) ។

ឧបោសថទី៨ ត្រង់ថ្ងៃ១៥កើតខែបឋមាសាឍ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, សត្ត ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា) ។

ឧបោសថទី៩ ត្រង់ថ្ងៃ១៥រោចខែបឋមាសាឍ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, អដ្ឋ ឧបោសថា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ) ។

ឧបោសថទី១០ ត្រង់ថ្ងៃ១៥កើតខែទុតិយាសាឍ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, នវ ឧបោសថា អតិក្កន្តា, ឧស

ឧបោសថា បរិបុណ្ណា) ។

## ឧបោសថ ៨-១០ ក្នុងគិម្ហរដូវ ចប់

៣-រដូវវស្សានមានខែ ៤ គឺ ចាប់ពីថ្ងៃ ១ រោចខែអាសាឍ ឬខែទុតិយាសាឍ ដល់ថ្ងៃ ១៥ កើតខែកត្តិក មានឧបោសថ ៧ ចាវណា ១ គឺ

ឧបោសថទី ១ ត្រង់ថ្ងៃ ១៥ រោចខែអាសាឍ ឬខែទុតិយាសាឍ ត្រូវសូត្រថា

(អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន ឯកោ ឧបោសថោ សម្បត្តោ, នត្ថិ ឧបោសថោ អតិក្កន្តោ, ឆ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ) ។

ឧបោសថទី ២ ត្រង់ថ្ងៃ ១៥ កើតខែស្រាពណ៍ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, ឯកោ ឧបោសថោ អតិក្កន្តោ, បញ្ច ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា ) ។

ឧបោសថទី ៣ ត្រង់ថ្ងៃ ១៤ រោចខែស្រាពណ៍ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, ទ្វេ ឧបោសថា អតិក្កន្តា, ចត្តារោ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា , ។

ឧបោសថទី ៤ ត្រង់ថ្ងៃ ១៥ កើតខែភទ្របទ ត្រូវសូត្រថា

(អយំ ។ល។ សម្បត្តោ, តយោ ឧបោសថា អតិក្កន្តា, តយោ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា) ។

*ឧបោសថទី៤ ត្រង់ថ្ងៃ១៥រោចខែភទ្របទ ត្រូវសូធ្យថា*

(អយំ ។ល។ សម្បត្តោ, ចត្តារោ ឧបោសថា អតិក្កន្តា, ទ្វេ ច ឧបោសថា ឯកា ច បវារណា អវសិដ្ឋា) ។

*បវារណា១ ត្រង់ថ្ងៃ១៥កើតខែអស្សុជ ត្រូវសូធ្យថា*

(អយំ វស្សានឧតុ, អស្មឹ ឧតុម្ហិ សត្ត ច ឧបោសថា ឯកា ច បវារណា, ឥមិនា បក្ខេន បវារណាទិវសោ(១) សម្បត្តោ, បញ្ច ឧបោសថា អតិក្កន្តា, ទ្វេ ឧបោសថា អវសិដ្ឋា) ។

*ឧបោសថទី៦ ត្រង់ថ្ងៃ១៤រោចខែអស្សុជ ត្រូវសូធ្យថា*

(អយំ ។ល។(២) សម្បត្តោ, បញ្ច ច ឧបោសថា ឯកា ច បវារណា អតិក្កន្តា, ឯកោ ឧបោសថោ អវសិដ្ឋោ) ។

*ឧបោសថទី៧ ត្រង់ថ្ងៃ១៥កើតខែកត្តិក ត្រូវសូធ្យថា*

(អយំ ។ល។(៣) សម្បត្តោ, ឆ ច ឧបោសថា ឯកា ច បវា-

---

១ បវារណា. សម្បត្តា ដូច្នេះក៏មាន ។

២-៣ បេយ្យាល នេះ ពុំមែនត្រូវសូធ្យដូចបវារណាទេ គឺត្រូវឲ្យសូធ្យដូចឧបោសថទី១ ក្នុងស្បាទាដូរនេះដែរ ។

រណា អតិក្កន្តា; សត្ត ច ឧបោសថា ឯកា ច បវារណា បរិបុណ្ណា)។

ឧបោសថ៧ បវារណា១ ក្នុងវស្សានរដូវ ចប់
ឧបោសថ:២៣ ឬ២៥ បវារណា១
ក្នុងមួយឆ្នាំ ចប់ ។

កណ្ឌទី ៤ ចប់

## ខណ្ឌទី ៦

### បក្ខគណនា

### ពុទ្ធានុញ្ញាតឱយរៀនរាប់បក្ខ

### ពិធីសូត្ររាប់ពុទ្ធសករាជ

## បក្ខគណនា

## បក្ខគណនាឧគ្គហណានុជាននំ
## ការទ្រង់អនុញ្ញាតឲ្យភិក្ខុរៀនរាប់បក្ខ

*ក្នុងគម្ពីរ វិនយបិដក មហាវគ្គ បឋមភាគ លេខ១៦ក្នុង ឧបោសថ– ក្ខន្ធកៈ ទំព័រ ៣៧៩ ត្រង់បទៈ (១៧៧) មានដំណើរនិទានដើមដាន ដូច្នេះថា*

អថខោ ភគវា ចោទនាវត្ថុស្មឹ យថាភិរន្តំ វិហរិត្វា បុនទេវ រាជគហំ បច្ចាគច្ឆិ ។ *លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងចោទនាវត្ថុ តាមសមគួរដល់ព្រះអធ្យាស្រ័យហើយ ក្រឡប់មកកាន់ក្រុងរាជគ្រឹះវិញទៀត ។*

*ក៏ក្នុងសម័យនោះឯង មនុស្សទាំងឡាយ សួរពួកភិក្ខុដែលកំពុងត្រាច់ទៅបិណ្ឌបាតថា* កតិមី ភន្តេ បក្ខស្ស *បពិត្រលោកដ៏ចម្រើន តិថីនៃបក្ខបានប៉ុន្មានហើយ (គឺប៉ុន្មានកើត ប៉ុន្មានរោចហើយ) ។*

*ភិក្ខុទាំងឡាយបាននិយាយយ៉ាងនេះថា* ន ខោ មយំ អាវុសោ ជានាម *នែអាវុសោ យើងមិនដឹងទេ ។*

*មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល . បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យៈទាំងនេះ ត្រឹមតែរាប់បក្ខ(ប៉ុណ្ណោះ)*

មិនដឹងទៅហើយ ចំណាន់បើការណ៍ណាមួយដទៃទៀត តើម្ដេចពួកសមណៈទាំងនេះនឹងដឹងបាន ។

ភិក្ខុទាំងឡាយ ក្រាបទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។

ព្រះអង្គទ្រង់អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ បក្ខគណនំ ឧគ្គហេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរៀនកប់បក្ខ(១) ។

វេលាភិក្ខុទាំងឡាយ មានសេចក្ដីត្រិះរិះដូច្នេះថា ត្រូវអ្នកណារៀនបក្ខហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។

ព្រះអង្គទ្រង់អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ សព្វេហេវ បក្ខគណនំ ឧគ្គហេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងអស់រៀនកប់បក្ខ ។

ព្រះបរមពុទ្ធានុញ្ញាតខាងលើនេះ ដែលមានមក ព្រោះតែពួកភិក្ខុមិនចេះវិជ្ជាខាងការកប់បក្ខ ហើយមនុស្សទាំងឡាយពោលទោស តិះដៀលបន្តុះបង្អាប់ បានជាព្រះអង្គទ្រង់អនុញ្ញាតឲ្យពួកភិក្ខុទាំងអស់គ្នារៀនកប់បក្ខឲ្យបានចេះដឹងឡើង ។

ពាក្យថា បក្ខប្រែថា „ចំណែក, ផ្នែក, ចំណែកខែ (កន្លះខែ); ពួក, ក្រុម, ជន ។ល។ „ស្រដៀងគ្នានឹងពាក្យថា គណៈដែរ ។

---

១ កន្លះខែមួយៗ ហៅថា បក្ខ មួយៗ ។

# ដំណើររាប់បក្ខ

ដំណើររាប់បក្ខ គឺរាប់ឲ្យដឹងចំណែកថ្ងៃខែខ្នើតរនោច (តាមដំណើរព្រះចន្ទ្រ ឬតាមដំណើរព្រះអាទិត្យ) (១) ។

ថ្ងៃខែដែលកំណត់រាប់តាមដំណើរព្រះចន្ទ្រ ហៅថា ចន្ទគតិ មានខែ១២ឬ១៣ បើក្នុងឆ្នាំដែលមានអធិកមាស ដែលកំណត់រាប់តាមដំណើរព្រះអាទិត្យ ហៅថា សុរិយគតិ មានខែ១២ ។

## ខែ ១២ ឬ ១៣ ខាងចន្ទគតិ

១- មិគសិរ មានថ្ងៃ២៩ ;

២- បុស្ស - ៣០ ;

៣- មាឃ - ២៩ ;

៤- ផល្គុន - ៣០ ;

៥- ចេត្រ - ២៩ ;

៦- ពិសាខ - ៣០ ;

៧- ជេស្ឋ · ២៩ឬ៣០បើឆ្នាំដែលមានអធិកវារៈ ;

៨- អាសាឍ - ៣០ ចួនកាលខែអាសាឍមាន ២ ដង បើឆ្នាំដែលមានអធិកមាស មុនឈ្មោះបឋមាសាឍ ក្រោយឈ្មោះទុតិ-

---

១ វចនានុក្រមខ្មែរភាគ១ ទំព័រ ៥៣០ ។

យាសាឍ មានថ្ងៃ៣០ ដូចគ្នា(ក្នុងឆ្នាំនោះមានខែ១៣) ;

៩ ស្រាពណ៍ មានថ្ងៃ២៩ ;

១០-ភទ្របទ ៣០ ;

១១-អស្សុជ - ២៩ ;

១២ កត្តិក -៣០ ។

បូករួមថ្ងៃទាំងអស់ ក្នុងខែទាំង១២ ឬ១៣ នេះទៅ ត្រូវមានថ្ងៃ ៣៥៤ តាមប្រក្រតី, បើឆ្នាំដែលមានចន្ទ្រាធិមាស (អធិកវារៈ) មានថ្ងៃ ៣៥៥, បើឆ្នាំដែលបានអធិកមាស មានថ្ងៃ ៣៨៤, ត្រូវជាមួយឆ្នាំនៃចន្ទគតិ ។

## ខែ ១២ ខាងសុរិយគតិ

១ មករា មានថ្ងៃ ៣១ ;

២-កុម្ភៈ -២៨ ឬ ២៩ ;

៣-មីនា - ៣១ ;

៤ មេសា - ៣០ ;

៥-ឧសភា - ៣១ ;

៦-មិថុនា - ៣០ ;

៧-កក្កដា - ៣១ ;

៨-សីហា – ៣១ ;

៩-កញ្ញា ៣០ ;

១០-តុលា – ៣១ ;

១១-វិច្ឆិកា – ៣០ ;

១២-ធ្នូ – ៣១ ;

បូកមួយថ្ងៃទាំងអស់ក្នុងខែទាំង ១២ នេះទៅ ត្រូវបានថ្ងៃ ៣៦៥ ឬជួនកាលបានថ្ងៃ ៣៦៦ ត្រូវជាមួយឆ្នាំនៃសុរិយគតិ ។

## សុក្កបក្ខនិងកាឡបក្ខ

ឯខែខាងចន្ទគតិទាំង ១២ ឬ ១៣ នោះ ក្នុងខែមួយៗ ចែកចេញជាពីរចំណែកដូច្នេះគឺ

១-**សុក្កបក្ខ** ចំណែកស, ចែកខាងភ្លឺ គឺខាងខ្នើតជាចំណែកថ្ងៃខាងដើមនៃខែមួយៗ មាន ១៥ ថ្ងៃ ដូចគ្នាគ្រប់ខែទាំងអស់ គឺតាំងពីថ្ងៃ ១ កើតដល់ថ្ងៃ ១៥ កើត កន្លះខែនេះជាបក្ខមួយ ។

២-**កាឡបក្ខ** ចំណែកខ្មៅ, ចែកខាងងងឹត គឺខាងរនោច ជាចំណែកថ្ងៃខាងចុងនៃខែមួយៗ បើខែខ្វះមាន ១៤ ថ្ងៃ បើខែពេញមាន ១៥ថ្ងៃ គឺតាំងពីថ្ងៃ ១ រោច ដល់ថ្ងៃ ១៤ រោច ឬ ១៥ រោច កន្លះខែនេះជាបក្ខមួយ ។

រួមចំណែកថ្ងៃ ក្នុងបក្ខទាំងពីរនេះគឺ សុក្កបក្ខ ១៥ ថ្ងៃ កាឡបក្ខ ១៤ ថ្ងៃ ឬ ១៥ ថ្ងៃ ត្រូវជា ២៩ ថ្ងៃ ឬ ៣០ ថ្ងៃ ពេញជាមួយខែនៃចន្ទគតិ ៗ

ឯខែខាងសុរិយគតិនោះ ពុំមានខែចកចំណែកថ្ងៃប៉ុណ្ណះប៉ុណ្ណោះ តាមបក្ខជាខ្នើតរនោចដូច្នេះទេ គឺគ្រាន់តែកំណត់រាប់ថ្ងៃថា ១ មករា ២ ៣ ៤ ៥ មករា ដូច្នេះជាដើម រៀងរហូតដល់គ្រប់ចំនួនថ្ងៃក្នុងខែមួយ ៗ ខែម្តង ៗ •

## ពុទ្ធសករាជ

ក្នុងដំណើររាប់បក្ខនេះ បើពុទ្ធបរិស័ទពុំទាន់បានចេះស្គាល់ពុទ្ធសករាជ(១) នៅឡើយទេ គួរតែបណ្តុះសទ្ធាជ្រះថ្លាឲ្យកើតមាន ហើយទំយកចិត្តទុកដាក់រៀនពុទ្ធសករាជ ឲ្យបានចេះដឹងឡើង ព្រោះពុទ្ធសករាជមានប្រាប់កំណត់អាយុកាលនៃព្រះពុទ្ធសាសនា ក្នុងកាលជាអតីត អនាគតនិងបច្ចុប្បន្ន ឈ្មោះថ្ងៃ តិថី បក្ខ ខែ រដូវ ព្រមទាំងឆ្នាំ និងស័កផង ដោយសព្វគ្រប់ ត្រូវតាមចំនួននៃព្រះបរមពុទ្ធានុញ្ញាតខាងដើមនោះឯង ៗ •

ពុទ្ធសករាជ គឺចំនួនថ្ងៃខែឆ្នាំ រាប់តាំងពីក្រោយថ្ងៃដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វានទៅបានមួយថ្ងៃរៀងមក(២) ៗ

ព្រះសក្យមុនីគោតមបរមសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ចូលបរិនិព្វាន

---

១ ធ្លាប់ហៅថា បកសករាជ ។ ២ វចនានុក្រមខ្មែរភាគទី ១ ទំព័រ ៧២២ ។

នៅថ្ងៃអង្គារ ១៥ កើតខែពិសាខ ឆ្នាំម្សាញ់; រាប់ពីត្រឹមថ្ងៃ ១ រោចខែពិសាខនោះមកជាពុទ្ធសករាជ ។

ទំនៀមរាប់ពុទ្ធសករាជ ដោយទៀងទាត់របស់ពួកពុទ្ធសាសនិកជននោះ(១) តែងរាប់យកចំណែកខាងរនោចខែមួយមុន ចំះរួមនឹងកើតខែបន្ទាប់នោះជា ១ខែ គឺត្រូវរាប់ពីថ្ងៃ ១ រោចខែពិសាខ មកដល់ថ្ងៃ ១៥កើតខែជេស្ឋជា១ខែ ។ល។ ពីថ្ងៃ ១រោចខែចេត្រ មកដល់ថ្ងៃ១៥កើតខែពិសាខជា១ខែ (ពេញជា១ឆ្នាំ) ត្រូវរាប់យ៉ាងនេះរៀងរាល់ឆ្នាំ, បើរាប់ពីដើមមកដល់ត្រឹមណា ត្រូវទុកថ្ងៃខែឆ្នាំនោះជាបច្ចុប្បន្នកាល មិនទាន់រាប់ពេញថា ជាសករាជដែលកន្លងទៅហើយទេ, ដូចជាកាលពីក្នុងថ្ងៃ ១២ រោចខែស្រាពណ៍ ឆ្នាំមមីបន្ទាប់ពុទ្ធបរិនិព្វានត្រូវរាប់ថា ពុទ្ធសករាជកន្លងទៅហើយបាន១ឆ្នាំ ៣ខែ១៣ថ្ងៃ (កន្លងទៅហើយបានប៉ុន្មាន ត្រូវជាតែត្រឹមប៉ុណ្ណោះ); តែបើប្រើខាងការសរសេរសំបុត្របុគហ្មាយ, ក្តក្រាបុះក្នុងគម្ពីរក្បួនច្បាប់ទាំងពួង ឬ និយាយស្តីប្រាប់គ្នាតាមធម្មតានោះ ត្រូវរាប់ចេញចំនួនសករាជយកត្រឹមឆ្នាំមមី ដែលចូលក្នុងរវាងឆ្នាំគម្រប់ ២ ម្ល៉ះឯងថា ពុទ្ធសករាជ២ឆ្នាំ ឬពុទ្ធសករាជ២; (ពុទ្ធសករាជនេះគឺជាបច្ចុប្បន្នកាល ពុំមែនជាអតីតកាលដែលត្រូវរាប់ថាកន្លងទៅហើយនោះទេ)។

---

១ វចនានុក្រមខ្មែរថា សម្រាប់ប្រើខាងរបៀបទេស្នា ។

## ពិធីសូត្ររាប់ពុទ្ធសករាជ

ព្រះពុទ្ធសករាជ ឈ្មោះថា ជាថ្នាដ៏សំខាន់មួយមុខខាងការកេចបត្ត ប្រាប់ឲ្យដឹងកំណត់កាល, សម័យ ឬ យុគ គឺប្រាប់ឲ្យស្គាល់ឈ្មោះថ្ងៃ ៧, តិថី១៥ ឬ ១៤, បក្ខ ២, ខែ ១២ ឬ១៣, រដូវ ៣, ឆ្នាំ ១២ ជាដើម ដោយច្បាស់លាស់ មានរបៀបសូត្ររាប់ដ៏ត្រឹមត្រូវឲ្យត្រេកអរចាប់ចិត្ត ចាប់អារម្មណ៍ កាលបើលោកអ្នកបានចាប់ផ្ដើមសូត្រឡើង ឮសូរពិរោះ គួរឲ្យចាប់ក្ដុកនឹកសង្វេគជ្រះថ្លាដល់កាលជាទីបរិនិព្វាន នៃព្រះសម្មាសម្ពុទ្ធ ជាបរមគ្រូរបស់យើងទាំងឡាយនោះមែនពិត ។

ឯពិធីសូត្ររាប់ពុទ្ធសករាជនោះ លោកអ្នកប្រាជ្ញទាំងឡាយពីបុរាណ បានរៀបរៀងបាលីទុកមក ជាពីរសង្កាត់ដូច្នេះគឺ សង្កាត់ទី ១ សម្រាប់សូត្រប្រាប់ឲ្យដឹងកំណត់កាលថ្ងៃខែឆ្នាំជាដើមនៃពុទ្ធបរិនិព្វាន; សង្កាត់ទី២ សម្រាប់សូត្ររាប់ចំនួនថ្ងៃ ខែ ឆ្នាំ ជាដើម តាំងពីក្រោយថ្ងៃនៃពុទ្ធបរិនិព្វាន នោះ តរៀងដរាបមកដល់កាលសព្វថ្ងៃនេះឯង ។

### បាលីសម្រាប់សូត្រ សង្កាត់ទី១

ឧភាស សិរីសក្យមុនីសព្វញ្ញុពុទ្ធស្ស ពលទប្បច្ចស-
សមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ
សប្បសំវច្ឆរេ គិម្ហឧតុម្ហិ វិសាខមាសេ សុក្កបក្ខេ

បណ្ណរសិយា តិថិយំ កុម្ភវារេ កុម្ភយាមេ អនុរាធ-នក្ខត្តិធិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា (១) ។

ខ្ញុំសូមគោរព សម្ដេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាល-ព្រឹក្សទាំងគូ(១) ជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យជំហានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាកំពីរពេញបូណ៌មីខានខែវិសាខ ក្នុងគម្រប់ឆ្នាំ ម្សាញ់ឯណោះ ហោង ។

## បាលីសម្រាប់សូត្រ សង្កាត់ ទី ២

### ប្រាប់កាល ៣ គឺ អតីតកាល១បច្ចុប្បន្នកាល ១ អនាគតកាល១

### អតីតកាល

ភស្ស ភគវតោ សម្មាសម្ពុទ្ធស្ស បរិនិព្វុតនិទ-

---

១. សត្តបរិត្ត ; ទ្វាទសបរិត្ត និងភាណវារៈ ។

២ សាលព្រឹក្សទាំងគូនេះ ជាសាលវនឧទ្យានរបស់ពួកមល្លក្សត្រ (មហាបរិនិព្វានសូត្រ) ។ ៣ ពាក្យដែលមានគំនូសខាងក្រោម ... ដូច្នេះទាំងប៉ុន្មានគប្បីចំណាំថាត្រូវផ្លាស់ចេញ ហើយដាក់ពាក្យថ្មីចូលមកវិញ (បានពន្យល់ក្នុងទំព័រខាងមុខដោយឡែកទៀត) ។

សគោ បញ្ចាយ យាទជូត្តនា

អដ្ឋទី(២)សតិ និទសុត្តរ ឯកាឧសមាសាធិក តេរស-
សំវច្ឆរុត្តរបញ្ចសតាធិកានិ ទ្វេ សំវច្ឆរសហស្សានិ
អតិក្កន្តានិ អហេសុំ ។

*តំគកប់តាប់ដើមតាំងអំពីថ្ងៃ ដែលព្រះសម្មាសម្ពុទ្ធមានព្រះភាគព្រះ
អង្គនោះទ្រង់ចូលបរិនិព្វានទៅ រៀងដកបមកដល់ថ្ងៃនេះ ព្រះពុទ្ធសករាជ
ព្រះសាសនា អតិក្កន្តានិ កន្លងទៅហើយបានចំនួន ២ ពាន់ ៥ រយ
១៣ ឆ្នាំ និង ១១ ខែ ២៨ ថ្ងៃ ។*

បច្ចុប្បន្នកាល

តស្មឹ បច្ចុប្បន្នកាលេ សូករសំវច្ឆរេ គិម្ហឧតុម្ហិ
វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ រវិវារេ។

*ក្នុងកាលបច្ចុប្បន្ននេះ គឺថ្ងៃ អាទិត្យ ជា តិថីទី ១៥ ចំណែក
ខាង ខ្នើត (គឺថ្ងៃ ១៥ កើត) ខែ ពិសាខ ក្នុង គិម្ហ រដូវ ឆ្នាំ
កុរ ត្រីស័ក ។* (១)

---

១ ចំណែកបច្ចុប្បន្នកាលនេះ ខ្ញុំប្រាប់ឈ្មោះថ្ងៃចេញមុន ហើយរាប់តិថីបក្ខ ខែ រដូវ ឆ្នាំ ស័កជាលំដាប់តមកដូច្នេះ ដើម្បីឲ្យត្រូវស្របតាមបាលីក្នុងសង្កាត់ទី ១ ដែលលោកប្រាប់ឈ្មោះថ្ងៃចេញមុននោះដែរ ។

## អនាគតកាល

អនាគតេ កាលេ នត្ថិ[១] ទិវសុត្តរំ នត្ថិ[២] មាសាធិកំ ឆអសីតិ សំវច្ឆរុត្តរំ ចតុសតាធិកានិ ទ្វេ សំវច្ឆរសហស្សានិ អវសេសានិ ភវិស្សន្តិ ។

ក្នុងកាលជាអនាគត ព្រះពុទ្ធសករាជព្រះសាសនា អវសេសានិ នៅមានសេសសល់ចំនួន ២ ពាន់ ៤ រយ ៨៦ ឆ្នាំ ខែ[៣] ពុំមានសល់ ថ្ងៃ[៣] ពុំមានសល់ទៀតទេ ។

សរុប រួបរួមថ្ងៃ ខែ ឆ្នាំ ទាំង ៣ កាលគឺ អតីតកាល ១ បច្ចុប្បន្នកាល ១ អនាគតកាល ១ ផ្សំបូកចូលគ្នាទៅត្រូវជា ព្រះពុទ្ធសករាជព្រះសាសនាយុកាលគ្រប់គ្រាន់ជា ៥០០០ វស្សា ដោយបរិបូណ៌ហោង ។

ពិធីត្រស្ងូត្ររាប់ពុទ្ធសករាជចប់ ។

---

១-២ ពាក្យថា នត្ថិ នេះគួរបានជាប្រយោគមួយផ្សេងថា នត្ថិ ទិវសោ អវសេសោ; នត្ថិ មាសោ អវសេសោ; ឬបើអតីតកាលថា នត្ថិ ទិវសោ អតិក្កន្តោ: នត្ថិ មាសោ អតិក្កន្តោ: ដូច្នេះ ឧទាហរណ៍ដូចបុព្វកិច្ចនៃឧបោសថកម្មថា នត្ថិ ឧបោសថោ អតិក្កន្តោ ដូច្នេះនោះដែរ ប៉ុន្តែពីដើមមកលោកពុំដែលស្ងូត្រដូច្នោះទេ ។ ៣- បើស្ងូត្រថា ខែនិងថ្ងៃពុំមានសល់ទៀតទេ ដូច្នេះក៏បានដែរ ។

## សំខ្យាស័ព្ទសម្រាប់ផ្លាស់ថ្ងៃខែឆ្នាំ

### បកតិសំខ្យា(១)

| ស័ព្ទបាឡី | ស័ព្ទប្រែ | ស័ព្ទបាឡី | ស័ព្ទប្រែ |
|---|---|---|---|
| ឯក | ១ | បណ្ណរស | ១៥ |
| ទ្វិ | ២ | សោឡស | ១៦ |
| តិ | ៣ | សត្តរស | ១៧ |
| ចតុ | ៤ | អដ្ឋារស | ១៨ |
| បញ្ច | ៥ | ឯកូនវីសតិ | ១៩ |
| ឆ | ៦ | វីសតិ | ២០ |
| សត្ត | ៧ | ឯកវីសតិ | ២១ |
| អដ្ឋ | ៨ | ទ្វាវីសតិ | ២២ |
| នវ | ៩ | តេវីសតិ | ២៣ |
| ទស | ១០ | ចតុវីសតិ | ២៤ |
| ឯកាទស | ១១ | បញ្ចវីសតិ | ២៥ |
| ទ្វាទស | ១២ | ឆព្វីសតិ | ២៦ |
| តេរស | ១៣ | សត្តវីសតិ | ២៧ |
| ចតុទ្ទស | ១៤ | អដ្ឋវីសតិ | ២៨ |

១ បកតិសង្ខ្យាមានច្រើនរហូតដល់ អសង្ខេយ្យជាទីបំផុត ក្នុងទីនេះស្រង់យកតែត្រឹម ១០០ ប៉ុណ្ណោះ ។

## បកតិសំខ្យា

| ស័ព្ទបាឡី | ស័ព្ទប្រែ | ស័ព្ទបាឡី | ស័ព្ទប្រែ |
|---|---|---|---|
| ឯកូនតឹសតិ | ២៩ | ឆចត្តាឡីស | ៤៦ |
| តឹសតិ | ៣០ | សត្តចត្តាឡីស | ៤៧ |
| ឯកតឹសតិ | ៣១ | អដ្ឋចត្តាឡីស | ៤៨ |
| ទ្វតឹសតិ | ៣២ | ឯកូនបញ្ញាស | ៤៩ |
| តេតឹសតិ | ៣៣ | បញ្ញាស | ៥០ |
| ចតុតឹសតិ | ៣៤ | ឯកបញ្ញាស | ៥១ |
| បញ្ចតឹសតិ | ៣៥ | ទ្វេបញ្ញាស | ៥២ |
| ឆតឹសតិ | ៣៦ | តេបញ្ញាស | ៥៣ |
| សត្តតឹសតិ | ៣៧ | ចតុបញ្ញាស | ៥៤ |
| អដ្ឋតឹសតិ | ៣៨ | បញ្ចបញ្ញាស | ៥៥ |
| ឯកូនចត្តាឡីស | ៣៩ | ឆបញ្ញាស | ៥៦ |
| ចត្តាឡីស | ៤០ | សត្តបញ្ញាស | ៥៧ |
| ឯកចត្តាឡីស | ៤១ | អដ្ឋបញ្ញាស | ៥៨ |
| ទ្វេចត្តាឡីស | ៤២ | ឯកូនសដ្ឋី | ៥៩ |
| តេចត្តាឡីស | ៤៣ | សដ្ឋី | ៦០ |
| ចតុចត្តាឡីស | ៤៤ | ឯកសដ្ឋី | ៦១ |
| បញ្ចចត្តាឡីស | ៤៥ | ទ្វេសដ្ឋី | ៦២ |

## បកតិសំខ្យា

| ពាក្យបាលី | ពាក្យប្រែ | ពាក្យបាលី | ពាក្យប្រែ |
|---|---|---|---|
| តេសដ្ឋី | ៦៣ | អសីតិ | ៨០ |
| ចតុសដ្ឋី | ៦៤ | ឯកអសីតិ | ៨១ |
| បញ្ចសដ្ឋី | ៦៥ | ទ្វេអសីតិ | ៨២ |
| ឆសដ្ឋី | ៦៦ | តេអសីតិ | ៨៣ |
| សត្តសដ្ឋី | ៦៧ | ចតុអសីតិ | ៨៤ |
| អដ្ឋសដ្ឋី | ៦៨ | បញ្ចអសីតិ | ៨៥ |
| ឯកូនសត្តតិ | ៦៩ | ឆអសីតិ | ៨៦ |
| សត្តតិ | ៧០ | សត្តអសីតិ | ៨៧ |
| ឯកសត្តតិ | ៧១ | អដ្ឋអសីតិ | ៨៨ |
| ទ្វេសត្តតិ | ៧២ | ឯកូននវុតិ | ៨៩ |
| តេសត្តតិ | ៧៣ | នវុតិ | ៩០ |
| ចតុសត្តតិ | ៧៤ | ឯកនវុតិ | ៩១ |
| បញ្ចសត្តតិ | ៧៥ | ទ្វេនវុតិ | ៩២ |
| ឆសត្តតិ | ៧៦ | តេនវុតិ | ៩៣ |
| សត្តសត្តតិ | ៧៧ | ចតុនវុតិ | ៩៤ |
| អដ្ឋសត្តតិ | ៧៨ | បញ្ចនវុតិ | ៩៥ |
| ឯកូនអសីតិ | ៧៩ | ឆនវុតិ | ៩៦ |

បកតិសំខ្យា

| សព្ទបាឡី | សព្ទប្រែ | សព្ទបាឡី | សព្ទប្រែ |
|---|---|---|---|
| សត្តនវុតិ | ៩៧ | ឯកូនសតំ | ៩៩ |
| អដ្ឋនវុតិ | ៩៨ | សតំ | ១០០ |

បកតិសំខ្យាត្រឹម ១០០ ចប់ដោយសង្ខេប ។

## សេចក្ដីពន្យល់អំពីរបៀបផ្លាស់ថ្ងៃខែឆ្នាំ

*សំខ្យាសព្ទទាំងអស់នេះ សម្រាប់ផ្លាស់ចំនួនថ្ងៃខែឆ្នាំ បើថ្ងៃខែឆ្នាំដែលកន្លងទៅ ឬដែលសល់នៅចំនួនប៉ុន្មាន ត្រូវរើសរកសំខ្យាចំនួនប៉ុណ្ណោះ យកទៅផ្លាស់ ត្រង់ពាក្យដែលមានគូសបន្ទាត់ខាងក្រោម.... ដូច្នេះនោះចុះ ។ សំខ្យា ក្នុងចំនួនមួយៗ មានច្រើនសព្ទក៏មាន ដូចត្រង់ចំនួន ១១ ឯការស, ឯកាទស; ចំនួន ១៤ ថា ចតុទ្ទស, ចុទ្ទស, ចោទ្ទស; ចំនួន ១៩ ថា ឯកូនវីស, ឩនវីស, ឯកូនវីសតិ, ឩនវីសតិ; ដូច្នេះជាដើម ។*

*ឯសំខ្យាដែលខ្ញុំសរសេរមកនេះ ក្នុងចំនួនមួយ ១ ស្រង់យកតែ ១ សព្ទ ១ ហើយសរសេរត្រឹមតែ ១០០ ប៉ុណ្ណោះ ។ អ្នកសិក្សា បើបានរៀនចេះចាំសំខ្យាត្រឹមប៉ុណ្ណោះ ក៏អាចនឹងផ្លាស់ចំនួនថ្ងៃខែឆ្នាំ ក្នុងការសូត្រកប់ពុទ្ធសករាជនោះបានហើយ ។*

*ក្នុងអតីតកាល ថ្ងៃដែលកន្លងទៅ ត្រូវផ្លាស់មួយអង្គ ១ រៀង*

រាល់ថ្ងៃ ក្នុងខែមួយ ១ ( មួយថ្ងៃផ្លាស់មួយ ) ។

ខែដែលកន្លងទៅ ត្រូវផ្លាស់មួយម្តង ១ រៀងរាល់ខែ ក្នុងឆ្នាំមួយ ១ ( មួយខែផ្លាស់មួយ ) ។

ឆ្នាំដែលកន្លងទៅ ត្រូវផ្លាស់មួយម្តង ១ រៀងរាល់ឆ្នាំ ត្រង់ ខ្ទង់រាយ សំរាប់ឆ្នាំគត់ ( មួយឆ្នាំផ្លាស់មួយម្តង ) ត្រង់ បញ្ចូលគាត់គាន ( ១០០ ឆ្នាំទើបផ្លាស់មួយម្តង ) ត្រង់ ខ្ទង់ សំរាប់សហស្សាទិ ( ១០០០ ឆ្នាំទើបផ្លាស់មួយម្តង ) ។

របៀបផ្លាស់ ថ្ងៃខែឆ្នាំ ខាងអនាគតកាល ដូចគ្នានឹងអតីតកាលដែរ ប៉ុន្តែអតីតកាលផ្លាស់បន្ថែមឲ្យច្រើនឡើង គឺឲ្យច្រើនខាងកន្លងទៅ, ឯអនាគតកាល ផ្លាស់បន្ថយឲ្យតិចចុះ គឺឲ្យតិចខាងសល់នៅប៉ុណ្ណោះ ព្រោះហេតុនោះ មិនបាច់និយាយពន្យល់ទៀតទេ ។

ត្រង់ថ្ងៃ ១៥ កើត ខែ ពិសាខ ជាថ្ងៃចុងបំផុតជាប់ឆ្នាំពុទ្ធសករាជ មួយ ១, ក្នុងអនាគតកាលត្រូវបញ្ចូលពាក្យថា នត្ថិ ទិវសគ្គ នត្ថិ មាសាធិក ដូច្នេះ ព្រោះថ្ងៃនិងខែឥតមានសល់នៅទៀតទេ ។

ត្រង់ថ្ងៃ ១ រោចខែពិសាខ ជាថ្ងៃមុនដំបូងបំផុត នៃឆ្នាំពុទ្ធសករាជ មួយ ១, ក្នុងអតីតកាល ត្រូវបញ្ចូលពាក្យថា នត្ថិ ទិវសគ្គ នត្ថិ មាសាធិក ដូច្នេះដែរ ព្រោះថ្ងៃនិងខែមិនទាន់កន្លងទៅនៅឡើយទេ ។

ឯពាក្យ នត្ថិ នេះ នៅមានត្រូវប្រើក្នុងថ្ងៃឯទៀតក្រៅពីថ្ងៃ ១៤ កើត និងថ្ងៃ១រោចខែពិសាខនេះខ្លះដែរ អ្នកសិក្សាគប្បីពិចារណាមើលឲ្យបានត្រឹមត្រូវល្អផងចុះ ។

បច្ចុប្បន្នកាល

ឈ្មោះឆ្នាំ ១២៖

១- មូសិកសំវច្ឆរ ឆ្នាំ ជូត;
២ ឧសភ – – ឆ្លូវ;
៣- ព្យគ្ឃ – – ខាល;
៤- សស – – ថោះ;
៥- នាគ – – រោង;
៦- សប្ប – – ម្សាញ់;
៧- អស្ស – – មមី;
៨- ឯឡក – – មមែ;
៩- កបិ(១) – – វក;
១០ កុក្កុដ – – រកា;
១១-សោណ- – ច;
១២- សូករ សំវច្ឆរ ឆ្នាំ កុរ ។

១— ថា បក្កដ ដូច្នេះក៏មាន ។

ឆ្នាំទាំង ១២ នេះសម្រាប់ផ្លាស់គ្រង់ពាក្យថា គត្រូករសំវច្ឆរេ ត្រូវផ្លាស់វៀនកល់ឆ្នាំ ( មួយឆ្នាំផ្លាស់មួយ ) ។

## ឈ្មោះរដូវ ៣

១. ហេមន្ត រដូវមានទឹកសន្សើម ឬ រដូវរងារ មាន ៤ ខែ រាប់ពីត្រឹមថ្ងៃ ១ រោច ខែ កត្តិក ដល់ថ្ងៃ ១៥ កើត ខែ ផល្គុន;

២– គិម្ហ រដូវក្តៅ តាមប្រក្រតីដែលមិនមានអធិកមាសទេ មាន ៤ ខែ រាប់ពីត្រឹមថ្ងៃ ១ រោច ខែផល្គុន ដល់ថ្ងៃ ១៥ កើត ខែអាសាឍ, បើឆ្នាំដែលមានអធិកមាស គិម្ហរដូវ មាន ៥ ខែ រាប់ពីត្រឹមថ្ងៃ ១ រោច ខែផល្គុន ដល់ថ្ងៃ ១៥ កើត ខែទុតិយាសាឍ;

៣– វស្សាន រដូវភ្លៀង មាន ៤ ខែ រាប់ពីត្រឹមថ្ងៃ ១ រោចខែអាសាឍ ឬ ខែទុតិយាសាឍ ដល់ថ្ងៃ ១៥ កើត ខែកត្តិក ។

រដូវទាំង ៣ នេះ សម្រាប់ផ្លាស់គ្រង់ពាក្យថា គិម្ហឧតុម្ហិ ត្រូវផ្លាស់វៀនកល់រដូវ ( ៤ ខែ ឬ ជួនកាល ៥ ខែផ្លាស់មួយ ) ។

## ឈ្មោះខែ ១២

១- មិគសិរមាសេ ខែ មិគសិរ ;
២- បុស្ស – – បុស្ស ;
៣- មាឃ – – មាឃ ;
៤- ផគ្គុណ – – ផល្គុន ;

៥- ចិត្រ - - ចេត្រ ;

៦- វិសាខ - - ពិសាខ ;

៧- ជេដ្ឋ - - ជេស្ឋ ;

៨- អាសាឍ(១) - - អាសាឍ ;

៩- សាវណ - - ស្រាពណ៍ ;

១០- ភទ្ទបទា - - ភទ្របទ ;

១១- អស្សុជ - - អស្សុជ ;

១២- កត្តិកមាសេ ខែកត្តិក ។

ខែទាំង ១២ ឬ ១៣ នេះ សម្រាប់ផ្លាស់គ្រប់ពាក្យថា វិសាខ-មាសេ ត្រូវផ្លាស់វៀនកល់ខែ (មួយខែផ្លាស់មួយ) ។

## ឈ្មោះបក្ខ ២

១- សុក្កបក្ខ ២- កាឡបក្ខ ៖ បាននិយាយការដើមគ្រប់ទំព័រ ៧៩ រួចហើយ ។ បក្ខទាំង ២ នេះ សម្រាប់ផ្លាស់គ្រប់ពាក្យ ថា សុក្កបក្ខេ ត្រូវផ្លាស់វៀនកល់បក្ខ (កន្លះខែផ្លាស់មួយ) ។

---

១បើឆ្នាំដែលមានអធិកមាស ខែអាសាឍ២ដង មុនអានថា បឋមាសាឍ-មាសេ ក្រោយអានថា ទុតិយាសាឍមាសេ (ក្នុងឆ្នាំនោះមានខែ ១៣) ។

ចំនួនតិថី ១៥

១– បាដិបទេ តិថិយំ តិថីបាដិបទ គឺថ្ងៃ ១ កើត ១ រោច ;

២– ទុតិយាយ – តិថីទី ២ – ២ – ២ – ;

៣– តតិយាយ – – ៣ – ៣ – ៣ – ;

៤– ចតុត្ថិយា – – ៤ – ៤ – ៤ – ;

៥– បញ្ចមិយា – – ៥ – ៥ – ៥ – ;

៦– ឆដ្ឋិយា – – ៦ – ៦ – ៦ – ;

៧– សត្តមិយា – – ៧ – ៧ – ៧ – ;

៨– អដ្ឋមិយា – – ៨ – ៨ – ៨ – ;

៩– នវមិយា – – ៩ – ៩ – ៩ – ;

១០– ទសមិយា – – ១០ – ១០ – ១០ – ;

១១– ឯកាទសិយា – – ១១ – ១១ – ១១ – ;

១២– ទ្វាទសិយា – – ១២ – ១២ – ១២ – ;

១៣– តេរសិយា – – ១៣ – ១៣ – ១៣ – ;

១៤– ចាតុទ្ទសិយា – – ១៤ – ១៤ – ១៤ – ;

១៥– បណ្ណរសិយា តិថិយំ តិថីទី ១៥ គឺថ្ងៃ១៥ កើត ១៥ រោច។

តិថីទាំង ១៥ នេះ សម្រាប់ផ្សំត្រង់ពាក្យថា <u>បណ្ណរសិយា</u>

គិឋិយំ ត្រូវញសរៀនកល់គិថី (មួយថ្ងៃផ្លាស់មួយ) ; ក្នុងកាលបក្ស បើខ្វះមានតិថីត្រឹមតែ ១៤ ប៉ុណ្ណោះ ។

ឈ្មោះថ្ងៃ ៧

| | |
|---|---|
| ១ រវិវារេ | ថ្ងៃអាទិត្យ ; |
| ២– សសិ – | – ចន្ទ ; |
| ៣– ភុម្ម – | – អង្គារ ; |
| ៤– ពុធ – | – ពុធ ; |
| ៥– គុរុ – | – ព្រហស្បតិ៍ ; |
| ៦– សុក្រ – | – សុក្រ ; |
| ៧– សោរវារេ | ថ្ងៃសៅរ៍ ។ – |

ថ្ងៃទាំង ៧ នេះ សម្រាប់ផ្លាស់គ្រង់ពាក្យថា រវិវារេ ត្រូវផ្លាស់រៀងរាល់ថ្ងៃ (មួយថ្ងៃផ្លាស់មួយ) ។

ស័ក១០សម្រាប់លំដាប់ឆ្នាំ

១.ឯកស័ក ; ២–ទោស័ក ; ៣– ត្រីស័ក ; ៤– ចត្វាស័ក ; ៥– បញ្ចស័ក , ៦– ឆស័ក ; ៧- សប្តស័ក ; ៨– អដ្ឋស័ក ; ៩– នព្វស័ក ១០- សំរឹទ្ធិស័ក ។

ស័កទាំង ១០ នេះ សម្រាប់ផ្លាស់គ្រង់ពាក្យ ត្រីស័ក ត្រូវផ្លាស់

រៀនកល់ស័ក (មួយឆ្នាំផ្លាស់មួយ) ។

សេចក្ដីពន្យល់អំពីរបៀបផ្លាស់ថ្ងៃខែឆ្នាំ ក្នុងកាលតាំង ៣ ដែលបានពន្យល់រួចហើយនេះ បើសាធុជនទាំងឡាយ បានសិក្សាមេរៀនសម្រាប់សូត្រកប់ពុទ្ធសករាជ តាមបាលីក្នុងសង្កេតទី ១ និងទី ២ ខាងដើមនោះ ឲ្យបានចាំស្ទាត់ជាក់ច្បាស់ជាមុនសិន នោះទើបពឹងពិចារណាទៅ នឹងការយល់បានដោយងាយ មិនលំបាកឡើយ ។

## សេចក្ដីពន្យល់អំពីរបៀបផ្លាស់ ថ្ងៃ ខែ ឆ្នាំ ចប់ ។

## ភាសិតោវាទគាថា

ក្នុងភាសិតោវាទសង្ខេប មានគាថា លោកប្រាប់បញ្ជាក់អំពីចំនួននៃព្រះពុទ្ធសាសនាយុកាល និងឈ្មោះគ្រងទីបំផុតនោះថា

ភុត្វាវេ សព្វញ្ញុ ពុទ្ធោ
តត្ថ ចក្កំ បវត្តយិ
និព្វានគមនំ សព្វេ
សហស្សំ បញ្ចមូសិកេ ។

(ព្រះវិជិតមារ) ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ក្នុងឆ្នាំរកា ទ្រង់សម្ដែងនូវព្រះធម្មចក្ក ក្នុង(ឆ្នាំរកា)នោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥០០០ គត់ក្នុងឆ្នាំជូត ។

## អវសានពេចន៍

ព្រោះពុទ្ធសករាជនេះ  គួរយើងចាំចេះរៀនគល់គ្នា
គ្រាន់ស្គាល់ក្រស្នាព្យាយគ្រប់វេលា  វន្ទាគោរពព្រះសម្ពុទ្ធ ។
ប្រែប្រាប់អាយុពុទ្ធសាសនា  ប្រាំពាន់វស្សាវិសេសសុទ្ធ
ឲ្យដឹងអតីត(១) អនាគត  កំណត់បច្ចុប្បន្នឲ្យជាក់លាក់ ។
ថ្ងៃអ្វី កិច្ចក្នុងបក្ខណា ?  មាសាវារឆ្នាំនិងសក
បច្ចុប្បន្នអ្វីណា ? ជាជាក់  ត្រូវគិតចាំឈ្មោះថ្ងៃខែឆ្នាំ ៕
ពុទ្ធសករាជកន្លងទៅ  សល់នៅប៉ុន្មានគិតឲ្យចាំ
សរុប ចូលថ្ងៃតាមចំណាំ  គ្រប់ប្រាំពាន់កុំឲ្យបាត់ ។
ប្រយោជន៍ដែលយើងពិចារណា  អាយុសាសនាដោយម៉ឺនម៉ាត់
ឲ្យមានប្រាជ្ញារៀនសូត្រស្ទាត់  ចេះចាំប្រវត្តិពុទ្ធសាសនា ។
មួយទៀត ត្រូវតាមពុទ្ធដីកា  វិន័យប្រាប់ខ្នាតឲ្យសិក្សា
រៀនខាងកប់ចក្ខុនោះឯងណា  គល់អគ្គអាត្មាជាបណ្ឌិត ។
ពោះចាំងគ្រហស្ថក៏គួររៀន  ខំប្រឹងប្រឹករៀនឲ្យចាំពិត
អាយុសាសនាដែលថេរបិត  គម្រិត៥០០០ឆ្នាំនោះហោង ។

អវសានពេចន៍ ចប់

បញ្ចុគណភាគា ដំណើរវរាប់បញ្ចប់ ។

---

១ អតីត អានថា អទិតកាមស្រួលមាត់ ( វចនានុក្រមខ្មែរ )

សេចក្តីនៃគាថានេះរៀនចាត់ណាស់ លុះដល់ព្រះពុទ្ធសាសនា មានព្រះជន្មាយុកាលគ្រប់៥០០០ឆ្នាំនោះ នឹងរៀនតែត្រូវគ្រន់ឆ្នាំផ្លូត នោះមែនពិត ។

ភាសិតោវាទគាថា ចប់

# ខណ្ឌទី ៧

*ចតុរារិយសច្ចសង្ខេប*(១)

*អវសានពេចន៍*

*យក្ខាសូត្រ*

*វិក្កសូត្រ*

*ភីកសូត្រ*

*អត្ថបទតាំងសេចក្តីប្រាថ្នា*

នមោ តស្ស ភគវតោ

អរហតោ សម្មាសម្ពុទ្ធស្ស ។

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ៗ*

---

១ អរិយសច្ចធម៌ទាំង ៤ ប្រការនោះ មានទៅប្រាកដក្នុងធម្មចក្កប្បវត្តនសូត្រ សតិប្បដ្ឋានសូត្រ សច្ចវិភង្គសូត្រ និង សច្ចវិភង្គអភិធម្មបិដក ជាធម៌មានសេចក្តីពិស្តារជ្រាលជ្រៅល្អិតល្អន់ក្រៃលែង ។ ឯក្នុងសៀវភៅនេះ ខ្ញុំស្រង់យកតែត្រង់គោលសេចក្តីនៃអរិយសច្ចធម៌ទាំង ៤ នោះដោយសង្ខេប ។ ជាបែបមេរៀនខ្លី ។ ជាការងាយស្រួលដល់អ្នកសិក្សាដំបូងប៉ុណ្ណោះ ។

## ចតុរារិយសច្ចសង្ខេប

ក្នុងទីនេះ ខ្ញុំនឹងដកស្រង់យកគោលសេចក្ដីនៃ ចតុរារិយសច្ច គឺ អរិយសច្ចធម៌ ៤ យ៉ាង មកចោទនារៀបរៀងជាមេរៀនសង្ខេបខ្លី ៗ ក្រាទុកជាគ្រឿងប្រដាប់សម្រាប់សិក្សា ជាផ្លូវសតិបញ្ញា នៃពួកពុទ្ធបរិស័ទទាំងឡាយជាលំដាប់តទៅ ។

អរិយសច្ចធម៌នេះ គឺជាធម៌ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្ដែងក្នុងធម្មចក្កប្បវត្តនសូត្រ បឋមទេសនាជាដំបូងបង្អស់ ក្នុងកាលដែលព្រះអង្គបានត្រាស់ដឹងទើបតែនឹងបាន ៦០ ថ្ងៃគត់, ទ្រង់ប្រកាសប្រាប់ដំណើរសេចក្ដី អំពីកងទុក្ខ និងហេតុដែលនាំឲ្យកើតកងទុក្ខ ព្រមទាំងសេចក្ដីប្រតិបត្តិ ជាដំណើរទៅរកសេចក្ដីរលត់កងទុក្ខ ប្រោសបញ្ចវគ្គិយភិក្ខុទាំង ៥ អង្គ និងពួកព្រហ្ម ១៨ កោដិ ឲ្យបានសម្រេចមគ្គផល តាមសមគួរដល់ឧបនិស្ស័យធម៌របស់ខ្លួនរៀងៗខ្លួន នាព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

## អរិយសច្ចធម៌ ៤ យ៉ាង

ពាក្យថា អរិយសច្ច ប្រែថា សេចក្ដីពិតរបស់ព្រះអរិយបុគ្គល, សេចក្ដីពិតឥតមានល្អៀង ។

អរិយសច្ចនោះ មាន ៤ យ៉ាងគឺ

១– ទុក្ខអរិយសច្ច សេចក្តីពិតរបស់ព្រះអរិយបុគ្គលគឺ ទុក្ខ;

២ ទុក្ខសមុទយអរិយសច្ច សេចក្តីពិតរបស់ព្រះអរិយបុគ្គល គឺ កំណើតទុក្ខ ឬ តណ្ហាជាមេហេតុនាំឲ្យកើតទុក្ខ;

៣· ទុក្ខនិរោធអរិយសច្ច សេចក្តីពិតរបស់ព្រះអរិយបុគ្គល គឺ សេចក្តីរលត់ទុក្ខ ឬ ព្រះនិព្វានធម៌សម្រាប់រលត់ទុក្ខ (១);

៤– ទុក្ខនិរោធគាមិនី បដិបទាអរិយសច្ច សេចក្តីពិតរបស់ព្រះអរិយបុគ្គល គឺ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វានធម៌សម្រាប់រលត់ទុក្ខ ។

អរិយសច្ចទាំង ៤ យ៉ាងនេះ ហៅដោយរួបរួមថា ចតុរា·រិយសច្ច ។

## ទុក្ខអរិយសច្ច

ទុក្ខៈ សេចក្តីព្រួយលំបាក មាន ១៣ កងគឺ

១– ជាតិទុក្ខ ទុក្ខព្រោះមានកំណើតកើតមកជារូបកាយ ឬ កិរិយាកើតឡើងប្រាកដនៃខន្ធទាំងឡាយ ;

---

១ ព្រះនិព្វានធម៌ សម្រាប់រលត់ភ្លើងកិលេសតណ្ហា និងភ្លើងទុក្ខទាំងអស់ ឥតមានសេសសល់ ។

២- ជរាទុក្ខ ទុក្ខព្រោះការចាស់ទ្រុឌទ្រោមគ្រាំគ្រា ;

៣- ព្យាធិទុក្ខ ទុក្ខព្រោះការឈឺថ្កាត់ ;

៤- មរណទុក្ខ ទុក្ខព្រោះសេចក្ដីស្លាប់ ;

៥- សោកទុក្ខ ទុក្ខព្រោះសេចក្ដីជ្រប់ស្រពោនស្ងួតស្ងប់ក្រៀមក្រំស្ដាយស្រណោះ ;

៦- បរិទេវទុក្ខ ទុក្ខព្រោះការខ្សឹកខ្សួល សម្រែកទ្រហោយំ អណ្ដើតអណ្ដកនិយាយបំប៉ាច់បំប៉ោច ;

៧- ទុក្ខទុក្ខ ទុក្ខព្រោះសេចក្ដីលំបាកកាយ ;

៨- ទោមនស្សទុក្ខ ទុក្ខព្រោះសេចក្ដីតាក់អន់ចិត្ត ;

៩- ឧបាយាសទុក្ខ ទុក្ខព្រោះសេចក្ដីចង្អៀតតានតឹងក្នុងចិត្ត;

១០- អប្បិយេហិ សម្បយោគទុក្ខ ទុក្ខព្រោះការជួបប្រសព្វដោយសត្វនិងសង្ខារមិនជាទីស្រឡាញ់(១);

១១- បិយេហិ វិប្បយោគទុក្ខ ទុក្ខព្រោះការព្រាត់ប្រាស

---

១ អារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ឬ ជនទាំងឡាយណា ប្រាថ្នាសេចក្ដីមិនចម្រើន ប្រាថ្នាអំពើឥតប្រយោជន៍ ប្រាថ្នាសេចក្ដីមិនសប្បាយ ប្រាថ្នាសេចក្ដីមិនក្សេមចាកយោគ ការជួបប្រសព្វនឹងអារម្មណ៍ ឬ ជនទាំងឡាយនោះ ជាទុក្ខ ។

ចាកសុខនិងសង្ខារជាទីស្រឡាញ់(១);

១២– យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ទុក្ខព្រោះចង់បានរបស់ណា មិនបានរបស់នោះ(២),

១៣– សង្ខិត្តេន បញ្ចុបាទានក្ខន្ធាទុក្ខា ដោយបំព្រួញប្រមូលមក ទុក្ខព្រោះតែឧបាទានក្ខន្ធទាំង៥(៣)។

កងទុក្ខទាំង ១៣ នេះ ឈ្មោះថា ទុក្ខអរិយសច្ច ។

ទុក្ខអរិយសច្ច ចប់ ។

ទុក្ខសមុទយអរិយសច្ច ។

---

១ អារម្មណ៍ទាំងឡាយមានបារម្មណ៍ជាដើម ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ឬ ជនទាំងឡាយណាគឺមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្រក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាសេចក្តីក្សេមចាកយោគៈ ការព្រាត់ប្រាសចាកអារម្មណ៍ ឬ ជនទាំងឡាយនោះ ជាទុក្ខ ។ ២ ពួកសត្វទាំងអស់ប្រាថ្នាចង់បានថា កុំឲ្យមានជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ក្នុងចិត្តជាធម្មតា ការមិនបានសម្រេចដូចសេចក្តីប្រាថ្នានោះ ជាទុក្ខ ។ ៣ ឧបាទានក្ខន្ធទាំង ៥ នោះគឺ រូបជាឧបាទានក្ខន្ធ ១ វេទនាជាឧបាទានក្ខន្ធ ១ សញ្ញាជាឧបាទានក្ខន្ធ ១ សង្ខារជាឧបាទានក្ខន្ធ ១ វិញ្ញាណជាឧបាទានក្ខន្ធ ១ ឧបាទានក្ខន្ធទាំង ៥ នេះក៏ជាទុក្ខ ។

ទុក្ខសមុទយៈ គឺហេតុទុក្ខ ឬ តណ្ហាជាមេហេតុនាំឲ្យកើតទុក្ខ ។

តណ្ហាដែលនាំសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយតម្រេកនឹងភព ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាល ក្នុងអារម្មណ៍នោះៗ ឬ ក្នុងភពនោះៗ តណ្ហានោះ មាន ៣ យ៉ាងគឺ

១. កាមតណ្ហា សេចក្ដីប្រាថ្នា ប្រកបដោយកាមគុណ ;
២. ភវតណ្ហា សេចក្ដីប្រាថ្នា ប្រកបដោយសស្សតទិដ្ឋិ(១):
៣. វិភវតណ្ហា សេចក្ដីប្រាថ្នា ប្រកបដោយឧច្ឆេទទិដ្ឋិ (២) ។

តណ្ហាទាំង ៣ នេះ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច ។

ទុក្ខសមុទយអរិយសច្ច ចប់ ។

## ទុក្ខនិរោធអរិយសច្ច

ទុក្ខនិរោធ : សេចក្ដីរលត់ទុក្ខ ឬ ព្រះនិព្វានជាធម៌សម្រាប់រលត់ទុក្ខ ។

កិរិយារលត់ទៅនៃតណ្ហានោះ ដោយអរិយមគ្គ ឥតមានសេសសល់ កិរិយាលះបង់នូវតណ្ហានោះ កិរិយាលះចោលនូវតណ្ហានោះ កិរិយារួចចាកតណ្ហានោះ សេចក្ដីមិនមានអាល័យចំពោះតណ្ហានោះឯង នេះ

---

១ សេចក្ដីយល់ឃើញថា សត្វលោកទៀង ហៅថា សស្សតទិដ្ឋិ ។ ២ សេចក្ដីយល់ឃើញថា បនុស្សសត្វទាំងអស់សុទ្ធតែស្លាប់ទៅហើយដាច់សូន្យលែងកើតទៀត ហៅថា ឧច្ឆេទទិដ្ឋិ ។

*ឈ្មោះថា* ទុក្ខនិរោធអរិយសច្ច ។

ទុក្ខនិរោធអរិយសច្ច ចប់ ,

ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច

ទុក្ខនិរោធគាមិនីបដិបទា *សេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វានធម៌សម្រាប់រលត់ទុក្ខ ។*

អរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការនេះគឺ

១. សម្មាទិដ្ឋិ *ប្រាជ្ញាយល់ឃើញត្រូវ* (១) ;

២. សម្មាសង្កប្បោ *សេចក្ដីត្រិះរិះត្រូវ*(២) ;

៣. សម្មាវាចា *វាចាត្រូវ*(៣);

៤. សម្មាកម្មន្តោ *ការងារត្រូវ*(៤);

៥. សម្មាអាជីវោ *ការចិញ្ចឹមជីវិតត្រូវ*(៥) ;

---

១ ប្រាជ្ញាដឹងច្បាស់ក្នុងអរិយសច្ច ៤ យ៉ាង ឈ្មោះថាប្រាជ្ញាយល់ឃើញត្រូវ ។ ២ សេចក្ដីត្រិះរិះដើម្បីចេញចាកកាម ១. ដើម្បីមិនព្យាបាទ ១. ដើម្បីមិនបៀតបៀន ១ ឈ្មោះថាសេចក្ដីត្រិះរិះត្រូវ ។ ៣ វាចាដែលវៀរចាកវចីទុច្ចរិត ៤ យ៉ាង ឈ្មោះថាវាចាត្រូវ ។ ៤ ការងារដែលវៀរចាកកាយទុច្ចរិត ៣ យ៉ាងគឺ ឈ្មោះថាការងារត្រូវ ។ ៥ ការចិញ្ចឹមជីវិតរបស់គ្រហស្ថ ដែលវៀរជំនួញ ៥ ប្រការ និងវៀរចាកការវៀចកោង ការបំបាត់បន្ទំ ដោយជញ្ជីងធ្ងន់ស្រាល ដោយរង្វាស់វែងខ្លី ដោយរង្វាស់តិចច្រើនជាដើម, ការចិញ្ចឹមជីវិតរបស់បព្វជិត ដែលវៀរចាកមិច្ឆាជីវៈបាបធម៌ ៥ យ៉ាង និងអនេសនៈ ២១ ជាដើម ហើយសម្រេចការចិញ្ចឹមជីវិតដ៏បរិសុទ្ធ ដោយសុចរិតយុត្តិធម៌ ឈ្មោះថា ការចិញ្ចឹមជីវិតត្រូវ។

៦· សម្មាវាយាមោ ព្យាយាមត្រូវ (១) ;

៧· សម្មាសតិ សេចក្ដីរលឹកត្រូវ (២) ;

៨· សម្មាសមាធិ ការតម្កល់ចិត្តត្រូវ (៣) ។

អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ឈ្មោះថា ទុក្ខនិរោធ-គាមិនីប៉ដិបទា អរិយសច្ច ។

ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច ចប់ ។

អរិយសច្ច ៤ យ៉ាង ចប់ ។

អត្ថនៃអរិយសច្ច ៤ ។

បណ្ដាអរិយសច្ចទាំង ៤ នោះ អរិយសច្ចមួយ ៗ មានអត្ថមួយៗ ។

ទុក្ខអរិយសច្ច មានអត្ថ ៤ ប្រការគឺ

---

១ ព្យាយាមបិទបាំងអកុសលធម៌ កុំឲ្យកើតឡើង ១ ព្យាយាមលះបង់អកុសលធម៌ ដែលកើតឡើងហើយ ១ ព្យាយាមញុំាងកុសលធម៌ឲ្យកើតឡើង១ ព្យាយាមថែរក្សាកុសលធម៌ដែលកើតឡើងហើយ ១ ឈ្មោះថា ព្យាយាមត្រូវ។
២ ការតម្កល់ស្មារតីទុកក្នុងសតិប្បដ្ឋានទាំង ៤ យ៉ាង ឈ្មោះថាសេចក្ដីរលឹកត្រូវ។
៣ សេចក្ដីស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយតម្កល់ចិត្តទុកក្នុងឈានទាំង ៤ ឈ្មោះថា ការតម្កល់ចិត្តត្រូវ ។ (អដ្ឋមគ្គទាំង ៨ ប្រការនេះ សុទ្ធតែមានសេចក្ដីពិស្ដារគ្រប់អន្លើទាំងអស់ ដែលសរសេរមកនេះគ្រាន់តែបង្ហាញគោលឲ្យឃើញជាចំនងខ្លះប៉ុណ្ណោះ លោកអ្នកត្រូវការសេចក្ដីពិស្ដារគប្បីស្វែងរកមើលក្នុងគម្ពីរទាំងឡាយ មានសតិប្បដ្ឋានសូត្រជាដើមផងចុះ) ។

១- បីឡូនក្តោ មានអត្ថជាបៀតបៀនសត្វឲ្យលំបាក ;

២- សំខតក្តោ មានអត្ថជាតណ្ហាជាបច្ច័យប្រជុំតាក់តែង ;

៣- សន្តាបក្តោ មានអត្ថជាញ៉ាំងសត្វឲ្យក្តៅក្រហាយ ;

៤- វិបរិណាមក្តោ មានអត្ថជាធ្វើសត្វឲ្យប្រែប្រួលវិបរិតផ្សេងៗ

ទុក្ខសមុទយអរិយសច្ច មានអត្ថ៤ប្រការគឺ

១ អាយុហានក្តោ មានអត្ថជាប្រមូលមកនូវតែងទុក្ខ ;

២- និទានក្តោ មានអត្ថជាជាហេតុឲ្យកើតតែងទុក្ខ ;

៣- សំយោគក្តោ មានអត្ថជាប្រកបសត្វទុកនៅក្នុងវដ្តសង្សារ;

៤ បលិពោធក្តោ មានអត្ថជាកង្វល់វល់ដោយកិលេសកាមនិងវត្ថុកាម ។

ទុក្ខនិរោធអរិយសច្ច មានអត្ថ ៤ ប្រការគឺ

១- និស្សរណក្តោ មានអត្ថជាចេញចេញចាកភព;

២- អបលិពោធក្តោ (១) មានអត្ថជាមិនមានកង្វល់វល់ដោយកិលេសកាមនិងវត្ថុកាម ;

៣- អសំខតក្តោ មានអត្ថជាតណ្ហាបច្ច័យប្រជុំតាក់តែងមិនមាន;

៤- អមតក្តោ មានអត្ថជាជាអម្រឹតធម៌ គឺធម៌ដែលមិនចេះស្លាប់ៗ

១ បាលីថា វិវេកក្តោ ដូច្នេះក៏មាន ។

ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច មានអត្ថ៤ប្រការគឺ

១· និយ្យានត្ថោ មានអត្ថថានាំឱ្យចេញចាកភព;

២· ហេត្វត្ថោ មានអត្ថថាជាហេតុនៃព្រះនិព្វាន;

៣· និទស្សនត្ថោ(១) មានអត្ថថាសម្តែងចេញ គឺបានឃើញនូវព្រះនិព្វាន ;

៤· អធិបតេយ្យត្ថោ(២) មានអត្ថថាជាធំក្នុះកិច្ចដែលនឹងរម្ងាប់នូវកងទុក្ខទាំងពួង ។

## អត្ថនៃអរិយសច្ច ៤ ចប់ ។

---

## សោឡសកិច្ច

អរិយសច្ចទាំង ៤ យ៉ាងនេះ មានកិច្ចផ្សេងៗ គ្នាដូច្នេះគឺ

១- ទុក្ខអរិយសច្ច ជាបរិញ្ញេយ្យកិច្ច (៣) គឺ កិច្ចដែលត្រូវកំណត់ដឹង ;

២· ទុក្ខសមុទយអរិយសច្ច ជាបហាតព្វកិច្ចគឺកិច្ចដែលត្រូវលះបង់ចោល ;

៣- ទុក្ខនិរោធអរិយសច្ច ជាសច្ឆិកាតព្វកិច្ចគឺកិច្ចដែលត្រូវធ្វើឲ្យ

---

១ ជា ទស្សនត្ថោដូច្នេះក៏មាន ។ ២ ជា អធិបតេយ្យត្ថោ ដូច្នេះខ្លះ ។
៣ ហៅថា បរិញ្ញាតព្វកិច្ច ដូច្នេះក៏បាន ។

ជាក់ច្បាស់ ;

៤. ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ជាភាវេតព្វកិច្ច គឺកិច្ចដែលត្រូវចម្រើនឲ្យកើតឡើង ។

## ចាត់កិច្ចតាមលំដាប់មគ្គ ៤

កិច្ចនៃអរិយសច្ចទាំង ៤ នេះ ចាត់ទៅតាមលំដាប់នៃមគ្គទាំង ៤ ដូច្នេះគឺ ក្នុងមគ្គមួយ ។ មានកិច្ចនៃអរិយសច្ចទាំង ៤ នេះដូច ។ គ្នាគឺ សោតាបត្តិមគ្គ ៤ សកទាគាមិមគ្គ ៤ អនាគាមិមគ្គ ៤ អរហត្តមគ្គ ៤ ចួន ។ ផង ផ្សំគ្នាទៅត្រូវជាកិច្ច ១៦ ហៅថា សោឡសកិច្ច ។

សោឡសកិច្ច ចប់ ។

---

## ញាណ ៣ ប្រការ

ញាណ ៣ ប្រការរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់គឺ

សច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ ។

### សច្ចញ្ញាណ

ព្រះប្រាជ្ញាញាណដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹង នូវចតុរារិយសច្ច ដោយប្រពៃចំពោះព្រះអង្គថា

១- ឥទំ ទុក្ខំ អរិយសច្ចំ ករទុក្ខនេះឈ្មោះថា អរិយសច្ច.

២- ឥទំ ទុក្ខសមុទយោ អរិយសច្ចំ តណ្ហា ជាដែនកើតឡើង

នៃកង់ទុក្ខនេះ ឈ្មោះថា អរិយសច្ច;

៣. ឥទំ ទុក្ខនិរោធោ អរិយសច្ចំ ព្រះនិព្វានធម៌ជាទីរលត់ទៅនៃកង់ទុក្ខនេះ ឈ្មោះថា អរិយសច្ច;

៤. ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ សេចក្តីប្រតិបត្តិនាំសត្វឲ្យដល់នូវព្រះនិព្វានធម៌ ជាទីរលត់ទៅនៃកង់ទុក្ខនេះឈ្មោះថា អរិយសច្ច; ដូច្នេះ ហៅថា សច្ចញ្ញាណ ។

កិច្ចញ្ញាណ

ព្រះប្រាជ្ញាញាណដែលព្រះសម្ពុទ្ធ ទ្រង់ត្រាស់ដឹង នូវកិច្ចនៃចតុរារិយសច្ចថា

១. តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យំ កង់ទុក្ខនោះឯងឈ្មោះថា អរិយសច្ច ដែលគប្បីកំណត់ដឹង;

២. តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វំ តណ្ហាជាដែនកើតឡើងនៃកង់ទុក្ខនោះឯង ឈ្មោះថា អរិយសច្ច, ដែលគប្បីគប្បីលះបង់ចោល;

៣- តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វំ ព្រះនិព្វានធម៌ជាទីរលត់ទៅនៃកង់ទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលគប្បីគប្បីធ្វើឲ្យជាក់ច្បាស់;

៤- តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វំ សេចក្ដីប្រតិបត្តិនាំសត្វឲ្យដល់នូវព្រះនិព្វានធម៌ជាទីរលត់ទៅនៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលតថាគតគួរតែចម្រើនឲ្យកើតឡើង ; ដូច្នេះហៅថា កិច្ចញ្ញាណ ។

## កតញ្ញាណ

ព្រះប្រាជ្ញាញាណដែលព្រះសម្ពុទ្ធ ទ្រង់ត្រាស់ដឹង នូវកិច្ចនៃចតុរារិយសច្ចដែលព្រះអង្គបានធ្វើសម្រេចហើយថា

១. តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតំ កងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលតថាគតកំណត់ដឹងបានហើយ ;

២. តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហីនំ តណ្ហាជាដែនកើតឡើងនៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលតថាគតលះបង់ចោលបានហើយ ;

៣. តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកតំ ព្រះនិព្វានធម៌ជាទីរលត់ទៅនៃកងទុក្ខនោះឯង ឈ្មោះថា អរិយសច្ច ដែលតថាគតធ្វើឲ្យជាក់ច្បាស់បានហើយ ;

៤. តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតំ សេចក្ដីប្រតិបត្តិនាំសត្វឲ្យដល់នូវព្រះនិព្វានធម៌ជាទីរលត់

ទៅនៃកិច្ចនោះឯង ឈ្មោះថា អរិយសច្ច ដែលគប្បីចម្រើនឲ្យ កើតឡើងបានហើយ ; ដូច្នេះ ហៅថា កតញ្ញាណ ។

ញាណទាំង ៣ ប្រការនេះឯងហើយដែល ហៅថា បរិវដ្ដៈ ៣ ។

បរិវដ្ដៈ ៣ នេះប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង ៤ អរិយសច្ចមួយ ១ មានបរិវដ្ដៈបី ១ គឺ ទុក្ខអរិយសច្ច ៣ ទុក្ខសមុទយអរិយសច្ច ៣ ទុក្ខនិរោធអរិយសច្ច ៣ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ៣ បី ៤ ដង ផ្សំគ្នាទៅត្រូវជា ១២ ហៅថា អាការៈ ១២ ។

ម្យ៉ាងទៀត បណ្ដាញាណៈទាំង ៣ ប្រការនេះ ញាណមួយ ១ សុទ្ធតែប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង ៤ ដូច ១ គ្នាគឺ សច្ចញាណ ៤ កិច្ចញាណ ៤ កតញ្ញាណ ៤ ចួន ៣ ដង ផ្សំគ្នាទៅ ក៏ត្រូវជាអាការៈ ១២ ដូចគ្នាដែរ ។

ញាណទស្សនៈ គឺព្រះប្រាជ្ញាញាណដែលព្រះអង្គទ្រង់ត្រាស់ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវអរិយសច្ចធម៌ទាំង ៤ ប្រការ ប្រកបដោយបរិវដ្ដៈ ៣ និងអាការៈ ១២ នេះឯងហើយដែលហៅថា ធម្មចក្ក ចក្រធម៌ ឬ ធម៌ដូចជាកង់ គឺធម៌ដែលព្រះសព្វញ្ញុទ្រង់ត្រាស់សំដែងអរិយសច្ច៤ បង្វិលដំណើរសេចក្ដី គឺ ទ្រង់បង្វិលញាណទាំង៣ ប្រការនេះជាបរិវដ្ដៈ ឲ្យវិលវែងជុំវិញចូលទៅក្នុងអរិយសច្ចទាំង ៤ យ៉ាង ដូចជាកង់រទេះ ។

ក្នុងធម្មចក្កប្បវត្តនសូត្រ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ជាក់ នីងបញ្ញត្តិយកត្ថុថា

ម្នាលភិក្ខុទាំងឡាយ ញាណទស្សនៈ ដ៏ប្រាកដជាដែលដឹងឃើញច្បាស់តាមពិត មានបរិវដ្ត ៣ មានអាការៈ ១២ យ៉ាងនេះ ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ របស់តថាគត នៅមិនទាន់បរិសុទ្ធល្អអស់កាលត្រឹមណា

ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងចំពោះ នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកព្រមទាំងទេវលោក មារលោកនិងព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលត្រឹមនោះ នៅឡើយទេ ។

ម្នាលភិក្ខុទាំងឡាយ ញាណទស្សនៈ តាមពិតមានបរិវដ្តៈ ៣ មានអាការៈ ១២ យ៉ាងនេះ ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ របស់តថាគតបរិសុទ្ធល្អហើយ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងចំពោះ នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ ក្នុងលោកព្រមទាំងទេវលោក មារលោកនិងព្រហ្មលោក ក្នុងពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះឯង ។

ឯញាណទស្សនៈ កើតឡើងហើយដល់តថាគតថា វិមុត្តិគឺអរ-ហត្តផលរបស់តថាគត មិនប្រែប្រួលកម្រើកឡើយ ជាតិនេះជាទីបំផុត ត្រឹមនេះហើយ ភពនេះទៅ ភពថ្មីគឺការត្រឡប់កើតទៀតមិនមានឡើយៗ

ញាណក៌ពាប្រការ ចប់ ។

និគមគាថា

នាពាធកំ យតោ ទុក្ខំ
ទុក្ខា អញ្ញំ ន ពាធកំ
ពាធកត្តនិយាមេន
តតោ សច្ចមិទំ មតំ ។

ឲ្យតែហៅថា ទុក្ខ មិនមែនជាមិនបៀតបៀន (ផល់សត្វ) ទេ ធម្មជាតដទៃ ក្រៅអំពីទុក្ខ មិនមែនជាមកបៀតបៀន (ផល់សត្វ) ឡើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា "ទុក្ខនេះជារបស់ពិត ១ តាមទំនងដែលបៀតបៀន (ផល់សត្វ)" ។

តំ វិនា នាញ្ញតោ ទុក្ខំ
ន ហោតិ ន ច តន្តតោ
ទុក្ខហេតុនិយាមេន
ឥតិ សច្ចំ វិសត្តិកា ។

ទុក្ខមិនមែនកើតមកអំពីហេតុដទៃ ក្រៅអំពីតណ្ហានោះឡើយ ទុក្ខនោះ ពិតជាកើតមកតែអំពីតណ្ហានោះម្យ៉ាង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា « តណ្ហានេះជារបស់ពិត ១ តាមចំនួនដែលជាហេតុបណ្ដាលឲ្យកើតទុក្ខ » ។

នាញ្ញា និព្វានតោ សន្តិ
សន្តំ ន ច ន តំ យតោ
សន្តភាវនិយាមេន
តតោ សច្ចមិទំ មតំ ។

គុណជាតដទៃក្រៅអំពីព្រះនិព្វាន មិនមែនជាធម៌សម្រាប់រម្ងាប់នូវទុក្ខបានឡើយ មានតែព្រះនិព្វាននោះឯងហើយ ទើបជាធម៌សម្រាប់រម្ងាប់នូវទុក្ខបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា «ព្រះនិព្វាននេះជារបស់ពិត ១ តាមចំនួននៃសភាពដែលរម្ងាប់នូវទុក្ខបាន» ។

មគ្គា អញ្ញំ ន និយ្យានំ
អនិយ្យានោ ន ចាបិ សោ
តច្ឆនិយ្យានភាវត្តា
ឥតិ សោ សច្ចសម្មតោ ។

មគ្គមានអង្គ ៨ ដ៏ប្រសើរ ដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន - ជាឋានរម្ងាប់បង់នូវសេចក្តីទុក្ខ ១ ដោយប្រាជ្ញាដ៏ត្រូវ ទីពឹងនុ៎ះឯងជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះជាទីពឹងដ៏ឧត្តម(របស់បុគ្គលនោះ) បុគ្គលរមែងប្រស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

## និគមគាថា ចប់ ។

(ក្នុងនិគមគាថានេះ គាថា ៤ សង្កាត់ខាងដើមនុ៎ះ លោកសន្មតឈ្មោះថាសំវេជនីយគាថា មាននៅក្នុងសៀវភៅសតិប្បដ្ឋានសូត្រ, គាថាទាំងឡាយក្នុងសង្កាត់ខាងចុងនេះ លោកសន្មតឈ្មោះថា សរណទីបិកាគាថា មាននៅក្នុងសៀវភៅសត្តបរិត្ត , ខ្ញុំបានស្រង់យកគាថាទាំងនេះព្រមទាំងសេចក្តីប្រែ មកធ្វើជានិគមគាថា តម្កល់ទុកក្នុងទីនេះ ដើម្បីថ្លែងសេចក្តីទៅ ក្នុងចតុរារិយសច្ចសង្ខេប ដែលបានរៀបរៀងហើយ ក្នុងខាងដើមនុ៎ះឯង ព្រោះគាថាទាំងនេះ មានដំណើរសេចក្តី សំម្តែងអំពីអរិយសច្ចធម៌៤ ប្រការនោះមែនពិត ) ។

## អវសានពចន៍

អរិយសច្ច ៤ នេះណា គឺព្រះសាស្តាទ្រង់ភាសិត
ទេសនាចេនាទុកមែនពិត ជាធម៌ជ្រៅល្អិតគួរគិតគន់ ។

## ១ ទុក្ខៈ

កើតចាស់ឈឺស្លាប់សោកខ្សឹកខ្សួល មិនស្រួលក្នុងកាយចិត្តកាក់អន់
ចង្អៀតតានតឹងចិត្តកាំងកាន់ គិតគន់ការអ្វីក៏ពុំបាន ។
ការជួបប្រសព្វសត្វសង្ខារ ដែលមិនត្រូវការមិនចាប់អាន
ឬ ការព្រាត់ប្រាសញាតិសន្តាន ឬ ចង់បានអ្វីមិនដូចចិត្ត ។
នេះសុទ្ធតែទុក្ខឃើញថ្មីៗ បើពោលឲ្យខ្លីដោយសង្ខិត
ឧបាទានក្ខន្ធ ៥ មែនពិត ប្រាកដជាមេនទុក្ខធំ ។

## ២– សមុទយៈ

ព្រោះឧបាទានមានតណ្ហា ជាហេតុជួយគ្នានាំផ្សំផ្គុំ
ឲ្យកើតកងទុក្ខទាំងតូចធំ ប្រជុំនៅក្នុងត្រៃលោក ។
តណ្ហា ៣ យ៉ាង ១- កាមៈ ទី២– ភវៈ ៣– វិភវៈ
បញ្ចើច(១)ពួកសត្វទាំងអស់គ្នា ឲ្យទុក្ខវេទនាវៀនវល់ប្រាណ ។

## ៣– និរោធៈ

និកេតនិព្វានលត់តណ្ហា ផុតកងទុក្ខាទាំងប៉ុន្មាន
មានតែបរមសុខក្សេមក្សាន្ត ឥតភ័យព្រួយប្រាណពីហេតុអ្វី ។

---

១ បាលីថា ឧទ្ទិត ប្រែថា បញ្ចើច, បញ្ចេក, បញ្ចោរ ; ពុទ្ធភាសិត ថា តណ្ហាយ ឧទ្ទិតោ លោកោ តណ្ហាបញ្ចើចសត្វលោក ។ (សំយុត្តនិកាយ ) ។

បានព្រះនិព្វានល្អចំណាប់ សម្រាប់ខ្លួនជនប្រុសស្រី
អ្នកដែលនឿយណាយនឹងភពបី ខំប្រឹងកាត់ក្រពូជតណ្ហា ៗ

## ៤ មគ្គៈ

ដើរតាមអដ្ឋង្គិកមគ្គ ផ្លូវត្រង់ត្រជាក់ល្អថ្លៃថ្លា
គឺសីល សមាធិ បញ្ញា ដែលព្រះសាស្ដាទេសនាពិត ៗ
ប្រាជ្ញាយល់ត្រូវ ត្រិះរិះត្រូវ វាចាចេញទៅដោយសុចរិត
ការងារត្រូវធម៌ល្អពិចិត្រ ចិញ្ចឹមជីវិតត្រូវលំអាន ៗ
ព្យាយាមប្រពៃ ស្មារតីត្រូវ តាំងចិត្តនឹងនៅក្នុងអង្គឈាន
សមាបត្តិកាត់បាបតណ្ហាបាន សម្រេចនិព្វានបានថ្លៃថ្លា ៗ

## ការណែនាំ

បពិត្រសាធុជន គួរគិតគន់តែអញ្ញា
ទៀតយកពេលសិក្សា ធម៌ចតុរារិយសច្ច ៗ
ព្រោះធម៌នេះឯងណា ព្រះសាស្ដាបានសម្រេច
លើគល់បល្ល័ង្កពេជ្រ ក្រោមម្លប់ពោធិព្រឹក្សា ៗ
ព្រះអង្គប្រោសប្រទាន ទេសនាទូន្មានសព្វសត្វា
តាំងមនុស្សតាំងទេវតា ឥន្ទព្រហ្មឥតមោះហ្មង ៗ
ភិក្ខុបញ្ចវគ្គិយ ព្រះមុនីទ្រង់បម្រុង

ព្រមទាំងពួកព្រហ្មផង　　មុនជាងគេទាំងអស់គ្នា
ទ្រង់ទេសន៍ធម្មចក្ក　　បឋមធម៌ទេសនា
ប្រកាសបញ្ចវគ្គិយា　　និងព្រហ្មឲ្យត្រាស់ដឹង ។
នូវអរិយសច្ចធម៌　　ល្អបវរថាត់ថឹង
សម្រេចធម៌ទីពឹង　　គឺមគ្គផលនិព្វានណា ។

អរិយសច្ចធម៌ ៤　　តាមបំរួនទ្រង់ទេសនា
១- គឺគង់ទុក្ខា　　២- តណ្ហាបង្កើតទុក្ខ ។
៣- និរោធនិព្វាន　　សុខក្សេមក្សាន្តបរមសុខ
លត់តណ្ហាកងទុក្ខ　　៤- អដ្ឋង្គិកមគ្គ ។
ផ្លូវមានអង្គ ៨　　ជាវិធីត្រង់ហួតថ្នាក់
ទៅរកសុខត្រជាក់　　មគ្គផលនិព្វានថ្លៃថ្លា ។
ព្រះពុទ្ធព្រះអរហន្ត　　ប្រើរយៈកាលតែងយាត្រា
តាមមាគ៌ានេះណា　　ផុតតណ្ហានិងកងទុក្ខ ។
សំដៅទៅរកបាន　　ព្រះនិព្វានបរមសុខ
លែងវិលមករកស្រុក　　សម្បុកទុក្ខនេះទៀតហើយ ។

ហេតុនោះសាធុជន　　គួរគិតគន់កុំភោះតើយ
រៀនធម៌កុំខានឡើយ　　ដាន់ខ្លួនជាមានកម្លាំង. ។

ឲ្យចាំអរិយសច្ច ពេះស្វាគ៌ស្រេចមិនកាន់កាំង

ហើយប្រតិបត្តិសម្រាំង តាមអដ្ឋង្គិកមគ្គ ។

ផ្លូវត្រង់ល្អប្រសើរ ឆ្ពោះដំណើរទៅដំណាក់

ប្រឹងដើរដោយចិត្តស្ម័គ្រ ដល់ដំណាក់និព្វានហោង ។

អវសានពេចន៍ចប់ ។

ចតុរារិយសច្ចសង្ខេបចប់ ។

ឃដ្ឋាសូត្រ

ទេវតាក្រាបបង្គំទូលសួរថា

កឹសុ ឃត្វា សុខំ សេតិ

កឹសុ ឃត្វា ន សោចតិ

កិស្សស្ស ឯកធម្មស្ស

វធំ រោចេសិ គោតមាតិ ។

បុគ្គលសម្លាប់អ្វីបាន ទើបដេកនៅជាសុខ

សម្លាប់អ្វីបាន ទើបមិនសោក បពិត្រព្រះគោតម ព្រះអង្គគាប់ព្រះហឫ-

ទ័យ ចំពោះការសម្លាប់ធម៌ឯក តើធម៌អ្វី ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា

កោធំ ឃត្វា សុខំ សេតិ

កោធំ ឃត្វា ន សោចតិ
កោធស្ស វិសមូលស្ស
មធុរគ្គស្ស ទេវតេ
វធំ អរិយា បសំសន្តិ
តញ្ហិ ឃត្វា ន សោចតីតិ ។

*បុគ្គលសម្លាប់សេចក្តីក្រោធបាន ទើបដេកនៅជាសុខ សម្លាប់សេចក្តីក្រោធបាន ទើបមិនសោក ម្នាលទេវតា ព្រះអរិយៈទាំងឡាយតែងសរសើរការសម្លាប់សេចក្តីក្រោធ ដែលមានគល់ជាពិស មានចុងផ្អែម លុះតែសម្លាប់សេចក្តីក្រោធនោះបាន ទើបមិនសោក ។*

ឃត្វាសូត្រចប់ ។

(សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ ទេវតាសំយុត្ត)

វិត្តសូត្រ

ទេវតាក្រាបបង្គំទូលសួរថា
កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ
កឹសុ សុចិណ្ណោ សុខមាវហាតិ
កឹសុ ហវេ សាធុតរំ រសានំ
កថំ ជីវី ជីវិតមាហុ សេដ្ឋន្តិ ។

ក្នុងលោកនេះ អ្វី ជាទ្រព្យដ៏ប្រសើររបស់បុរស អ្វី ដែលគេសន្សំល្អហើយ តែងនាំសេចក្តីសុខមកឲ្យ អ្វី មានរសឆ្ងាញ់ពិសាលើសលប់ជាងរសទាំងឡាយ បណ្ឌិតទាំងឡាយពោលថា អ្នករស់នៅបែបណា ឈ្មោះថា ជាអ្នករស់នៅប្រសើរបំផុត ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា

សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាធុតរំ រសានំ
បញ្ញាជីវី ជីវិតមាហុ សេដ្ឋន្តិ ។

ក្នុងលោកនេះ សទ្ធា ជាទ្រព្យដ៏ប្រសើរ របស់បុរស ធម៌ដែលគេសន្សំល្អហើយ តែងនាំសេចក្តីសុខមកឲ្យ ពាក្យសច្ច មានរសឆ្ងាញ់ពិសាលើសលប់ជាងរសទាំងឡាយ បណ្ឌិតទាំងឡាយ ពោលថា អ្នករស់នៅដោយបញ្ញា ឈ្មោះថា ជាអ្នករស់នៅប្រសើរបំផុត ។

វិត្តសូត្រចប់ ។

( សុ. សំ. ស. ទេ. )

---

ភីតសូត្រ

ទេវតាក្រាបបង្គំទូលសួរថា

កឹសូធ ភីតា ជនតា អនេកា
មគ្គោចនេកាយតនប្បវុត្តោ
បុច្ឆាមិ តំ គោតម ភូរិបញ្ញ
កិស្មឹ ឋិតោ បរលោកំ ន ភាយេ ។

*ក្នុងលោកនេះ ពួកអ្វី ដែលប្រជុំជនច្រើនគ្នាភ័យខ្លាច ហើយព្រះអង្គសម្ដែងថា ជាផ្លូវមានមែកមែកច្រើនណាស់ បពិត្រព្រះគោតមជាម្ចាស់ ព្រះអង្គមានបញ្ញាក្រាស់ ខ្ញុំព្រះអង្គសូមសួរថា នរជនតាំងនៅក្នុងធម៌ដូចម្ដេច រមែងមិនភ័យទៅក្នុងបរលោក ។*

ព្រះមានព្រះភាគទ្រង់ត្រាស់តបថា

វាចំ មនញ្ច បណិធាយ សម្មា
កាយេន បាបានិ អកុព្វមានោ
ពហុន្នបានំ ឃរមាវសន្តោ
សទ្ធោ មុទូ សំវិភាគី វទញ្ញូ
ឯតេសុ ធម្មេសុ ឋិតោ ចតូសុ
ធម្មេ ឋិតោ បរលោកំ ន ភាយេ ។

*សាធុជនតម្កល់វាចា និងចិត្ត ដោយប្រពៃ មិនធ្វើបាបដោយកាយ គ្រប់គ្រងនូវផ្ទះ ដែលមានបាយនិងទឹកច្រើន ជាអ្នកមានសទ្ធា មានចិត្តទន់*

ជាអ្នកចែករំលែក ជាអ្នកដឹកនូវពាក្យពោល ជនដែលតាំងនៅក្នុងធម៌តាំង៤ប្រការនេះ ឈ្មោះថា ជាអ្នកបំរើនៅក្នុងធម៌ រមែងមិនភ័យនៅក្នុងបរលោកនេះ ។

## ភិតសូត្រចប់ ។

( សុ. សំ. ស. ទេ. )

---

## អត្ថបទតាំងសេចក្តីប្រាថ្នា

| | |
|---|---|
| រីឯធម្មទាននេះ | ខ្ញុំនេះរៀបរៀងទុក |
| កសាងទានទៅមុខ | ដោយសទ្ធាចិត្តផូរផង់ ។ |
| តាំងប្រារព្ធព្យាយាម | តាក់តែងគ្នាម(១) ដោយផ្ចិតផ្ចង់ |
| តាមច្បាប់ត្រឹមត្រូវត្រង់ | ក្រាទុកឲ្យអ្នកសិក្សា ។ |
| បើខ្ញុំអន្ទោលទៅ | ចាប់ជាតិនៅក្នុងភពណា |
| ជាមនុស្ស ឬ ទេវតា | សូមសុខសាន្តសព្វ ៗ ជាតិ ។ |
| សូមមានបញ្ញាក្រាស់ | ភ្លឺធ្លុះធ្លាស់ឥតវិឃាត |
| យល់ត្រូវផ្លូវធម៌ស្អាត | ដោយសារផលនៃធម្មទាន ។ |
| អហំ ខ្ញុំករុណា | តាំងសច្ចាប្រណិធាន |
| សូមបានព្រះទ្រង់ញាណ | ព្រះអរិយមេត្តេយ្យ ។ |

---

១ គ្នាម គឺ ដំណើរ , បទ , បែបបទ (របស់គាថា ឬ កាព្យឃ្លោង), សេចក្តី។

ព្រះអង្គទ្រង់បានត្រាស់ ត្រាប់ធម៌ច្បាស់ដោយញាណញ្ញេយ្យ
បរិសុទ្ធល្អប្រពៃ ពិតជាអង្គព្រះសម្ពុទ្ធ ។
ក្នុងកប្បនេះ ជា មហាសាស្តាថ្លៃវិសុទ្ធ
ពួកអនាគត ទីបំផុតខាងមុខឆ្ងាយ ។
សូមបានស្តាប់ទេសនា ព្រះលោកនាថទេសន៍ផ្សព្វផ្សាយ
ព្រោសប្រាណសត្វទាំងឡាយ គ្រប់ទិសាយសុខក្សេមក្សាន្ត ។
សូមបានត្រាស់ដឹងធម៌ ដ៏បវរល្អថ្កើងថ្កាន
គឺ មគ្គផលនិព្វាន ក្នុងសាសនាព្រះអង្គហោង ។

អត្ថបទតាំងសេចក្តីប្រាថ្នា ចប់ ។

ក្នុងអត្ថបទនេះ សូមប្រាថ្នាយកគុណធម៌៥យ៉ាងគឺ

១ សូមឲ្យបានសុខសាន្តរៀងរាល់ជាតិ ;

២-សូមឲ្យមានបញ្ញាជាសម្មាទិដ្ឋិ យល់ត្រូវផ្លូវធម៌ល្អ ;

៣- សូមឲ្យបានជួបនឹងព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាម អរិយមេ-ត្តេយ្យ;

៤-សូមឲ្យបានស្តាប់ព្រះទេសនារបស់ព្រះអង្គ ;

៥-សូមឲ្យបានសម្រេចមគ្គផលនិព្វាន ក្នុងសាសនារបស់ព្រះអង្គ ។
សាធុជនអ្នកមានសទ្ធា បានសរសេរតាមច្បាប់ធម៌អាថ៌រៀបរៀងដោយខ្លួន

ឯង ឬ បានជាតែប្ដីពេលរីរ៉ៃយកប្អូលទុកក្នុងពុទ្ធសាសនា ឲ្យគេសិក្សារៀនសូត្រក្ដី អ្នកឲ្យទាំងប្រៀនប្រដៅ ឬ បង្ហាត់បង្រៀនធម៌អាថ៌ក្ដី អ្នកសម្ដែងធម៌ឲ្យខ្លួនឯង ឬ និមន្តព្រះភិក្ខុសម្ដែងធម៌ក្ដី អ្នកសូត្រធម៌នមស្ការថ្វាយបង្គំព្រះរតនត្រ័យ ឬចម្រើនព្រះបរិត្តក្ដី ឲ្យអ្នកដទៃបានរៀនសូត្របានស្ដាប់បេះដឹងផង ទាំងអស់នេះ ឈ្មោះថា បានកាត់តែងស្ពាន តំរៀបរៀបសេចក្ដីធម៌អាថ៌ ធ្វើឲ្យមានដូចគ្នា បើត្រូវការសូត្រតាំងសេចក្ដីប្រាជ្ញាតាមបែបអក្សរទនេះក៏បាន ។

# ភណ្ឌទី៨
# បត្តិទានគាថា និង អត្ថបទផ្សេងៗ

## បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ  កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា  តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ  យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ  សព្វេ ភាគី ភវន្តុ តេ
យេ តំ កតំ សុវិទិតំ  ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ  ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា  ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ  លភន្តុ មម ចេតសា ។

*កុសលកម្ម*
*ណាមួយដែលខ្ញុំ  ធ្វើរួចហើយណា*
*ដោយទ្វារទាំងឡាយ  គឺកាយវាចា*
*ចិត្តខ្ញុំជ្រះថ្លា  ខំធ្វើបុណ្យបាន* ។

*កុសលកម្មនោះ*
*សាបនាំទៅត្តោះ  ឲ្យកើតក្នុងឋាន*
*ត្រៃត្រឹង្សសួគ៌នាយ  សប្បាយក្សេមក្សាន្ត*
*ហេតុផលកល្យាណ  នៃបុណ្យថ្លាថ្លៃ* ។

*សត្វទាំងឡាយណា*
*គឺមនុស្សទេវតា  គន្ធព្រហ្មប្រេត*

ដែលមានសញ្ញា កក់ក្រោចាំក្តី
ឬ អសញ្ញី- សត្វឥតសញ្ញា ។
សត្វទាំងឡាយនោះ
ចូរបានចំពោះ នូវភាគផលា
នៃបុណ្យជាធំ យើងខ្ញុំនេះណា
ដែលខ្ញុំជ្រះថ្លា ហើយឧទ្ទិសផ្សាយ ។
ដោយចិត្តមេត្តា (១)
និងករុណា ដល់សត្វទាំងឡាយ
មុទិតាគុណ ពោរពេញរីករាយ
ឧបេក្ខាផ្សាយ គ្រប់ទិសទីឋាន ។
សត្វទាំងនោះ, ណា
បើបានដឹងថា បុណ្យទាំងប៉ុន្មាន
ដែលខ្ញុំផ្សាយឲ្យ ចូរសោយក្សេមក្សាន្ត
ហើយសូមឲ្យបាន សុខសមបំណង ។
រួមទៀតបណ្តា
សត្វទាំងនោះ , ណា មិនដឹងទំនង

១ ព្រហ្មវិហារធម៌ទាំង ៤ មានមេត្តាជាដើមនេះ កុំមានក្នុងបាលីបត្តិទាន-គាថានេះទេ ប៉ុន្តែខ្ញុំចងក្រងរៀបរៀងផ្ទាត់មកតាមដំណើរសេចក្តី ។

នៃបុណ្យដែលខ្ញុំ ធ្វើផ្ញើផ្សាយផ្សង
សូមទេវតាផង អញ្ជើញជួយប្រាប់ ៗ
ដល់សត្វទាំងនោះ
ឲ្យដឹងចំពោះ បុណ្យនេះឆាប់ ៗ
ឲ្យបានស្រុះស្រួល ទទួលតាមច្បាប់
ត្រេកអរប្រញាប់ ក្នុងបុណ្យប្រពៃ ៗ
សត្វទាំងឡាយណា
នៅក្នុងលោកា ទាំងអស់នោះនៃ
សោយនៅដោយសារ អាហារសព្វថ្ងៃ
ចូរបានកស្រ័យ ផលបុណ្យថ្លៃពិត ៗ
សត្វទាំងនោះឯង
ចូររស់នៅវែង ដោយសុខពិសិដ្ឋ
ចូរបានភោជន គ្រប់គ្រាន់តាមចិត្ត
ដោយបុញ្ញឫទ្ធិ ដែលខ្ញុំគិតផ្សាយ ៗ
ដូចចិត្តខ្ញុំប៉ង
ឧទ្ទិសផ្សាយផ្សង ដល់សត្វទាំងឡាយ
សូមពួកសត្វបាន សុខសាន្តសព្វកាយ

រីកពយសេចក្ដីយ . . .    គ្រប់គ្នាទៅហោង (១)    ។

ចប់

## បត្តិទានគាថា

យា ទេតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មធានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ

---

១ ពាក្យកាព្យដែលមានក្នុងសៀវភៅនេះ គ្រង់ខាងដើមក្ដី គ្រង់កណ្ដាលក្ដី គ្រង់ខាងចុងនេះក្ដី ខ្ញុំបានចងក្រងរៀបរៀងឡើងដោយពិនិត្យតាមក្បួនកាព្យដែលមានគោលដ៏ត្រឹមត្រូវជាគ្រឿងសម្គាល់ ៦ យ៉ាងគឺ ១- សាត្ថៈ ប្រកបដោយអំពើរសេចក្ដី ; ២- សព្វញ្ញានៈ ប្រកបដោយតួអក្សរកំណត់ពាក្យត្រឹមត្រូវ ; ៣- រ គឺឡល់ រ ; ៤- ស គឺឡល់ ស ; ៥- វិសជ្ជនីយ រះមុខ (:) ; ៦- យុគលពិន្ទុ ចំណុចពីរខាងមុខតួអក្សរដែលត្រូវចុច (:) ; គ្រឿងសម្គាល់ទាំង ៦ យ៉ាងនេះ ជាគោលដ៏ទៀងទាត់របស់ក្បួនកាព្យដែលត្រឹមត្រូវល្អស ប្រាប់ផ្ទៀងពាក្យកាព្យឲ្យដឹងខុសត្រូវ ដែលលោកកវីពីបុរាណ និងកវីដ៏ស្រួចស្រាស់ដែលតែងក្បួនកាព្យទៀងទាត់ក្នុងបច្ចុប្បន្ននេះ បានកំណត់ត្រាទុកមកហើយ ។

ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។

ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សង្ឃោ ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយ ច
អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ
វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។

*ទេវតាទាំងឡាយណា មាននៅលំនៅសង្ឃ*
*ក្នុងទីនោះ ៗ ក្រង់ ជឿនព្រះស្តូប – ពោធិព្រឹក្ស*
*ទេវតាទាំងឡាយនោះ យើងចំពោះនឹករលឹក*
*បូជាបុណ្យអំពិត ដោយធម្មទានដ៏ឧត្តម ៗ*
*ចូរធ្វើទៅសួស្តី ទុកក្នុងទីឋានមនោរម្យ (១)*
*មណ្ឌលវិហារធំ ជាលំនៅសង្ឃនេះណា*
*វព្រះភិក្ខុសង្ឃ រៀនពល់អត្ថក្នុងសីមា*
*ជាថេរថ្លៃថ្លា ជាកណ្ដាល ឬ ចួសថ្មី ៗ*
*ឧបាសកទាំងឡាយណា ឧបាសិកាម្ចាស់ទានក្ដី*

---

១ ទីជាទីរីករាយចិត្ត ឬ ទីដែលគួរឲ្យសប្បាយចិត្ត ក្នុងទីនេះសំដៅយកទីលំនៅរបស់ព្រះសង្ឃ ដែលជាទីរីករាយសប្បាយខាងផ្លូវធម៌ ។

តាំងញោមវត្តប្រុសស្រី　　តាំងអ្នកស្រុកអ្នកនិគម
តាំងជនអ្នកប្រទេស　　ជនវិសេសជាឧត្តម
ពួកសត្វតាំងតូចធំ　　សូមឲ្យបានសុខល្អផើត ។
មួយទៀតពួកសត្វណា　　ជាជលាពុជៈកើត ,
អណ្ឌជៈកំណើត　　ឬ សំសេទជៈខ្ទ
ឬ មានកំណើតជា-　　ឧបបាតិកៈជន
ចូរបានសុខគ្រប់គ្រាន់　　ពីបច្ចុប្បន្នតទៅមុខ ។
ពួកសត្វតាំងអស់នោះ　　ចូរផុតគ្រោះកាចកើតទុក្ខ
ចូរបានសេចក្ដីសុខ　　បានកស្រ័យធម៌ប្រសើរ
ជានិយ្យានិកៈ(១)　　ធម៌សេដ្ឋៈនាំដំណើរ
ឲ្យដល់ទីប្រសើរ　　កើតមិនសល់ទុក្ខទាំងពួង ។
សូមធម៌ពួកសប្បុរស　　ឋិតនៅតែរស់កាលយូរលង់
តាំងលោកអ្នកទ្រទ្រង់　　សូមឋិតយូរអង្វែងណា
សូមព្រះសង្ឃមូលមិត្រ　　ព្រមព្រៀងចិត្ត កាយ វាចា
ដើម្បីកើតផលា　　សុខចម្រើនប្រយោជន៍ធំ ។
សូមព្រះសទ្ធម្ម　　ជួយរក្សាពួកយើងខ្ញុំ
តាំងពួកអ្នកអប់រំ　　ខំប្រព្រឹត្តនូវធម៌ផង ។

---

១ ធម៌ដែលនាំសត្វឲ្យចេញចាកសង្សារទុក្ខ សំដៅយកព្រះអដ្ឋង្គិកមគ្គ ។

សូមពួកយើងបានដល់ ចម្រើនផលល្អគ្រប់

ក្នុងធម៌ឥតសៅហ្មង ព្រះអរិយៈលោកទេសនាហើយ ។

ចប់

---

# អភយបរិត្តគាថា

ទុក្ខប្បត្តា ច និទ្ទុក្ខា

ភយប្បត្តា ច និព្ភយា

សោកប្បត្តា ច និស្សោកា

ហោន្តុ សព្វេបិ បាណិនោ ។

ពួកសត្វទាំងពួង – ដែលដល់ទុក្ខា

លំបាកកាយា – សូមបាត់ទុក្ខទៅ

ដែលដល់នូវភ័យ – បានក្តីហ្មងសៅ

សូមបាត់ភ័យទៅ – កុំគប្បីមាន

ដែលដល់នូវសោក – វិយោគគ្រប់ប្រាណ

សូមឲ្យក្សេមក្សាន្ត – បាត់សោកទៅហោង ។

ចប់

---

អត្ថបទ

## សូត្ររំលឹកបុណ្យ(១)

នមស្ការ   នមោ ទុនកាយ

គាថា ចិត្តថ្វាយ ... បង្គំប្រណម្យ
ត្រោះព្រះគតថៃ អរហន្តឧត្តម
អគ្គនោះបរម សម្មាសម្ពុទ្ធ ។

បង្គំព្រះធម៌

ថ្ងៃថាបវរ ព្រះសង្ឃវិសុទ្ធិ
ដោយកតុភាព ក្រួញក្រាបលំអុត
ត្រ័យរ័ត្នវិសុទ្ធ សូមសុខសួស្តី ។

រំលឹកបុណ្យ – ខ្ញុំសូត្របាទបទ

បង្គំត្រ័យរ័ត្ន គុណកែវទាំងបី
ហើយរំលឹកបុណ្យ មុន ៗ នោះក្តី

---

១ ការរំលឹកបុណ្យដែលធ្វើរួចហើយ ជាចេតនាមួយដ៏ប្រសើរឈ្មោះអបរាបរចេតនា ជាហេតុឲ្យទាយកអ្នកធ្វើទានបានបុណ្យច្រើន ; ក្រុមពុទ្ធបរិស័ទអ្នកភូមិជើងគោរ បានធ្វើគ្នាជាព្រះត្រៃបិដក១ចប់ សាងទុកក្នុងព្រះពុទ្ធសាសនាសម្រាប់អាស្រមសន្តិវ័ន សង្កាត់ជើងគោរ របាប្បៀរ កំពង់ធ្នាំង, អត្ថបទនេះ ដែលខ្ញុំបានចងក្រងរៀបរៀងឡើង ក៏ព្រោះប្រារព្ធនូវព្រះត្រៃបិដកនោះឯង ដំណាលគ្នានឹងព្រះត្រៃបិដកនោះដែរ ។

និងបុណ្យថ្មីៗ    របស់យើងខ្ញុំ ។

ដែលខ្ញុំបានសាង

ទុកជាពស្ដុភាង    មគ្គផលឧត្ដម

ជាមិត្តនៃខ្លួន    មាំមួនជាធំ

ជាទីមនោរម្យ    ដូចដើមអាចិជាះ ។

<u>បកសករាជ</u>    កាលថ្ងៃអាទិត្យ (១)

ប្រាំបួនពេញពិត    កត្តិកមាស

ឆ្នាំមមីជាក់    អដ្ឋស័កសញ្ញា

ព្រះពុទ្ធសាសនា    កន្លងទៅបាន ។

ពីរពាន់ប្រាំរយ

ប្រាំបួនឆ្នាំដោយ-    ប្រាំមួយខែមាន

ប្រាំបីថ្ងៃចែស    នៅសេសសល់ខាន

ខាងមុខទៀតមាន-    ពីរពាន់បួនរយ ។

កៅសិបប្រាំកត់

ប្រាំខែកំណត់    ថ្ងៃមួយថ្ងៃឲ្យ-

ដ៏កាលខាងមុខ    គិតទុកកុំក្លាយ

---

១ ព្រះត្រៃបិដកនៅអាស្រមសន្តិនៃ ជើងគ្រាវ ពុទ្ធបរិស័ទបានសាងកាលពី ថ្ងៃអាទិត្យ ៩ រោចខែកត្តិក ឆ្នាំមមីអដ្ឋស័ក ព.ស. កន្លងទៅ ២៥០៩ ។

រំលឹកញឹកញយ ឲ្យឃើញច្បាស់ថា ៈ។

<u>ធម្មទាន</u> យើងខ្ញុំតាំងឡាយ

ខំប្រឹងចំណាយ ទ្រព្យតាមសទ្ធា

សាងត្រៃបិដក កញ្ចក់សាសនា(១)

ដោយចិត្តជ្រះថ្លា ក្នុងពុទ្ធចក្រ ។

នាំគ្នាសិក្សា

គិតចម្រើនគុណា ព្យាយាមសង្វាត

សន្សំប្រាជ្ញា ទុកជាពូជស្អាត

ប្រតិបត្តិតាមខ្នាត លោកនាថសាស្តា ។

មួយទៀតបម្រុង

ពួកជនខាងចុង- ក្រោយយើងកល់គ្នា

ឲ្យបានអប់រំ អាគមសាសនា(២)

---

១ ព្រះត្រៃបិដក ទុកដូចជាកញ្ចក់ ឬ ជាកែវឆ្លុះយ៉ាងភ្លឺថ្លា សម្រាប់ឆ្លុះបំភ្លឺមើលផ្លូវប្រតិបត្តិនៃពុទ្ធបរិស័ទក្នុងព្រះពុទ្ធសាសនា ដែលប្រតិបត្តិស្វែងរកសេចក្តីសុខចម្រើនដល់ខ្លួន ។

២ អាគម គឺ ការមក, ដំណើរមកដល់; ការរៀនសូត្រ ; សេចក្តីដឹង , ការចេះដឹង ; គម្ពីរ ; សាស្ត្រ ឬ សាស្ត្រា , ពុទ្ធមន្ត ; ។ល។ អាគមសាសនា ក្នុងទីនេះសំដៅយកគម្ពីរព្រះត្រៃបិដក ។

សម្រាប់សិក្សា — កេរ្តិ៍គ្រូគ្រប់ ៗ
ជួយលើកតម្កើង
ឲ្យផុតរៀនឡើង — សាសនាព្រះអង្គ
ដោះខ្លួនចាកទុក្ខ — យកសុខជួបផង
ប្រកបក្ដីតម្រង់ — និព្វានសុខា ៗ

ឧទ្ទិសបុណ្យ — ហេតុផលឧត្ដម
នៃបុណ្យធារ៉ង់ — យើងខ្ញុំនេះណា៎
យើងខ្ញុំសូមចែក — ចំណែកផលា
ដល់សព្វសត្វា — ក្នុងលោកទាំងឡាយ ៗ
ទាំងមនុស្សទេវា
ជនព្រហ្មណាៗ — សូមនៅសប្បាយ
សូមរួចចាកទុក្ខ — បានសុខសព្វកាយ
ដោយយើងទាំងឡាយ — ផ្សាយបុណ្យថ្លៃថ្លា ៗ

សេចក្ដីប្រាថ្នា — ដោយបុណ្យនេះឯង
សូមសុខអផ្សែង — ដល់យើងខ្ញុំណា៎
សូមមានសិរី — សួស្ដីសោភា
មង្គលជយា — គ្រប់កាលកុំខាន ៗ

សូមមានប្រាជ្ញា

ធុះធុះភ្លឺថ្លា　　សាយសុះសព្វឋាន
ដោះស្រាយបញ្ហា　　យ៉ាងណាក៏បាន
ប្រាជ្ញប្រាយប្រោសប្រាណ　　បានដូចប្រាថ្នា ។

លុះព្រះពុទ្ធថ្លៃ

អរិយមេត្តេយ្យ(១)　　ទ្រង់ត្រាស់កាលណា
យើងខ្ញុំសូមបាន　　គន្ធសាស្តា
ស្តាប់ធម៌ទេសនា　　ព្រះអង្គប្រទាន ។

សូមត្រាស់ដឹងធម៌

មគ្គផលបវរ　　ប្រសើរថ្កើងថ្កាន
លះទុក្ខកិលេស　　សល់សេសប៉ុន្មាន
ចូលសិវស្ថាន　　គឺនិព្វានហោង ។

ចប់

អត្ថបទសូត្រតាំងសេចក្ដីប្រាថ្នា(២)

១ អានថា អរិយៈ មេត តៃ ។

២ សេចក្ដីប្រាថ្នានេះ កំណត់ទីបំផុតត្រឹមតែឲ្យបានទាន់ព្រះពុទ្ធព្រះនាមអរិយមេ-ត្តេយ្យ ហើយឲ្យបានសម្រេចមគ្គផលព្រះនិព្វានក្នុងសាសនារបស់ព្រះអង្គនោះឯង ។

បញ្ជាក់ការបុណ្យ៖ បុណ្យដែលយើងខ្ញុំបានសាងទុកជាសំណាងល្អហើយណា៎

ដោយចិត្តចេតសិកក្តីសទ្ធា　　សទ្ធាបញ្ញាជាសោភណ ៗ
សតិតម្រង់ចិត្តខ្ជាប់ខ្ជួន　　ព្យាយាម មាំមួនគិតគ្រប់គ្រាន់
នាំគ្នាធ្វើបុណ្យនាបស្រេកទ　　បានតាមសម័យចិត្តជ្រះថ្លា ៗ
គួរទៀតយើងសង្រួមទុកចិត្ត　　ជាបានបុណ្យពិតឥតកង្វា
ព្រោះបានពិនិត្យដល់ចេតនា　　សុទ្ធតែជ្រះថ្លាឥតសៅហ្មង ៗ
បុណ្យនេះអ្នកប្រាជ្ញលោកពន្យល់　　ថាត្រូវបានផលច្រើនកន្លង
ហេតុនោះយើងធ្វើបុណ្យម្តងៗ　　គួរច្រើនតាំងផ្គងចិត្តជ្រះថ្លា ៗ

ប្រាថ្នាទី១ - ដោយអានុភាពផលឧត្តម　　នៃបុណ្យការធំ.យើងខ្ញុំណា៎
សូមប្រណិធានតាំងប្រាថ្នា　　ឲ្យមានបញ្ញាវាងវៃឆ្លាត ៗ
ទុះធុះបុះសាយសព្វទីឋាន　　ប្រាជ្ញប្រាប់ប្រាសប្រាណប្រុងប្រៀបស្អាត
ដោះស្រាយបញ្ហាសូរសីហនាទ　　សុខសាន្តសព្វជាតិមានជោគជ័យ ៗ
មានអាយុវែងសប្បាយស្រស់　　សុខខ្ពស់មានយសមានសិរី
មានកម្លាំងច្រើនមានសួស្តី　　តាំងពីលោកិយដល់លោកនាយ ៗ
សូមមានមង្គលយ៉ាងសម្បូរ　　សម្បត្តិទ្រព្យហូរចូលងាយៗ
ញាតិផៅពឹងផងចូរខូលាយ　　សប្បាយកែកាយរៀងរាល់ថ្ងៃ ៗ

ប្រាថ្នាទី២- យើងខ្ញុំសូមតាំងចិត្តសច្ចា　　ប្រាថ្នាទាន់ព្រះពុទ្ធម្ចាស់ថ្ងៃ

ព្រះនាម អរិយមេត្តេយ្យ ជាមកុដកពៅក្រត្រាស់ខាងមុខ ៗ
សូមបានស្តាប់ធម៌ព្រះសាស្តា ទេសនាប្រោសសត្វកាត់កងទុក្ខ
កាត់កងកិលេសស្រស់ស្អាញស្អុត នាំសត្វចូលស្រុកសុខក្សេមក្សាន្ត ៗ
ខ្ញុំសូមឲ្យបានត្រាស់ដឹងធម៌ មគ្គផលបវរល្អថ្កើងថ្កាន
ក្នុងព្រះសាសនាព្រះទ្រង់ញាណ ចូលព្រះនិព្វានគ្រានោះហោង ៗ

ចប់

## ពាក្យអារាធនាធម៌ទេសនា

ឱកាស មយំ យើងខ្ញុំតាំងចិត្តជ្រះថ្លា
សង្រួម កាយ វាចា ផ្ចៀងសោតាចាំស្តាប់ធម៌ ៗ
គោរពថ្វាយវន្ទា ក្រយគេនាកៅបវរ
គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃអគ្គសាវក ៗ
ហើយសូមអារាធនា ធម៌ទេសនាដោយចិត្តស្ម័គ្រ
ស្មោះត្រង់អរិយមគ្គ អរិយផលព្រះនិព្វាន ៗ
បពិត្រព្រះករុណា សូមមេត្តាប្រោសប្រទាន
ធម៌ទេសនាទូន្មាន ដល់យើងខ្ញុំទាំងអស់គ្នា ៗ
ឲ្យបានជាពូជបុណ្យ និងជាគុណកើតបញ្ញា

ព្រោះអភ័ព្វមិនទេសនា ព្រះករុណាត្រាស់ហោង ។

## ចប់

---

### នានាធម្មសម្មុហោ ចប់ដោយសង្ខេប ។

# នាមនៃពុទ្ធបរិស័ទ

## អ្នកមានសទ្ធាចំណាយប្រាក់បោះពុម្ព

### បព្វជិត

| | ចំនួន |
|---|---|
| ព្រះតេជព្រះគុណ ឈុម - លិត គង់នៅអាស្រមភ្នំតាបាំង | ២០០៛ |
| ព្រះធម្មាចារ្យ ម៉ី - ស៊ាន គង់នៅអាស្រមសន្តិវ័ន | ១២០០៛ |
| លោកគ្រូ ហៀង - ស៊ុន ,, ,, | ៣០០៛ |

ព្រះតេជព្រះគុណទាំងពីរព្រះអង្គនេះ គឺពុទ្ធបរិស័ទអ្នកមានសទ្ធា ចេញបច្ច័យថ្លៃពុម្ពប្រគេនលោក ព្រោះចង់ឲ្យមានព្រះនាមលោក ក្នុងការបោះពុម្ពសៀវភៅនានាធម្មសមុហោ នេះផងដែរ ។

### គ្រហស្ថ

| ឧបាសក ទាយក | និង ឧបាសិកា និង ទាយិកា | ទីលំនៅ | ចំនួន |
|---|---|---|---|
| លៀ · សេនយៀង | សឹម - សារី | បាត់ដំបង | ៣.៧០០៛ |
| | ឧបាសិកាអ៊ា · អេង | ភ្នំពេញ | ១.០០០៛ |
| ម៉ីង - ជ្រី | ម៉ម - ថៃ | ដើម-គ្រាក | ១.០០០៛ |
| ម៉ីង - គោត | អ៊ឹង - ប៉ោស៊ុម | ភ្នំពេញ | ១.០០០៛ |

| ឧបាសក | និង ឧបាសិកា | ទីលំនៅ | ចំនួន |
|---|---|---|---|
| សឺន – គួ | ហ៊ុយ – សាក | ភ្នំពេញ | ១២០០៛ |
| សឺន – វណ្ណាវេក | ម៉ែន – កៀន | " | ៣០០៛ |
| | អ៊ុន – យ៉ុន | " | ២០០៛ |
| | យួន – ណាល់ | " | ២០០៛ |
| តាច – ស៊ុយ៉ើន | គួ វណ្ណារី | " | ១០០៛ |
| សួន – ឈៀន | គួ សុនី | " | ១០០៛ |
| ចិក – ផា | សឺន សុភាពនារី | " | ១០០៛ |
| កុល – ម៉ុល | អ៊ិក យ៉ែន | " | ១០០៛ |
| | ឧឌូ – អ៊ុម | " | ១០០៛ |
| | ជុំ – ប៊ុន | " | ១០០៛ |
| | កៅ ឆែម | " | ១០០៛ |
| | យាន – សេនមួយ | " | ១០០៛ |
| | ស៊ូ – ខាត់ | " | ១០០៛ |
| ផា – ជុន | ខាន – ចូន | " | ១០០៛ |
| កន – គីមសន | ពាន់ – ថន | " | ១០០៛ |
| | ម៉ុញលុច | " | ១០០៛ |
| ពុក – អ៊ុម | គីម – សុត | " | ៧០៛ |

| ឧបាសក | និង ឧបាសិកា | មកពី | ចំនួន |
|---|---|---|---|
| | ញ៉ែម–អ៊ុត | ភ្នំពេញ | ៥០៛ |
| | ចាន់ ធុន | ,, | ៥០៛ |
| សោម-ជៀប | គិម | ,, | ៥០៛ |
| | អ៊ុន-យ៉ន | ,, | ៥០៛ |
| ហេង-ឡេ | | ,, | ៥០៛ |
| | អ៊ុស | ,, | ៥០៛ |
| យឿន-យៀប | គឹម-អ៊ុយ | ,, | ៥០៛ |
| | ញ៉ែម-ឃុត | ,, | ៥០៛ |
| ស៊ុម-ប៊ុត | ហម-ទឹម | ,, | ៥០៛ |
| នួន-សួង | ស៊ុម | ,, | ៣០៛ |
| នួន-ហ៊ុល | ងួប | ,, | ៣០៛ |
| សេ-សួស | គង់ | ,, | ២០៛ |
| | លន់ | ,, | ២០៛ |
| | ជឹម | ,, | ២០៛ |
| | កញ្ញា មាត់ផាប | ,, | ២០៛ |
| | ,, មាត់ជ៉ា | ,, | ២០៛ |
| អ៊ូម-គឹមល័ | | ,, | ២០៛ |

| ឧបាសក ទាយក | និង ឧបាសិកា និង ទាយិកា | ទីលំនៅ | ចំនួន |
|---|---|---|---|
| | ព្រុំ យុន | ភូមិដើមត្រាវ | ១២០០៛ |
| | ព្រុំ-ហួត | ,, | ១៤០០៛ |
| ម៉ុង អៀប | ជា ណាំ | ,, | ៨០០៛ |
| សូរ-ឡេង | នូ-ហ៊ឹម | ,, | ៥០០៛ |
| | ព្រុំ រឿង | ,, | ៤០០៛ |
| | ផែក ម៉ុន | ,, | ៤០០៛ |
| | គុច-វ៉ែន | ,, | ៣០០៛ |
| ម៉ូវ-អាង | លីម-ឈី | ,, | ៦៥០រ |
| ហ៊ុម ផុន | ជុំ-យ៉ាន | ,, | ២៥០រ |
| | ជា-ទីវ | ,, | ២០០រ |
| សំ-សយ | អឿន | ,, | ២០០រ |
| | លាង-មួន | ,, | ២០០រ |
| | កុន-ឆ៊ន | ,, | ២០០រ |
| ហាន់ ឌី | មួន យាប | ,, | ២០០រ |
| កែ-មួង | ផៃ-គិន | ,, | ២០០រ |
| ចក់ស្រេង | មាន-តាន់ថូ | ,, | ២០០រ |
| | សៃ-ឆាន់ | ,, | ២០០រ |

| ឧបាសក<br>ទាយក | និង<br>និង | ឧបាសិកា<br>ទាយិកា | ទីលំនៅ | ចំនួន |
|---|---|---|---|---|
| ម៉ម–ម៉េម | | អំ–សម | ភូមិជើងគ្រាក | ២០០៛ |
| ចក់–វិល | | ផា–នៃប | ,, | ២០០៛ |
| | | ព្រុំ ណៃ | ,, | ២០០៛ |
| ហៀង-ស៊ិន | | អ៊ុច-វឿន | ,, | ១០០៛ |
| យី-កិម | | ហេង ហេង | ,, | ១០០៛ |
| ផន | | គុល | ,, | ១០០៛ |
| ហែម-ឌិក | | ខន | ,, | ១០០៛ |
| | | ជួន-ក្រៃ | ,, | ១០០៛ |
| ហង់-គិន | | ញ៉ែក-អួន | ,, | ១០០៛ |
| ហួន-ហេង | | ស៊ួន | ,, | ១០០៛ |
| មាន-កុយ | | សេន | ,, | ១០០៛ |
| | | ផាម-ស៊ុន | ,, | ១០០៛ |
| ហៀង-ហោ | | ប៉ុក | ,, | ១០០៛ |
| គុំ-អម | | អំ-ម៉ៃ | ,, | ១០០៛ |
| មន-ចក់ | | ទុក-ចឹន | ,, | ១០០៛ |
| | | គឹម-ហុង | ,, | ១០០៛ |
| គៅ-លឹមហៃ | | | ,, | ១០០៛ |

| ឧបាសក ខាយក | និង និង | ឧបាសិកា | ទីលំនៅ | ចំនួន |
|---|---|---|---|---|
| សុខ-សំ | | ញា ផាត | ភូមិជើងគ្រារ | ១០០រ |
| អ៊ុន-ទិន | | ញា-ឌៀម | ,, | ១០០' |
| ញ៉ែម-ក្រន | | ញា-ធឿន | ,, | ១០០' |
| ទេព-ផស | | អ៊ុន-យ៉ន | ,, | ១០០' |
| កាន់-ជុន | | លិម-ធន | ,, | ១០០' |
| ហៀង-សុស | | ខាត់-ស៊ុន | ,, | ១០០' |
| ហាក់-យ៉ឹន | | | ,, | ១០០' |
| គឹម-ហ៊ៃល | | អ៊ុន-យាន | ,, | ១០០' |
| ហុក-ថេង | | យ៉ឹន-ទុំ | ,, | ១០០' |
| ឃួន-គឹន | | នុច-ពាញ | ,, | ១០០' |
| អែម-យ៉ាន | | ហ៊ុច | ,, | ១០០' |
| ហង់-ណុំ | | | ,, | ៥០' |
| | | គួ-យ៉ាន | ,, | ៥០' |
| មុំ-ផយ | | កិន-យន់ | ,, | ៥០' |
| មាស-ជួ | | យ៉ែម-កែម | ,, | ៥០' |
| និត | | ញ៉ោក-សែ | ,, | ៥០' |
| | | សារ៉ើន | ,, | ៥០' |

| ឧបាសក និង ឧបាសិកា<br>ទាយក និង ទាយិកា | | ទីលំនៅ | ចំនួន |
|---|---|---|---|
| គួន- ប៉ក់ | ម៉-អៀន | ភូមិជើងគ្រាវ | ៥០៛ |
| ស៊ិយ យ៉ិន | គិន-ជុន | " | ៥០៛ |
| វ៉ែន- ហួក | ថែន-វែម | " | ៥០៛ |
| ផល | វ៉ែន-សារូ | " | ៥០៛ |
| ក្រៃ-ឌីន | សុខ-តាន់ | " | ៥០៛ |
| ណាង- ម៉ក | ក៉ន-ប៊ូ | " | ៥០៛ |
| មាស-ប៊ិន | ណឹម | " | ៥០៛ |
| | ឃួន-យន | " | ៥០៛ |
| | សូ-ខាន់ | " | ៥០៛ |
| ម៉ឹង-ឈឹន | ហុក-ប្រិប | " | ៥០៛ |
| ញ៉ាក ចឹង | មុក-កាន | " | ៥០៛ |
| | ព្រំ-ផៃ | " | ៥០៛ |
| ណៃ | ហួក | " | ៥០៛ |
| | ឧបាសិកាម៉ក | " | ៥០៛ |
| សយ | អ៊ិត | " | ៥០៛ |
| ហង់- ព្រី | ឌុប-ពន | " | ៥០៛ |
| ផន | ម៉ម- សោយ | " | ៥០៛ |

- ៨ -

| ឧបាសក ទាយក | និង និង | ឧបាសិកា ទាយិកា | ទីលំនៅ | ចំនួន |
|---|---|---|---|---|
| ទូ-ហ៊ូ | | កៅ-សុស | ភូមិជើងគ្រាវ | ៤០៛ |
| | | ប៉ុល-ហ៊ៀ | " | ៣០៛ |
| | | ឈុំ-ឌា | " | ៣០៛ |
| ញ៉េក ចក | | | " | ៣០៛ |
| ទូ-យ៉ែម | | កៅ-សួន | " | ២០៛ |
| | | វ៉ន-ឈុំ | " | ២០៛ |
| | | កែម | " | ២០៛ |
| | | ឯក ជុំប | " | ២០៛ |
| គង់ យុន | | ស-គំ | " | ១០៛ |
| គង់-បាន | | ជុប | " | ១០៛ |

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **សំ ហ្សឺឌី**

កញ្ញា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ីស និងលោកម្ដាយ ឱន សៅខុន

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org